# មនុស្ស
# សិល្បៈ
# ជំនឿ



PETER FRECKLINGTON

៤១២.
១៤

# ជុច ភឿន

បរិញ្ញាប័ត្រ បុរាណវិទ្យា

មនុស្ស - សិល្បៈ

និង ជំនឿ

ជុច ភឿន

វប្បធម៌ - សិល្បៈ

LIBRARY
BUDDHIST INSTITUTE

មនុស្ស - សិល្បៈ និង ជំនឿ
ផ្សាយចេញអំពីគណៈកម្មការ
ស្រាវជ្រាវសាកលវិទ្យាល័យ
វិចិត្រសិល្បៈ ។
ភ្នំពេញ ១៩៩៣

# សហការី រួមយោបល់

និងជំនួយការ

ស៊ិក ប៊ុន ហុក

ជា ពន្លក

តែ ជិន រិទ្ធ

ចាន់ សុំផា

ភៀ សុផា

ហេង ប៊ុនតុង

ភៀន ឆដាភា

# ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីស្សូ កូសី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ការុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh www.elibraryofcambodia.org

# កថាមុខ

មូលហេតុអ្វីដែលនាំអោយខ្ញុំខិតខំសរសេរស្នាដៃសាកល្បង ពិចារណានេះឡើង ? ដោយយល់ថា ការចេះចាំតែម្នាក់ឯង ពុំមានផលប្រយោជន៍អ្វីសំរាប់សមូហភាពសោះ ។ រីឯស្នាដៃមួយរបៀបនេះដែលមានខ្លឹមសារសង្កត់ធ្ងន់ទៅលើតំលៃបុរាណវិទ្យា និង មនុស្សនិយមពុំទាន់មានបោះពុម្ពជាខេមរភាសានៅឡើយទេ ។ អស់លោកអ្នកប្រាជ្ញ អ្នកនិពន្ធ ដែលបានសិក្សារួចហើយអំពីបុរាណវិទ្យានៅលើបេតិកភណ្ឌជាតិកម្ពុជា ពិតជាអ្នកត្រួសត្រាយផ្លូវផ្តល់ប្រយោជន៍ធំធេងណាស់សំរាប់ប្រវត្តិសាស្ត្រជាតិខ្មែរ ។ សៀវភៅជាច្រើនរយក្បាល បានលាតត្រដាងពិនិត្យតែផ្នែកបុរាណវិទ្យាប៉ុណ្ណោះទេ តែថែមទាំងសិក្សាអំពីទំនៀមទំលាប់នៃការរស់នៅ វប្បធម៌ និង សង្គមជាតិ និងចូលជ្រៅទៅដល់វិស័យ ចិត្តវិទ្យា និង ជាតិពន្ធុសាស្ត្រ របស់ប្រជាជនកម្ពុជាថែមទៀត ។ ប៉ុន្តែសៀវភៅទាំងឡាយពោលខាងលើ ស្ទើរតែបោះពុម្ពជាភាសាបរទេស ដែលជះឥទ្ធិពលរារាំងមិនចំពោះប្រយោជន៍ប្រជាជនជាទូទៅបាន ។ ស្នាដៃជាច្រើនទៀតដែលបោះពុម្ពជាខេមរភាសារួចហើយ របស់បណ្ឌិតសាស្ត្រាចារ្យខ្មែរជាអ្នកស្រឡាញ់វប្បធម៌ជាតិ និងចង់ពង្រីកពុទ្ធិបន្ថែមសំរាប់កុលបុត្រខ្មែរ បានរលាយស្ទើរបាត់ស្រពោនអស់ក្នុងរបបប្រល័យពូជសាសន៍ ក្នុងចន្លោះឆ្នាំ ១៩៧៥ - ១៩៧៩ ។

អាស្រ័យដោយមានបំណងចង់រក្សាតំលៃពិតរបស់វប្បធម៌ខ្មែរ ជាប្រយោជន៍សមូហភាព ដើម្បីស្វែងយល់អំពីវប្បធម៌របស់ខ្លួន តាមរយៈស្នាដៃសាកល្បងដ៏តូចនេះ ខ្ញុំខិតខំស្រាវជ្រាវដោយពុំរង់ចាំ អ្វីដែលហៅថា " សុក្រិតភាព " នោះឡើយ ។

ពេលវេលាចេះតែរសាត់បាត់ទៅដោយឥតរង់ចាំ ទន្ទឹមនោះ ឯកសារ " រស់ " ឬមួយចំនួនដែលសេសសល់អំពីការសម្លាប់រង្គាល បានលាចាកទឹកដីអង្គរជាទីគោរព និងស្រឡាញ់ដោយនាំទៅជាមួយនូវឯកសារវប្បធម៌ដ៏មានតម្លៃជាបន្តបន្ទាប់ ។ កត្តាពោលខាងលើនេះហើយដែលជំរុញអោយខ្ញុំព្យាយាមសរសេរឯកសារនេះ ដើម្បីជាការតបស្នងសងគុណចំពោះមាតុភូមិ ។ កូនសៀវភៅដ៏តូចនេះនិងបូកចំណែកក្នុងកិច្ចការពារ និងកសាងមាតុភូមិស្របតាមទិសដៅរួមលើវិស័យវប្បធម៌របស់

មហាសន្និបាតបក្សប្រជាជនបដិវត្តកម្ពុជា ។ ខ្ញុំបានលើកឡើងអំពីលោកទស្សនៈចាស់ដើម្បីជាពន្លឺ សំរាប់ការស្វែងយល់លោកទស្សនៈថ្មី ហើយនិងសម្បត្តិកម្មផ្ទាល់ខ្លួនខ្លះៗ ដើម្បីស្វែងយល់តើស្នាដៃបុព្វបុរសខ្មែរយើងបង្កប់ទស្សនៈលោកិយសច្ចៈធំធេងប៉ុណ្ណាទៅ នៅពីក្រោយស្នាដៃទាំងឡាយនោះ ។ បញ្ហាគំនិតធំៗ ដែលបានលើកឡើងក្នុងឯកសារនេះ គឺបានមកអំពីការផ្តួចផ្តើមឡើងរបស់ព្រឹទ្ធសាស្ត្រាចារ្យ ផេង ផុន ដែលភក្តីបារម្ភ ចំពោះវប្បធម៌របស់លោក ក៏ដូចជារបស់ខ្ញុំដែរ ។ ខ្ញុំបានយកគតិបណ្ឌិតរបស់លោកមកពង្រីកបន្ថែមលើការគេះគាំរបស់ខ្ញុំ និងញែកគ្នារវាងលោកទស្សនៈចាស់ និង ថ្មី សំរាប់មើលអោយឃើញអ្វីដែលជាតម្លៃរបស់ខ្មែរពិតៗ ។ ខ្ញុំយល់ថា កូនសៀវភៅនេះមិនទាន់ឆ្លើយតបទៅនឹងក្តីប្រាថ្នា របស់សិក្ខាកាមជន អ្នកប្រវត្តិសាស្ត្រ អ្នកស្រាវជ្រាវ អ្នកស្រឡាញ់វប្បធម៌ជាតិ អោយបានគ្រប់ជ្រុងជ្រោយទេ តែបើខ្ញុំរង់ចាំ ហើយខ្លាចពិន មិនបានសរសេរនោះ គឺមានន័យថា ខ្ញុំពុំទាន់បានតបស្នង សងគុណចំពោះប្រទេសជាតិរបស់ខ្ញុំនៅឡើយ ។

សូមឧទ្ទិសស្នាដៃនេះចំពោះ អ្នកមានគុណនារា ជុត - ហៃ និង ប៊ីន ភើ ដែលបានផ្តល់កំណើតនិងលះបង់អ្វីៗទាំងអស់ ដើម្បីបង្កលទ្ធភាពអោយខ្ញុំបានសិក្សារៀនសូត្រ ហើយនិងចំពោះព្រលឹងបុព្វបុរសដែលបន្សល់ទុកកេរ្តិ៍ដំណែលដ៏ស្តុកស្តម្ភ សំរាប់ផ្តល់តម្លៃដល់ប្រទេសកម្ពុជា លើឆាកអន្តរជាតិ ។ ក្នុងអវសានកថានេះ ខ្ញុំសូមថ្លែងអំណរគុណចំពោះព្រឹទ្ធសាស្ត្រាចារ្យ ផេង ផុន និង សហការីរួមការងារក្នុងសមាគមវប្បធម៌ពីតែប៉ូយ ដែលបានជួយធ្វើអោយសំរេចឯកសារនេះឡើង ហើយក្នុងនោះក៏មានភរិយាខ្ញុំ នាង គាន់ ធុំ ដែលជាអ្នកបានសិក្សារៀនសូត្រក្នុងជំនាញជាមួយគ្នា បានចូលរួមយោបល់ដើម្បី ជួយធ្វើអោយកូនសៀវភៅ នេះមានកំណើតឡើងដែរ ។

ភ្នំពេញ , ថ្ងៃ ទី ២៤ ខែ មិថុនា ឆ្នាំ ១៩៨៨

អ្នកស្រាវជ្រាវ

ជុត ភឿន

# វប្បធម៌ សិល្បៈ

## ជំពូក ១

## សិក្សាបុរាណវិទ្យា

### I . អ្វីទៅហៅថា វិមានប្រវត្តិសាស្ត្រ ៖

វិមានប្រវត្តិសាស្ត្រ គឺ ជាសំណង់ " អចលនវត្ថុ " ឬ ជាចលនវត្ថុ ដែលជាកម្មសិទ្ធិរបស់សម្បត្តិសាធារណៈ ឬ ឯកជនដែលត្រូវបានគេដាក់អោយនៅក្រោមច្បាប់ពិសេស អាស្រ័យដោយវាមានប្រយោជន៍ជាប្រវត្តិសាស្ត្រ ឬ សិល្បៈ បន្ទាប់ពីមានចាត់ទុកជាផ្លូវការរួចហើយ ធ្វើឡើងដើម្បីធានាដល់ការថែរក្សាទុកនៃសម្បត្តិនេះ ។

បុរាណវិទ្យាជាវិទ្យាសាស្ត្រមួយ ដែលសិក្សាពន្យល់អំពីអតីតកាលតាមរយៈប្រាង្គប្រាសាទ ហើយនិងសិក្សាអំពីបុរេប្រវត្តិសាស្ត្ររបស់ប្រជាជាតិ ។ វិទ្យាសាស្ត្រនេះឆ្លុះបញ្ចាំងអារ្យធម៌ តាមរយៈវិទ្យាសាស្ត្រដទៃជាច្រើនទៀត ដូចជា នរវិទ្យា ជាតិពន្ធុវិទ្យា ជាសាណវិទ្យា ភូគព្ភសាស្ត្រ ។ល។ ដែលជំនួយអោយអ្នកសិក្សាយល់អ្វីដែលជាគ្រឹះ នៃអារ្យធម៌របស់មនុស្ស ។ បុរាណវិទូជាច្រើនបានសិក្សាអំពីអារ្យធម៌ខ្មែរនាសម័យថ្មរំលីង ដូចជាសំរោងសែន ម្លូព្រៃ អន្លង់ព្រាវ[1] ហើយនិងល្អាងស្ពាន។ ស្ថានីយ៍ទាំង ក្រោយនេះ បានប្រាប់អាយុកំនូន ៤២៩០ ឆ្នាំ មុនគ្រិស្តសករាជរបស់ប្រជាជនកម្ពុជា ដែលចេះប្រើប្រាស់ គួម ឆ្នាំង សំរាប់ចំអិនម្ហូបអាហារ ។

សេចក្តីសន្និដ្ឋានកំណត់ថា ប្រជាជនកម្ពុជា បានរស់នៅក្នុងល្អាងស្ពាននេះតាំងពីប្រមាណ ៨០០០ ឆ្នាំមុនគ្រិស្តសករាជនោះមកម្ល៉េះ[2] ។ ការវត្ថុតាំងជាច្រើនទៀត ដូចជាធានរបស់ស្ថានីយ៍ សំរោងសែន ពូធៅថ្ម ថ្មែកល្អៀវ ធ្វើអំពីសំរិទ្ធ គ្រឿងអលង្ការ នាកាលខាងដើមនៃប្រវត្តិសាស្ត្រ ។ល។ ចាប់តាំងពីពាក់កណ្តាលសតវត្សទី ១៩ មកពណ្ណលោកអ្នកប្រាជ្ញ ស្លាបត្សករ បុរាណវិទូ បានបង្ហើកខ្មៅជាច្រើនដើម្បីកត់ត្រាអ្វីដែលយើងហៅថា វិមានប្រវត្តិសាស្ត្រ ដែលត្រូវបានចុះបញ្ជីចត្រេស ហើយៗដាក់អោយនៅក្រោមច្បាប់របស់រដ្ឋ ដើម្បីធានាដល់ការថែរក្សាជូនសង្គម

---

(១) អន្លង់ ព្រាវពុ អន្លង់ព្រៅ ស្ថិត នៅខេត្តកំពង់ឆ្នាំង [illegible]

(២) [illegible] បុរេប្រវត្តិនៅល្អាងស្ពាន [illegible] ប្រទេសកម្ពុជា ដោយ [illegible] និង [illegible] - [illegible] ទស្សនាវដ្តី លេខ ២ ខែកក្កដា [illegible]



កម្ពុជា: ផែនទីរូប និង មនុស្ស

ខ្សែតំនួសធំ : បង្ហាញជួរភ្នំ ។ តំនួសដាច់បង្ហាញព្រំប្រទល់ ។ ខ្សែតំនួសជាចំណុច : បង្ហាញព្រំខណ្ឌតំបន់ទឹកលិចរៀងរាល់ឆ្នាំ ។ ខ្សែតំនួសជាប់ តូច ជុំវិញបឹងធំ : បង្ហាញទីដីកោនប្រជាជនច្រើន ដកស្រង់អំពី - ឌិល ដែរត៍ ។

និងដាក់តាំងក្នុងសារមន្ទីរ ។ នៅទីនេះ យើងបានសិក្សា បុរាណវិទ្យាស្របទៅតាមទស្សនៈម្ួយរបស់ ហ្វីបាច ដែលលោកបាន កត់សំគាល់ថា " គេមិនបានកសាងប្រាង្គប្រាសាទឡើង ដើម្បីថ្វាយអាទិទេពទេ ក៏ប៉ុន្តែគេបានកសាងប្រាសាទ ដើម្បីតំណាងស្ថាបត្យកម្ម នេះហើយជាទូទៅមានតម្លៃសំរាប់សិល្បៈ " ។ ជាការពិតណាស់ នៅក្នុងសតវត្សទី ១៣ សំណង់ជាច្រើនសាងឡើងដើម្បីជាបញ្ជោជាយសំដែងប្រាប់អ្វីដែលមាននៅក្នុងជីវិតប្រជាជន ដូចជាសេចក្តីសប្បាយ និង សុភមង្គល ការឈឺចាប់ និងទុក្ខព្រួយ អំពើល្អ និង អាក្រក់ ...

១.១. តួលេខ នៃវិមានប្រវត្តិសាស្ត្រដកស្រង់អំពីបញ្ជីសារពើភណ្ឌចុះបញ្ជីរួចហើយ÷ [៣]

| ល.រ | បណ្តាខេត្ត | ចំនួន | សំគាល់ផ្សេងៗ |
|---|---|---|---|
| ១ | - បាត់ដំបង ... | ៣៥៤ | |
| ២ | - សៀមរាប ... | ២៩២ | |
| ៣ | - កំពង់ធំ ... | ១៦៤ | |
| ៤ | - កំពត ... | ៨ | |
| ៥ | - កណ្តាល - ភ្នំពេញ... | ៩ | |
| ៦ | - កំពង់ចាម ... | ៤៨ | |
| ៧ | - កំពង់ឆ្នាំង ... | ៩ | |
| ៨ | - កំពង់ស្ពឺ ... | ៦ | |
| ៩ | - ក្រចេះ ... | ១២ | |
| ១០ | - ព្រៃវែង ... | ២៧ | |
| ១១ | - ពោធិសាត់ ... | ៧ | |
| ១២ | - ស្ទឹងត្រែង ... | ៥៤ | |
| ១៣ | - ស្វាយរៀង ... | ៦ | |
| ១៤ | - តាកែវ ... | ៣៤ | |
| | | សរុប : ១០៧០ | |

(៣) នាយកដ្ឋាន ម.ស.វ. : បញ្ជីវិមានប្រវត្តិសាស្ត្រ សន្និបាតប្រចាំឆ្នាំ ១៩៧០

១.២. សិល្បៈរបស់សោភ័ណវិទ្យា ពិចារណាសិល្បៈទុកដូចជាប្រព័ន្ធនៃបណ្ដាទំនាក់ទំនងទាំងឡាយនៃនិម្មិតកម្មសិល្បៈ ដែលបានរៀបចំឡើងទៅតាមក្រិត្យក្រមទាំងឡាយយ៉ាងត្រឹមត្រូវណាស់។ គ្មានបាទិយកម្ម ឯកភាពអំពីសិល្បៈទេ គឺមិនទាន់គេអាចស្រង់យកគោលការណ៍ខ្លះ អំពីការចែងចែកសិល្បៈជាក្រុមៗ ដែលបង្ហាញបណ្ដាចំណុចស្មុគស្មាញនានា។ ទាំងនិយកម្ម[៦] ដែលចែកសិល្បៈជា ៣ ក្រុម ដោយញែកច្បាស់បំផុតនោះគឺ :

១.២.១ - សិល្បៈអចលៈ " ស្ដាទិក " ក្នុងសិល្បៈនេះ រូបភាព " ចំនិត ភាសា និងការស្រមៃ " មួយបានគេដាក់អោយនៅនឹងក្នុងអវកាស ហើយមិនអភិវឌ្ឍន៍ទៅតាមពេលវេលា ។ សិល្បៈប្រភេទ ទី ១ នេះគឺមានជាអាទិ៍ សិល្បៈសូនរូប និង ស្ថាបត្យកម្ម ។

១.២.២ - សិល្បៈ ចលៈ " ឌីណាមិក " ក្នុងសិល្បៈនេះ រូបភាពមួយវិវត្តទៅតាមពេលវេលាមួយជាកំណត់ ហើយគ្មានអត្ថិភាព អវកាសទេ ។ សិល្បៈប្រភេទ ទី ២ នេះ គឺ អក្សរសិល្ប៍ ភ្លេង ។

១.២.៣ - សិល្បៈអចលៈ-ចលៈ ក្នុងសិល្បៈនេះ រូបភាពមួយគឺ ជាការផ្ដុំទំនាក់ទំនងពីរខាងលើ ។ សិល្បៈប្រភេទ ទី ៣ នេះ គឺរាល់សិល្បៈនៃទស្សនីយភាព ។

តើមូលហេតុអ្វីដែលនាំអោយប្រជាជនកម្ពុជា កសាងវិមានដែលមានតម្លៃប្រវត្តិសាស្ត្រ - សិល្បៈនេះឡើង ? ការសិក្សាស្រាវជ្រាវទៅលើមនុស្សតាំងពីអតីតកាលដ៏យូរលង់ណាស់ គឺតាំងពីពូជសាសន៍នេអង់ដែកតាល់មកដល់ ក្រូម៉ាញ៉ុង និងត្រីប៉ាត់ឌី បានបង្ហាញច្បាស់ថា សិល្បៈកើតចេញអំពីការថែប្រឌិតបច្ចេកទេសផ្សេងៗ សំរាប់ជំពីជីវភាពប្រចាំថ្ងៃ របស់មនុស្ស ហើយនិងជំនឿដំបូងៗទៅលើលទ្ធិជីវចលៈ " ព្រលឹង " ។ ម្យ៉ាងទៀត យើងក៏សង្កេតឃើញផងដែរថា រាល់ទំរង់សិល្បៈគំនូរកើតចេញអំពីការគូសព្រាងទុក ។ ពីព្រោះការគូសព្រាងទុក គឺជាការសង្កេតដោយត្រង់ដែលៗ ពីការចាក់ចិត្តរបស់អ្នកនិពន្ធ គឺ សិល្បករ ។ ៣ ។ ទៅលើធម្មជាតិដែលរស់រវើក នៅជុំវិញខ្លួនយើង ហើយនិងភាពចំរុះរបស់ជាតុក្ខតធម្មជាតិ ។ ដោយឡើងលេចអំពីនេះ សិល្បៈ ប្រាកដនិយមក៏បានចាប់កំណើតឡើង ។ ហើយជាបន្តបន្ទាប់មកក៏វិវត្ត ទៅកាន់សិល្បៈប្រភេទអរូបិយ៍ ប្រភេទសិល្បៈចំព្រាញ " សេម៉ាតិស " ហើយនៅក្នុងក្រោយវាវិវត្តទៅរកប្រភេទនិមិត្តរូប ។ តាំងពីមនុស្សចេះគប់ថ្មោធ យើងឃើញការស្ថាបត្យកម្មដែក ជុលម៉ុន និង ម៉ុនហៀរ ដែលគេសាងឡើងសំរាប់បញ្ចុះសាកសព ហើយនិងការកសាងជាប្រាសាទសាធិ នៅប្រទេសអេស៊ីប កសាងផ្នូរខ្មោចធំៗដោយពូនដី

(៦) កាមកាន់ត្ន

ដូចគ្នំ ក្នុងប្រទេសចិន កសាងប្រាសាទតូចៗ យំអដោយតិរតិរុខ នៅកោះថ្វា និងប្រាសាទធំៗ ដូចជាប្រាសាទបាយ័ន្ត ប្រែរូប ជាខែង បន្ទាយសំរែ អង្គរវត្ត ។ល។ នៅក្នុងប្រទេសកម្ពុជា ហើយនិងការកសាងចេតិយធំៗនៃអារ្យធម៌ ឥន្ទ និង សិល្បៈផ្លូវខ្មោច " កាតាកុម " នៅប្រទេសអ៊ីតាលី ។ ចាប់ផ្ដើមអំពីការប្រើប្រាស់បច្ចេកទេសសាពញ្ញក្នុងការបញ្ចុះផ្ទាំងថ្មទៅក្នុងដី ឬ លើកបន្ទុបលើគ្នា រហូតដល់ធ្វើបន្ទប់ល្អៗ មានទាំងលំអជញ្ជាំងដោយតំនួរ ឬ បញ្ចុះសពទៅក្នុងបន្ទប់ មានប្រព័ន្ធស្មុគ្រស្មាញនៅក្រោមប្រាសាទ ពៀរ៉ាមីត " រាងសាជី " និង ទុយបុលុស " ផ្លូវដូចគ្នំ " ហើយនិងសាងសំណង់ស្ថាបត្យកម្ម ប្រកបដោយក្បូរក្បាច់ធនាយ៉ាងវិចិត្រ មនុស្សបានចំរើនទាំងជីវិតលោកិយសច្ចៈ ពោលគឺកសាងបូជដ្ឋានសំការៈ ដើម្បីចំរើនស្មារតិ ក្នុងតារេយវិហារ ដែលនៅទីនោះ យើងមើលឃើញជ្រុងនៃជីវិតរបស់មនុស្ស ហើយនិងទាំងជំនឿរបស់ប្រជាជនក្នុងរយៈ កាលប្រវត្តិសាស្ត្រមួយជាកំណត់ ។

ជំនឿមួយដែលមានប្រាកដនិយមនៅក្នុងប្រទេសកម្ពុជា និយាយដោយឡែក ឬ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍នៃភាសាក្រុមអូស្ត្រូ-អេស-ស្ទីត និយាយរួម មានស្ទើរនៅឡើយ រហូតមកដល់បច្ចុប្បន្ននេះ ។ ជំនឿនេះបានក្លាយទៅជាប្រពៃណីដ៏សំខាន់ណាស់ទៅហើយ ហើយអាចចាត់ទុកបានដូចជាព្រលឹងមួយរបស់ប្រជាជនយើងទៀតផង ។ នោះគឺ មាតាធិបតេយ្យ ។ ប្រាង្គប្រាសាទខ្លះ នៅតំបន់អង្គរ ទំនងជាបានយកព្រលឹងមាតាធិបតេយ្យនេះមកភ្ជាប់ជាប្រពៃណី ដើម្បីកំណត់នាមរបស់ប្រាសាទនោះ ឧទាហរណ៍ ប្រាសាទមេបុណ្យខាងកើត ប្រាសាទមេបុណ្យខាងលិច ។ ដោយឡែកនៅលើទស្សនៈប្រហាក់ប្រហែលគ្នានេះ យើងក៏សង្កេតឃើញប្រាសាទមួយចំនួនទៀតយកពាក្យ "តា" ទៅដាក់ពីមុខ ដូចជាប្រាសាទតាព្រហ្ម ប្រាសាទតាកែវ " ឬព្រះកែវ " ប្រាសាទតាសោម ប្រាសាទ តានេះ ប្រាសាទតាម៉ឺន ប្រាសាទតាសែន " ឬតាសិទ្ធិ " ... ។ ដោយទំនងជាភ្ជាប់ទៅលើទស្សនៈ នេះហើយ ក្នុងសម័យដ៏យូរលង់ ទី ៧ ប្រាសាទតូចៗ មួយ ចំនួន បានកសាងឡើងសំរាប់ឧទ្ទិសដល់ម្ដាយ ឪពុក ជីដូន ជីតា ។ សិលាចារឹកបានប្រាប់សេចក្ដីពិតដូចពោលខាងលើនេះក៏ពិតមែនហើយ ប៉ុន្តែសំណង់ទាំងឡាយនេះ ពិតជាបង្ហាញប្រាប់ស្ថាបត្យកម្មមួយប្រកបដោយគុណតម្លៃ បច្ចេកទេស និងពុទ្ធិសោភ័ណ្ឌរបស់វិលសតវត្ស ដែលពិតជា មានតម្លៃមួយជាផ្លូវទៅសំរាប់សិល្បៈដែលក្នុងនោះ បញ្ជាក់បានពីសេចក្ដីទុក្ខសោករបស់កូនចៅ ការគោរពត្រិ និងលើកតម្កើង ដែលជាពន្លាជីវិត




មគ្គុបង្ហាញ : ឥណ្ឌាភាវូបនីយកម្ម តំបន់អាស៊ីអាគ្នេយ៍ និងប្រទេសកម្ពុជា។

របស់មនុស្សពិតៗ ។

១.២.៤ - តើពាក្យកម្ពុជាចេញមកអំពីណា ?

អតីតអ្នកសិក្សាស្រាវជ្រាវជាច្រើនបានអោយតម្លៃទៅលើ រឿងព្រេងមួយផ្នែក ។ រឿងខ្លះទាក់ទង ទៅនឹងព្រះថោងដែលទំនងជាជាតិឥណ្ឌា ដែលត្រូវបានបណ្តេញចេញអំពីស្រុក ហើយបានរកភព្រសពជាមួយស្ត្រីនាគ ។ នាគជាឪពុកបានផឹកទឹកសមុទ្រនោះដើម្បីបង្កើតបានជាប្រទេសមួយមានឈ្មោះថា កម្ពុជា ជាចក្រភពថ្មី ហើយនឹងបានសាងនីក្រុងមួយនៅទីនោះ ។ រឿងខ្លះទាក់ទងដល់ព្រាហ្មណ៍ កៅឌិន្យ ដែលបានរៀបអាពាហ៍ពិពាហ៍ នាងនាគឈ្មោះ សោមា ។ តាមរយៈការនិទានកៅឌិន្យ បានចោលស្នរបស់គាត់ ដើម្បីកំណត់ទីតាំងរបស់រាជធានី នៅកន្លែងណាដែលចុងស្នបានធ្លាក់ដោតទៅក្នុងដី សំរាប់យកធ្វើជាទីតាំង ហើយនឹងរៀប អាពាហ៍ពិពាហ៍ ។ រឿងព្រេងមួយទៀតរបស់ប្រពៃណីក្នុងស្រុក ទាក់ទងទៅនឹង ឥសី កម្ពុ ស្វយម្ភូវ និងនាងទេវីមេរ៉ា ។ ប្រពៃណីនេះលេចឡើងក្នុងពាក្យ កម្ពុជា "ប្រែមកជាកូនរបស់កម្ពុ" ។ ប្រជាជនកម្ពុជា គឺចេញពីពាក្យនេះឯងហើយ ។[៨] ក្នុងភាគខាងដើម នៃ គ.ស គេស្គាល់ កម្ពុជាដោយវាក្យសព្ទ " ហ្វូណន " ឬ " ជាផ្នំ " ឬ " នគរភ្នំ " នេះឯង ។

តាមភូមិសាស្ត្រជាក់ស្តែង យើងរកឃើញផ្លូវស្ពានក្នុងភ្នំទាក់ទ្រាំងក្នុងស្រុកកោះអណ្តែត របស់ខេត្តជាត់ជីបង ហើយនៅទីនោះ ភស្តុតាងជាក់ស្តែងនៃវប្បធម៌របស់ខ្មែរ ទើបយើងអាចសិលាបានកំណត់យ៉ាងច្បាស់លាស់ថា ខ្មែរជាម្ចាស់ស្រុក មានមូលដ្ឋានសេដ្ឋកិច្ចជាប់លាប់ ពោរពេញដោយកសិកម្ម ។ រឿងព្រេងខាងលើទំនងកើតមានតាំងពីមុនប្រវត្តិ ហើយបន្តមកដល់សម័យប្រវត្តិសាស្ត្រ ។ ក្នុងអំឡុង ៥០០០ ឆ្នាំ មុន គ.ស ប្រជាជនខ្មែរស្គាល់ទឹកដីរបស់ខ្លួនទៅហើយៗ មានវប្បធម៌របស់ខ្លួនមួយដ៏គួរកត់សំគាល់ ប៉ុន្តែយើងនៅរារែកក្នុងការកំណត់នាមថាយ៉ាង ណាៗនោះនៅឡើយ ។ យើងដឹងច្បាស់ថាពាក្យ " កម្ពុជា " លេចឡើងម្តងទៀតក្នុងសម័យចេនឡា ។

នៅក្នុងអត្ថបទសិលាចារឹកប្រាសាទ បក្សីចាំក្រុង ដែលកសាងឡើងក្នុងឆ្នាំ ៨៤៧ នៃគ្រិស្តសករាជនោះ យើងបានឃើញថា ព្រះរាជាក្នុងសម័យនោះបានអះអាងថា ស្តេចកម្ពុជាទាំងឡាយគឺជាអ្នកបន្តវង្សអំពីឥសីឈ្មោះ កម្ពុស្វ័យម្ភូវ ដែលជាខ្សែស្រឡាយរបស់ស្តេច នៅអារ្យទេស គឺប្រទេសឥណ្ឌា ។ បន្ទាប់អំពីសិលាសំណាក់របស់គាត់បានធ្វើឲ្យកាលទៅ ឥសីរូបនេះ ធ្វើឲ្យក្លាយ

(៨) ម៉ូរីសខ្លែប្ប : ប្រវត្តិប្រាសាទក្នុងក្រុមអង្គរ ។ ១៩៦៣ - ទំព័រ ៣

ផ្ទាល់ខ្លួនដើម្បីធ្វើអត្តឃាតនៅក្នុងព្រៃតាមវិធីដើរផ្សងព្រេង ។ ប៉ុន្តែអំពើនេះមិនបានសំរេចតាមបំណងរបស់គាត់ទេ ហើយជាចៃដន្យ គាត់ក៏បានមកដល់ដែនសុវណ្ណភូមិ ហើយក៏បានរៀបអាពាហ៍ពិពាហ៍ជាមួយកូនស្រីស្តេចនាគ ឈ្មោះថានាង សោមា ។

ទោះបីការបកស្រាយយ៉ាងណាៗនោះក៏ដោយចុះ ន័យរបស់ " កម្ពុជា " មិនមែនគួរសង្ស័យទេ ហើយក៏មិនអាចបញ្ចៀសតថភាពនៃព្រឹត្តិការណ៍បានដែរ ។ វប្បធម៌ខ្មែរបានរាក្រិកខ្លួន និងអនុម័តយកវប្បធម៌ស្រុកក្រៅតាមការប្រទាក់ប្រទងគ្នានៃសមាសធាតុផ្សេងៗគ្នា នៅតំបន់អាស៊ីខាងត្បូង តំបន់សមុទ្រ ប៉ាស៊ីហ្វិក ។ អារ្យធម៌របស់ជនជាតិឥណ្ឌា បានមកលាយនិងអារ្យធម៌ខ្មែរ ដែលជាម្ចាស់ស្រុក បានលេចធ្លោឡើងគួរកត់សំគាល់ក្នុងពេលដែលកើតមាន " ជំនោរនៃប្រវេសន៍ " យ៉ាងធំក្នុងយុបប្រវត្តិសម័យ [3] ។

លោក ប៉ូរីស ផ្លែហ្ស កត់សំគាល់ថា តាំងពីសម័យមុនប្រវត្តិសាស្ត្រ នោះមកម្ល៉េះ ប្រជាជនខ្មែរមានខ្សែរយៈទាក់ទងគ្នាជាមួយប្រជាជន មន ហើយនិងប្រជាជនដែលក្លាយពីសមាសធាតុ មេឡាណេស៊ីន និង ឥណ្ឌូណេស៊ី [4] ។

បណ្ឌិតឱយេអូពិក ក៏បានប្រាប់សញ្ញា អំពីដែនដីឧត្តរបស់រាជវង្ស កម្ពុ-សួយម្ភូវ ដែលជាដែនដីចេន្ទា ។ ក្នុងសតវត្សទី ៦ នៃសម័យប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា កម្ពុជាតិចេន្ទា [5] ។ ពាក្យចេន្ទានេះ នៅជាពាក្យដែលគេពន្យល់នៅឡើយ នាសតវត្សទី ១៣ ។ សារពោ របស់ ជាវតាកួន អំពីទម្លាប់របស់ប្រជាជនកម្ពុជា នាសតវត្សទី ១៣ ។

អ្នកនិពន្ធមួយចំនួនបានខិតខំរកប្រមាន្ត ដើម្បីពន្យល់ប្រភពរបស់ពាក្យ " កម្ពុជា " និងពាក្យ "ខ្មែរ" តាមការយល់ឃើញ តែរៀងៗខ្លួន ។ ការពន្យល់នេះធ្វើអោយអ្នកអានមានការពិបាកផងតាំណាស់ ។ ចំពោះរឿងនេះ យើងសូកពន្យាយជូនពាក្យ " កម្ពុជា " តាមន័យវចនប្បូលយ៉ាងស្រួលផងជាំបំផុត តាមការយកពាក្យសំស្ក្រឹតមកដាក់ជាទីសំអាង ។ តាមរយៈរឿងព្រេងខាងលើយើងបានស្គាល់ឈ្មោះ ឥសី កម្ពុដែលបានផ្តល់កំណើតអោយកម្ពុជា ។ យើងលើកយកពាក្យ កម្ពុ ហើយ និង ជៈ " បច្ច័យ " សំរាប់ធ្វើការពន្យល់ " កម្ពុ + ជៈ ( Kambu + ja ) = កម្ពុជ ។ ក្នុងភាសាសំស្ក្រឹត ជៈជានាមសំរាប់ធ្វើជាសព្ទដែលបញ្ជាក់ន័យ ថា " កើតចេញអំពី ... ឬ បង្កើតដោយ ... ។ ដូច្នេះកម្ពុជាមានន័យថា " កើតចេញអំពី កម្ពុ " ។ វចនានុក្រមសំស្ក្រឹតកំណត់ថា កម្ពុ ជានាមសំគាល់ភេទ ប្រុស ង

---

( ៣ ) [illegible] : [illegible] - ១៩៦៩ . [illegible]
( ៤ ) ប៉ូរីស ផ្លែហ្ស : [illegible] ១៩៦៣ . ទំព័រ ៥ ។
( ៥ ) ប្រវត្តិ សាស្ត្រ [illegible] ។



ឥណ្ឌូចិន មុនប្រវត្តិ ហើយ និងខ្ពង់រាបស៊ុងនៅភាគខាងត្បូង សម័យទឹកកកចុងក្រោយ :
ក្នុង ពេលកំពស់ទឹកសមុទ្រនៅក្រោម កំរិត - ៥០ ម៉ែត្រ ប្រមាណ - ១០០.០០០ ឆ្នាំមុន គ.ស.

កម្ពុជាជានាមសំរាប់សំគាល់ប្រជាជនកម្ពុជាផង ហើយនិងសំរាប់សំគាល់ប្រទេសមួយដែលប្រជាជននោះរស់នៅផង។ ដោយយោលទៅលើទស្សនះសង្គមរបស់អាឡុធពីអ្នស្រូវ ណោហ្សរ៉ុត ដែលយកមាតាធិបតេយ្យជាធំនោះ វាក្យសព្ទកម្ពុជា ក៏ប្រាកដឡើងជាប់រហូតមកទល់និងបច្ចុប្បន្ននេះ ។

## ១ _ ៣ . សម័យនវសិលា [១០]

## របស់ប្រជាជនកម្ពុជា

ល្អាងស្ពានស្ថិតនៅលើកំពូលភ្នំទាក់ទ្រាំង កំពស់ ១៨០ ម ។ ល្អាងនេះជាជំរកសម័យថ្មរំលីងទី ១ ដែលស្រាវជ្រាវរកឃើញនៅក្នុងប្រទេសកម្ពុជា ។ គេធ្វើដំណើរទៅកាន់ភ្នំនេះតាមផ្លូវជើងគក្លាករ ៥ គ.ម ទៅទិសពាយ័ព្យ ។ផ្លូវជើងនេះបែកចេញអំពីផ្លូវជាតិបាត់ដំបង _ ប៉ៃលិន ត្រង់ភូមិស្ពៅ ។ ល្អាងស្ពានស្ថិតនៅក្នុងភ្នំ ថ្មកំបោរពណ៌ប្រផេះមានអាយុតាំងពីសម័យពាមិញាង " ២៤០ លានឆ្នាំ មុន " ហើយមានក្លាំងថ្មស៊ីឡិចស៊ីតរួល១ជាច្រើន។

អ្នកស្រាវជ្រាវបានធ្វើកំណាយជីសាកល្បងពីរកន្លែងនៅទីនោះ ។ កន្លែងទី ១ ហៅថា " កំណាយកណ្តាល " ។ ទីនេះយើងឃើញស្ពាកម្ម" ស្រទាប់ដី " មួយមាន ៥ ស្រទាប់មានកំពស់សរុប ១,៤០ ម. ។ ក្នុងចំណោមស្រទាប់ទាំង ៥ មានតែស្រទាប់ ៣ ប៉ុណ្ណោះដែលមានកំទេចធ្យូងអាចអោយយើងកំណត់អាយុតាមវិធីប្រើរ៉ាឌ្យូសកម្ម សេ.១៤ ។

ស្រទាប់ទាំង ៣ នេះស្ថិតនៅផ្នែកខាងលើរបស់កំណាយកណ្តាល ។ ក្នុងវិស័យបុរាណវិទ្យា ស្រទាប់ទាំង ៣ នេះ មានលក្ខណះសំគាល់ដោយឧបករណ៍ថ្មនៅលាយជាមួយនិងសំណល់កុលាលភាជន៍ជាច្រើន ។

ឧបករណ៍នេះដូចគ្នានិង ឧបករណ៍ ហូប៊ិញៀន ធ្វើអំពីថ្មមូល១នៃសិលាបូរ៉ាវ័ត្ត ដែលជាទូទៅគេដាច់បំបែកនៅលើផ្ទៃតែម្ខាង ។

គេបានឃើញមានស្លាកស្នាមរំលីងនៅលើបំណែកថ្មធ្វើមអក្តេកមួយដុំ ដែលរកឃើញនៅក្នុងស្រទាប់ពណ៌ខ្មៅ " ស្រទាប់ ទី ៤ " ហើយថ្មនេះត្រូវបានមនុស្សដាច់បំបែកវាអំពីវត្ថុដែលរលីងស្រាប់ ។ ការរំលីងថ្មនេះទំនងជាមនុស្សបានស្គាល់រួចទៅហើយ នៅសម័យកកើតស្រទាប់ខ្មៅ ប៉ុន្តែការពិតមនុស្សនៃល្អាងស្ពាននេះមិនបានអនុវត្តការរំលីងថ្មទេ ។

---

(១០) នវសិលា : គិតចាប់តាំងពី ១០០០០ ឆ្នាំមុន គ.ស មកដល់ ២៥០០ ឆ្នាំមុន គ.ស. ។

សូមអានទំព័រ ២




តំនូសបង្ហាញ ស្តរាកឬល្អាងស្ពាន ។ ស្រទាប់ទី ១ : ដីពណ៌ក្រហម ។ ស្រទាប់ទី ២ : ដីពណ៌ក្រហមរឹង ។ស្រទាប់ ទី ៣ : ដីពណ៌ក្រហមស្រួយ ។ ស្រទាប់ទី ៤ : ដីពណ៌ខ្មៅ ។ ស្រទាប់ទី ៥ : ដី កកដុំៗ ។ស្រទាប់ទី ៦ : ដីពណ៌ដីឡេង ។

ក្នុងស្រទាប់ដីដែលមានអាយុច្រើន គេមិនបានប្រទះឃើញឧបករណ៍ធំៗទេ ប៉ុន្តែគេឃើញមានបំណែកថ្មស៊ីឡិចស៊ិតជាច្រើន នៅលាយឡំជាមួយបំណែកថ្មបរិវត្ត ហើយនិងដុំថ្មភក់ក្រហមបែកបាក់ ។

កុលាលភាជន៍លំអដោយក្បាច់រចនាច្រើនបែបណាស់តែក្នុងចំណោមនោះ ក្បាច់រចនាជាទម្លាប់ដែលមានស្នាមដូចញួរតូចៗ ប្រកាន់នាទីច្រើនជាងគេ ។ កុលាលភាជន៍មានច្រើននៅក្នុងស្រទាប់ទាំងឡាយខាងលើ ហើយកាន់តែមានតិចទៅៗនៅស្រទាប់ក្រោម ប៉ុន្តែក៏នៅមាននៅឡើយក្នុងស្រទាប់ដីខ្មៅដែរ ។ នៅពីក្រោមស្រទាប់ដីខ្មៅមានក្រមរថ្មផុះរឹងខ្លាំងដោយកន្លែងៗ ហើយកំទេចកុលាលភាជន៍ជាច្រើនស្ថិតនៅពីក្រោមក្រមរនេះ ។ គេសន្និដ្ឋានថា មនុស្សមិនបាន នាំយកកំទេចកុលាលភាជន៍ទាំងនេះមកកាន់ទីនេះ នាពេលខាងក្រោយសម័យកើតស្រទាប់ដីនេះទេ ។

កំណាយដីមួយទៀត ធ្វើនៅកាត់ផ្លូវចូលទៅក្នុងល្អាង ។ ទីនេះមានស្រទាប់ដី ៣ ស្រទាប់ ។ ស្រទាប់ពណ៌ក្រហម - ក មានអាយុ ៨៣០ គ.ស . ។ ស្រទាប់ពណ៌ ក្រហម - ខ មានអាយុ ៥០០ ឆ្នាំ មុនគ.ស . ។ ស្រទាប់ ក្រហម - គ មានអាយុ ២០២០ ឆ្នាំ មុន គ.ស. ។

ស្រទាប់ដីពណ៌ក្រហមខាងលើ " ស្រទាប់ទី ១ " របស់កំណាយកណ្ដាលមានអាយុ ៧៥០ ឆ្នាំ គ.ស.។ ស្រទាប់ដីពណ៌ក្រហមស្រួយ " ស្រទាប់ទី ៣ " មានអាយុ ២០៥០ ឆ្នាំមុនគ.ស.។ ស្រទាប់ដីពណ៌ខ្មៅ " ស្រទាប់ទី ៤ " មានអាយុ ៤២៥០ មុន គ.ស. ។ ក្នុងទីនេះហើយដែលគេរកឃើញការ ធ្វើអំពីដីដុតមួយ ។

ស្រទាប់ទាំង ៣ នៃច្រកចូលនេះ មាន ឧបករណ៍គ្រប់កន្លែង អាចប្រដូចទៅនិងឧបករណ៍នៃកំណាយកណ្ដាល ហើយអ្នកស្រាវជ្រាវចាត់ទុកដូចគ្នានិងស្រទាប់ពណ៌ក្រហមខាងលើ និងស្រទាប់ពណ៌ក្រហមស្រួយរបស់កំណាយកណ្ដាលដែរ ។

ក្រៅពីឧបករណ៍ថ្ម គេបានប្រទះឃើញឆ្អឹងរបស់សត្វរមាស សត្វតោតូចៗ ថនិកសត្វតូចៗ បក្សីទិក ខរង្គទិក មច្ឆកសត្វ មច្ឆជាតិ សំពកសិរៀសត្វ[១១] ដ៏ច្រើន ហើយមានខ្លះជាសិរៀសត្វសមុទ្រផ្សឹងសត្វកង់ -ក្ដាន់ -ប្រើស ឆ្អឹងបំសា ហរសត្វ ហើយនិងឆ្អឹងពួកការសត្វថែរទៀត ផង ។

រាករនិទិនស៊េលារបស់គ្នីក្បាលរមាសក៏មានកុលាលភាជន៍ដែរ ហើយមានអាយុ ៣៤២០ ឆ្នាំ មុន គ.ស. ។ ប៉ុន្តែ កុលាលភាជន៍ក្នុងស្រទាប់ដីខ្មៅរបស់ល្អាងស្ពានមានអាយុ ចាស់ជាងគេក្នុងការ

---

(១១) ពួកខ្យង គ្រំ

ផលិតក្អមឆ្នាំងនៅប្រទេសកម្ពុជាយើង ។

កាលបរិច្ឆេទអប្បបរិមាណចំនួន ៤២៨០ ឆ្នាំមុន គ.ស. ចំពោះការផលិតកុលាល័ភាជន៍ នៅប្រទេសកម្ពុជា នោះគឺមានចំណាស់ដ៏បង្គួរបើប្រៀបធៀបទៅនឹងកាលបរិច្ឆេទដទៃខ្លះទៀត ដែលគេស្គាល់នៅក្នុងប្រទេសជិតខាង នៅអាស៊ី អាគ្នេយ៍នេះ ។ កុលាល័ភាជន៍ដែលមានលំអស្នាមក្បូរតូចៗដូចល្អាងស្ពានដែរ នៅប្រទេស ម៉ាលេស៊ី មានអាយុត្រឹមតែ ១៥០០ មុន គ.ស និង ២៨៥០ មុន គ.ស.ប៉ុណ្ណោះ ។

ស្រទាប់ដែលនៅខាងក្រោមស្រទាប់ខ្មៅរបស់ល្អាងស្ពាន ពុំមានកុលាល័ភាជន៍ទេ តែមានឧបករណ៍ថ្មមិនដូចគ្នា ។ យើងបានកំណត់អាយុជាអតិបរិមាណត្រឹមតែភាគខាងដើម នៃសម័យ នវសិលា ឬក៏ភាគខាងចុងនៃសម័យថ្មបំបែក ចំពោះបណ្ដាស្រទាប់ផ្នែកខាងក្រោមទាំងឡាយនេះ[១២] ។

បណ្ដាកាលបរិច្ឆេទទាំងនេះ បានបង្ហាញការមកកាន់កាប់ល្អាងស្ពានជាបន្តបន្ទាប់យ៉ាងយូរណាស់ ក៏ចាប់តាំងពី ៥០០០ ឆ្នាំមុន គ.ស. រហូតមកដល់សតវត្សទី ៩ គ.ស. ប្រកបដោយវប្បធម៌ដូចគ្នា ដោយគ្មានការប្រែប្រួលធំដុំឡើយ ។ គេមិនបានឃើញមានស្លាកស្នាមនៃការប្រើប្រាស់លោហធាតុទេ ព្រោះពេលនោះ វាស្របគ្នានឹងសម័យ ជ័យវរ្ម័នទី ២ ដែលបានមកកសាងលទ្ធិទេវរាជ នាឆ្នាំ ៨០២ នៅលើខ្នងភ្នំមហេន្ទ្របព៌ត នោះឯង ។

## ១.៤. វប្បធម៌សម្ភារៈឆ្លុះបញ្ចាំងអំពីទំនាក់ទំនងជាមួយពិភពក្រៅ

ទស្សនៈម៉ាក្ស - ឡេនីននិយម បានកំណត់ជានិច្ចកាលថា រាល់បាតុភូតនិងវត្ថុក្នុងលោកសត្យានុម័ត តែងមានទំនាក់ទំនង និងឥទ្ធិពលទៅវិញទៅមករវាងគ្នានឹងគ្នា ។ ពិភពលោក មួយ ឬអារ្យធម៌មួយដែលនៅដាច់តែឯង ពិតជារីកចំរើនតែមួយរយៈ ហើយអាចនឹងស្លាប់ទៅវិញផង ក៏សឹងមាន ។ ប្រវត្តិសិល្បៈនៅក្នុងកោះក្រែតមុនសម័យអារ្យធម៌ក្រិករីកចំរើនក្នុងសមុទ្រ មេឌីទែរ៉ាណេខាងកើតបានបង្ហាញភស្តុតាងស្រាប់ ។ សិល្បៈ មីសែន ទទួលឥទ្ធិពលអំពីក្រែត រួចហើយរីកចំរើនយ៉ាងឆាប់រហ័ស បន្ទាប់មកក្លាយសិល្បៈក្រែតទាំងមូល មុននឹងរលត់ទៅវិញ ។

ឥទ្ធិពលនៃសិល្បៈពហុជាតិអាចបន្ថែមទម្ងន់ទៅលើទុនជាតិ នៃសិល្បៈមួយ ដើម្បីឈានទៅរករូបភាពជាតិដ៏សម្បូរបែបក្នុងវិស័យសិល្បៈ ។ វាជាការពិតណាស់ទៅហើយ បណ្ដាបច្ចេកទេស

---

(១២) ចន្ទរៈឆ្នាំ ១០.៣៣០ និង ៦០០០ មុនគ្រិស្តសករាជ

ស្ថាបត្យកម្មនៃសម័យមុនអង្គររុងរឿង ក៏បានទទួលជំរុញបច្ចេកទេសក្នុងសំណង់ថ្ម និងឥដ្ឋ នាសម័យមុនប្រវត្តិសាស្ត្រនៃអារ្យធម៌នគរភ្នំដែរ ។ ចំណែកគ្រឿងរតនម័យក៏បានទទួលបច្ចេកទេសខ្លះអំពីទំនាក់ទំនងរវាងប្រទេសឥណ្ឌូណេស៊ី ម៉ាឡេស៊ី ឥណ្ឌា និងពិភពក្រិកដែរ ។ ក្នុងវិស័យបដិមាសាស្ត្រអាណាចក្រខ្មែរ ក៏បានទទួលប្រពៃណីចម្លាក់អំពីសិល្បៈក្រិកសម័យសិល្បករ លីស៊ីប " Lysippe " សិល្បៈដែលចេញអំពីពិភពខាងលិច ហើយនិងសិល្បៈឥណ្ឌាថែមទៀត ។[១៣]

នៅក្នុងប្រវត្តិសិល្បៈរបស់ខ្លួន ប្រទេសកម្ពុជាមិនបានបិទខ្ទប់នៅក្នុងពិភពលោកដាច់ដោយឡែកតែម្នាក់ឯងទេ ក៏ប៉ុន្តែតាំងពីសម័យបុរេប្រវត្តិនោះមកម្ល៉េះ ប្រជាជនកម្ពុជាមានទំនាក់ទំនងជាមួយជាតិសាសន៍ ។ន បណ្តាប្រជាជន ក្នុងចង្កោមអារ្យធម៌អូស្ត្រូណេស៊ី ហើយរហូតមកដល់សម័យមុនប្រវត្តិសាស្ត្រ វប្បធម៌សិល្បៈកម្ពុជា មានទំនាក់ទំនងជាមួយពិភពល្បីរ៉េង គ្រិច អ៊ីរ៉ង់ " ល្វីស្តង់ " ឥណ្ឌា ចិន និងវៀតណាម ។ ក្នុងឆាករយៈពហុវប្បធម៌អន្តរជាតិ កម្ពុជាបានគំរាញ់យកខ្លឹមវប្បធម៌ក្រៅស្រុក មកផ្សំបញ្ចៀជាមួយវប្បធម៌របស់អ្នកម្ចាស់ស្រុក សំរាប់ជំរុញនិម្មិតកម្មសិល្បៈដ៏ប្រពៃរបស់ខ្លួន ទាំងក្នុងវិស័យស្ថាបត្យកម្ម បដិមាសិល្បៈក៏ដូចជាវិស័យគុបកែងលំអដទៃទៀត ដូចជារតនម័យ កុលាលភាជន៍ ស្មិត និង គំនូរលើជញ្ជាំង " ប្រាសាទនាងខ្មៅ ស.វ.ទី ១០ " ។

## ១.៥. ព្រលឹងក្នុះបញ្ជាំងតាមស្នាដៃសិល្បៈ

អត្ថបទសិលាចារឹកដែលចាស់ជាងគេ " ភាគទី ៣/៤ នៃសតវត្សទី ៥ ឬ ភាគខាងដើមនៃសតវត្សទី ៦ " បានប្រាប់អត្ថិភាពរបស់ប្រាង្គប្រាសាទទាំងឡាយដែលសព្វថ្ងៃបាត់បង់អស់ទៅហើយ រីឯសិលាចារឹក អ្នកកាន់បងដែក រៀបរាប់អំពីការកសាងរូបសំណាក ។[១៤] ប្រវត្តិស្ថាបត្យកម្ម និងបដិមាសិល្បៈតាំងអំពីការកកើតឡើងរហូតដល់ភាគខាងចុងនៃសម័យអង្គរ ត្រូវបានគេសិក្សាតាមការវិវត្តន៍របស់វា ហើយនិងការប្រើប្រាស់សិលាចារឹកជាមង្គែក ។ បណ្តាប្រាង្គប្រាសាទធំៗក្នុងក្រុមប្រាសាទអង្គរ តែងមាននាមដោយឡែកតាមគ្រាកសាងយោលទៅលើ អ្វីដែលប្រជាជនបានឃើញមានការស្វែងឡើង ជាភស្តុតាងដោយដៃជន្ម ឬ ការនិយមហៅតៗគ្នាពីដូនតា ។ ប៉ុន្តែយើងអាចដឹងនាមពិតប្រាកដបាន តាមរយៈអត្ថបទរបស់សិលាចារឹកដែលកំណត់ទិសដៅច្បាស់លាស់ចំពោះតួប្រាសាទនិមួយៗ ។ ប្រាសាទប៉ុប្រូបមាននាមថា រាជេន្ទ្រភទ្រេស្វរៈ ។ បន្ទាយ

---

១៣ : [illegible] : [illegible] ប្រទេសកម្ពុជា ទំព័រ ៣២-៣៣

១៤ : [illegible]

ស្រី កសាងឡើងសំរាប់ដំកល់សិវៈលិង្គឈ្មោះ ស្រីត្រីកុរ៉ន មហេស្វរៈ ប្រាសាទភ្នំជាខែងសំរាប់ដំកល់លិង្គឈ្មោះ ស្រីយសោធរេស្វរៈ ប្រាសាទជាយ័នសំរាប់ដំកល់រូបសំណាករបស់អាណាចក្រឈ្មោះថា ពុទ្ធ - ស្តេច ។ ល ។ ឧទាហរណ៍មួយចំពោះប្រាសាទនាងខ្មៅ នៅក្នុងស្រុកបាទិ ខេត្ត តាកែវ ។ ប្រាសាទនេះមិនមែនឈ្មោះថា នាងខ្មៅទេ ប៉ុន្តែប្រជាជនបានយករូបសំណាក នាងកាឡីបាក់បែកទៅដាក់ទុកក្នុងទីនោះ ។ កាឡីប្រែមកថាខ្មៅ ។ ក្រោយមកអ្នកស្រុកក្តីបានហៅប្រាសាទនេះថា "នាងខ្មៅ" យ៉ាងនេះរហូតមក ។

អ្វីទៅដែលយើងកំណត់ថា ព្រលឹងដែលបង្កប់នៅពីក្រោយស្នាដៃសិល្បៈនោះ ?

ព្រលឹងជាពាក្យរបស់ខ្មែរ ត្រូវគ្នានិងពាក្យសំស្រ្កឹត ថាអាត្ម័ន ។ ក្នុងលទ្ធិព្រហ្មញ្ញទិយម អាត្ម័នសំគាល់ឯកធាតុពិសេសដែលបែកចេញអំពីព្រហ្ម័ន ដើម្បីបង្កើតភាវៈឯទៀត ។ ក្នុងការបង្កើតនេះ អាត្ម័នបានទៅសណ្ឋិតក្នុងរូបកាយ មនុស្ស សត្វដែលកកើតឡើងអាស្រ័យដោយការផ្សំធាតុទាំង ៤ គឺ ទឹក ដី ភ្លើង ខ្យល់ ។ ចក្រនៃជីវិតបានបង្ហាញការវិវត្តន៍របស់ជីវភូ វិកចំមិនធំធាត់ ហើយក៏ត្រូវរលត់ទៅវិញ ។ រូបរាងកាយបានរលត់ទៅវិញក៏ពិតមែន ក៏ប៉ុន្តែព្រលឹងមិនស្លាប់ទេ ។ តាមន័យព្រលឹងខាងលើនេះ យើងសាកល្បងឆ្លុះបញ្ចាំងបណ្តាសញ្ញាណទាំងឡាយដូចខាងក្រោមនៅក្នុងស្នាដៃសិល្បៈរបស់ប្រជាជន កម្ពុជា ថាតើសញ្ញាណទាំងអស់នេះ វាជាព្រលឹងមែនដែរ ឬ អ្វី ?

១ - ប្រាជ្ញាញាណ

២ - ឧស្សាហ៍ព្យាយាមក្នុងពលកម្ម

៣ - និម្មិតកម្ម " សិល្បៈ "

៤ - ទេពកោសល្យ - កោសល្យ

៥ - អំណត់

៦ - ហេតាធិបតេយ្យ

៧ - ទំនាក់ទំនង

៨ - ការបង្រួបបង្រួម

៩ - វិទ្យាសាស្ត្រ - បច្ចេកទេស

វិភាគប្រវត្តិសាស្ត្រទាំង ១៨៦០ " ១២០០ តាមឯកសារជប៉ុន " អាចឆ្លុះបញ្ចាំងបណ្តាសញ្ញាណ

ខាងលើបានដូចៗគ្នា ក៏ប៉ុន្តែយើងសូមលើកយកប្រាសាទអង្គរវត្ត និងបាយ័នដែលស្ថិត នៅក្នុងសម័យរុងរឿងដ៏កំពូលទាំងពីរមកពិចារណា អាស្រ័យដោយប្រាសាទទាំងពីរនេះជំណាងអោយគ្រប់គ្រាន់ស្ទើរ ឥតខ្ចោះ បណ្តាបទពិសោធន៍ - បច្ចេកទេស មនោគមវិជ្ជាសង្គម លោក ទស្សនសាសនា មនុស្សនិយម ហើយនិងសីលធម៌សង្គម ។

ស្ថាបត្យករ ប៉ាមទិក សិល្បករខ្មែរជំនាន់នោះបានកំណត់យក " ភ្នំមាស " ឬ " ភ្នំកណ្តាល " ជាជាលោកទស្សនៈរួមមួយសំរាប់ធ្វើជាគោលក្នុងការកសាងសំណង់ជាប្រវត្តិសាស្ត្រនេះ ។ សមាសធាតុទាំងអស់ក្នុងស្ថាបត្យកម្មរាប់តាំងពីសត្វឆ្មាំទ្វារ ផ្លូវចូល ផ្តែរទ្វារ បឿន កំពូលប្រាសាទ គូទឹកនៅជុំវិញ ក៏សុទ្ធតែនិមិត្តរូបរបស់ទស្សនវិជាជនៃមនុស្សនិយម និងជំនឿរោរស់ ខ្មែរ ។ ប្រាសាទប្រែរូប - មេបុណ្យ - តាកែវ ដែលកសាងឡើងមុនប្រាសាទអង្គរវត្ត មានកំពូល ៥ ពិតប្រាកដណាស់ ។ ប្រាសាទអង្គរវត្ត ក៏រាប់បញ្ចូលទៅក្នុងក្រុមប្រាសាទកំពូល ៥ ដែរ ថ្វីបើ្បិតតែមានប្រាសាទតូចៗ ៤ ទៀតបានបាត់បែកទៅហើយ នៅតាមជ្រុងទាំង ៤ របស់ថែវទី ២ ។ ក៏ប៉ុន្តែកំពូលទាំង ៥ របស់អង្គរវត្ត ក៏មានអត្ថន័យកំណត់ជាក់ស្តែងនៅក្នុងលោកទស្សនៈរបស់ពុទ្ធនិយមដែរ ។ ទស្សនៈនេះបានប្រាប់ថា ភ្នំព្រះមេរុ គឺជាភ្នំមាស មានកំពូលចំនួន ៥ ហើយស្ថិតនៅចំកណ្តាលទ្វីបទាំង ៤ ដែលអណ្តែតនៅក្នុងមហាសមុទ្រទី ៧ ខាងក្រៅ ខណ្ឌដោយជញ្ជាំង ចក្រវាឡដ៏ខ្ពស់ ។ ទ្វីបទាំង ៤ នោះគឺ : ទ្វីបខាងត្បូងឈ្មោះថា ជម្ពូទ្វីប ។ ទ្វីបខាងលិចឈ្មោះថា អបរគោយាន ។ ទ្វីបខាងជើងឈ្មោះថា ឧត្តរកុរុ ។ ទ្វីបខាងកើត ឈ្មោះថាបុព្វវិទេហៈ ។ ចំពោះលោកទស្សនៈព្រាហ្មនិយមវិញ អ្នកប្រាជ្ញក៏បានសំដៅទៅលើតារាគពទាំង ៥ ដែរ ។ តែបើយើងពិនិត្យទៅលើបណ្តាតារាគព ដែលស្ថិតនៅក្នុងប្រព័ន្ធរបស់ព្រះអាទិត្យដែលជាពិភពតថៈនៅក្នុងជីវិតបច្ចុប្បន្ននេះ នោះក៏យើងឃើញថា តារាគពទាំងឡាយនោះមានចំនួន ៩ ពិតប្រាកដណាស់ : ទី ១ ផ្កាយព្រះពុធ " មាកុរ " ទី ២ ផ្កាយព្រះសុក្រ " វេនុស " ទី ៣ ផែនដី " ទែរ " ទី ៤ ផ្កាយព្រះអង្គារ " ម៉ារស " ទី ៥ ផ្កាយព្រះហស្បត៍ " ស៊ុយពីទែរ " ទី ៦ ផ្កាយព្រះសៅរ៍ " សាទួន " ទី ៧ ផ្កាយអ៊ូរ៉ានុស " អ៊ុយរ៉ានុស " ទី ៨ ផ្កាយណិបទូន " ណិបទូន " និង ទី ៩ ផ្កាយព្លុយតុង " ព្លុយតុង " ។

បើផ្អែកទៅលើការសិក្សាខាងតារាវិទ្យារបស់ក្រុមហោរាសាស្ត្ររបស់ខ្មែរយើង ។ ក៏សង្កេតឃើញថា មានតារាគព ៥ ដែរ ។ តារាគពចំនួន ៧ ជាតារាគពពិតដូចជា ផ្កាយព្រះអាទិត្យ ព្រះចន្ទ

ព្រះអង្គារ ព្រះពុធ ព្រះព្រហស្បតិ៍ ព្រះសុក្រ ហើយនិងព្រះសៅរ៍ ។ ហើយតារាគព ២ ទៀត គេអោយឈ្មោះថា តារាគព មិនត្រឹមត្រូវៈ តារានោះគឺ ផ្កាយកេតុ " ពន្លឺព្រោងព្រាយ ឬ ល្អ " ហើយ និងផ្កាយឈ្មោះ រាហូ ។ យោលតាមការសិក្សាខាងលើបុព្វបុរសខ្មែរយើងមិនគ្រាន់តែចង់បង្ហាញអ្វីដែលជាគតិក្នុងលោកសម្ភារៈតែប៉ុណ្ណោះទេ ថែមទាំងបង្ហាញអ្វីដែលជាជំនឿនោះផងទៀត នៅពីក្រោយស្នាដៃសិល្បៈរបស់គាត់ ។ ប្រសិនបើទស្សនិកជនឈរនៅចំខ្សែបន្ទាត់មេឡ្យានិ៍រ ហើយមើលពីទិសខាងលិចទៅកាន់ទ្រង់ទ្រាយរូបរបស់ប្រាសាទអង្គរ នោះគេនិងឃើញថា មានកំពូល ៥ ដដែលដោយមិនចាំបាច់ទៅឈរមើលអំពីជ្រុងម្ខាងនោះឡើយ ។ តាំងពីផ្លូវចូលធំឆ្លងតួខាងលិច យើងក៏អាចឃើញគោបុរៈនៃកំផែងក្រៅ ចង្អុលប្រាប់ទ្រង់ទ្រាយរូបរបស់អង្គរវត្តនោះរួចស្រេចទៅហើយដែរ ។ ដូចនេះមុននិងទៅដល់ជាន់ទី ៣ យើងអាចយល់បានពីរជង្សរួចស្រេចទៅហើយថា អង្គរវត្ត គឺជាប្រាសាទមានកំពូល ៥ ផ្អែកតាមទស្សនៈរូបនាសម័យកាលនោះ ។

បតិចោទសួរថា ប្រសិនបើគេមើលចំពីមុខ "ដោយមិនគិតប្រាសាទជាក់បែកនៅតាមជ្រុង" គេឃើញតែកំពូល ៣ បើគេទៅឈរមើលអំពីជ្រុងក្បែរស្រះទឹក អមផ្លូវចូលធំ នោះគេនិងឃើញកំពូល ៥ ។ តើហេតុដូចម្តេចក៏យ៉ាងដូច្នេះ ?

ចំពោះ លោកទស្សនៈចាស់របស់អារ្យធម៌អាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ជំនាន់បុរាណ កំពូល ទាំង ៥ គឺនិមិត្តរូបភ្នំព្រះសុមេរុរាជដែលមានកំពូល ៥ ឬ ភ្នំសុមេរុរាជស្ថិតនៅចំកណ្តាលនៃទ្វីបទាំងបួន ខណ្ឌដោយមហាសមុទ្រទាំងប្រាំពីរ ។ កំផែងក្រៅរបស់ប្រាសាទជានិមិត្តរូបជញ្ជាំងភ្នំដ៏ខ្ពស់ ដែលខណ្ឌសមុទ្រខាងក្រៅ ។

បើឈរលើវិទ្យាសាស្ត្រជាក់ស្តែង ដែលជាពន្លិច្ចលដ្ឋាននៃរាល់សំណង់នោះ កំពូលទាំង ៥ គឺសាង សង់ឡើងតាមការកំណត់យកប្រាសាទធំកណ្តាលជាចំណុចផ្ចិតនៃខ្សែអង្កត់ទ្រូង ឯកំពូល ៤ ទៀត កសាងនៅតាមជ្រុងកែងទាំង ៤ របស់ផ្ទៃការេមួយ ។ តាមរបៀបនេះបើគេឈរមើលចំពីមុខនោះគេឃើញកំពូលត្រឹមតែ ៣ ប៉ុណ្ណោះ ដោយកំពូលពីរតាមជ្រុងខាងក្រោយត្រូវបាំងនិងកំពូលជ្រុងទាំងពីរខាងមុខ ។ប្រសិនបើគេឈរអោយខុសតែអំពីខ្សែបន្ទាត់មេឡ្យានិ៍រនោះ គេនិងឃើញកំពូល ៥ ។ ត្រង់ចំណុចនេះ ស្ថាបត្យករ និង ជាងចម្លាក់ បានគោរពចម្លាតជាសាកលរបស់សំណង់ពោលគឺ ច្បាប់សមាមាត្រ និង សមតា ។ កំពូល ៣ ក៏អាចជានិមិត្តរូបនៃទស្សនៈមួយដែររបស់



រូបថតសហការរបស់ ប.ឡូបិនៈ
Photo cooperee de
Bill Lobban

ប្រាសាទអង្គរវត្ត-មើលពីអាកាស-កសាងក្នុងស.វទី ១២
រូបនេះបង្ហាញអោយឃើញកំពូលទាំង ៥ របស់ប្រាសាទ
ជាន់ទី៣ ហើយនិងកំពូលទាំង៤ របស់ជាន់ទី២ និងជាន់ទី ៣

សម័យកាល ។ កំពូល ៣ ទំនងជាតំណាងជាតិសាសន៍ មនោគមវិជ្ជា និង រដ្ឋ ។

យើងសាកល្បងផ្ទុះបញ្ជាំងកំពូល ៣ របស់បណ្ដាប្រាសាទដែលស្ថាបត្យករ - ជាងចម្លាក់បាន កសាងឡើងមុនសម័យអង្គរវត្ត : ឧទាហរណ៍ ប្រាសាទភ្នំក្រោម ភ្នំបូក ។ តាមទស្សនៈរបស់ខ្មែរយើង ជំនាន់នោះ គេបានអោយតម្លៃទៅលើ លទ្ធិត្រៃភូមិ គឺ ជំនឿសិវៈ វិស្ណុ និង ព្រហ្ម ។ បើសិនជាយើងគិត ទៅលើតម្លៃបែបពុទ្ធនិយមវិញ ត្រៃភូមិ គឺ មានន័យស្មើនឹង លោកតេស្វរៈ ប្រាជ្ញាបារមិតា ហើយនិង តួអង្គព្រះពុទ្ធនេះឯង ។ រីឯទស្សនៈបែបវេទនិយមវិញ ក៏យើង ឃើញមានសញ្ញាណធំ ៣ សំខាន់នៅក្នុង តម្លៃពិតរបស់គម្ពីរ ឫគវេដា " ១ " គម្ពីរ យយុរវេដា " ២ " ហើយនិងគម្ពីរសាមាវេដា " ៣ " ដែរ ។ គម្ពីរ ទី ១ មានតម្លៃស្មើនឹងភ្លើង គឺសំដៅ យកដី ។ គម្ពីរ ទី ២ មានតម្លៃស្មើនឹងខ្យល់ គឺសំដៅយក ស្រទាប់ខ្យល់ ។ ឯគម្ពីរទី ៣ មានតម្លៃ ស្មើនឹងព្រះអាទិត្យ គឺសំដៅយកមេឃ ។ បើយើងពិនិត្យលើពុទ្ធ និយមប្លែងវិញ ក៏យើងឃើញ មានតម្លៃ គម្ពីរត្រៃបិដក ដែលជាគម្ពីរធំ សំដៅលើខ្លឹមសារ ៣ របស់ព្រះវិន័យ ព្រះសូត្រ ហើយ និងព្រះអភិធម្ម យ៉ាងដូច្នេះដែរ ។ យើងអាចនិយាយរបៀបនេះបាន ក៏អាស្រ័យដោយក្នុងរយៈកាលប្រវត្តិសាស្ត្រ ជាក់ស្តែងរបស់ប្រទេសជាតិ ដែលក្នុងរជ្ជកាលណា មួយរបស់អ្នកដឹកនាំរដ្ឋ ពុទ្ធសាសនា ព្រហ្មញ្ញសាសនា ហើយនិងជំនឿរបស់ប្រជាជនតែងមានជីវិត រស់នៅទន្ទឹមគ្នាជានិច្ច ។

បើយើងឈរលើទស្សនៈមនុស្ស នោះយើងអាចបកស្រាយបានពីរបែបបន្ថែមទៀត អាស្រ័យដោយប្រជាជនខ្មែរជា " មនុស្សនិយម " ពុំងប់ទៅក្នុងមនោគតិ ។ កំពូល ៥ ទំនងជាតំណាង អោយបាតដៃពលករ ដែលបញ្ចេញកំលាំងពលកម្មទាំងប្រាជ្ញា ទាំងបាតុពលកម្ម ដើម្បីបង្កើតបាន ជាសំណង់ប្បូចប៉ីមីល្ងអើត នេះ ។ ប្រជាជនជាអ្នកបង្កើតប្រវត្តិសាស្ត្រ ។[១៥]

ការបកស្រាយមួយបែបទៀត គឺ សង្កត់ទៅលើសញ្ញាណនៃព្រលឹងរបស់ប្រជាជនខ្មែរ ដែល បង្កប់នៅពីក្រោយស្នាដៃសិល្បៈរបស់ខ្លួន : នោះគឺជា និមិត្តរូបនៃ ប្រាជ្ញាញាណ - ព្យាយាមក្នុងពល កម្ម - អំណត់ - ទេពកោសល្យ និង និម្មិតកម្ម " សិល្បៈ " ។

នៅក្នុងមហាស្នាដៃសិល្បៈដទៃទៀត យើងឃើញលេចឡើងនូវសញ្ញាណព្រលឹងដទៃទៀត ដូចជាការរាប់អាន និងការប្រង្គុំបង្រួបក្នុងសង្គម តាមរយៈរូបសំណាក ហរិហរៈ ប្រាង្គប្រាសាទ ជាដើម ។ល។

---

១៥ សូមអានភាគបន្តក្រោយនៃស្នាដៃនេះ



រូបថត ប.ឡូបិន : Photo.B.Lobban

សិល្បៈសម័យព្រៃក្មេង - ចុងស.វ.ទី ៧ យកមកពីប្រាសាទអន្លែត " កំពង់ធំ " ។ បដិមាសិល្បៈដែលរក្សាបាននូវកេរិតសិល្បៈខ្ពស់ក្នុងពេលដែលប្រទេសកំពុងមានវិបត្តិនយោបាយ និងគ្រោះថ្នាក់ធម្មជាតិ ។

តើប្រាសាទបាយ័នជានិមិត្តរូបអ្វីដែរ ក្នុងសង្គមខ្មែរ ទាំងក្នុងសម័យនោះ និងក្នុងសម័យបច្ចុប្បន្ន ? យើងអាចនិយាយបានដោយឥតសង្ស័យថា ប្រាសាទបាយ័ន គឺនិមិត្តរូបនៃ " មនុស្សនិយម " របស់ខ្មែរ ។

## II . និន្នាការសិល្បៈខ្មែរ

២.១. វិស័យបដិមាសិល្បៈ : ភាគខាងដើមនៃសម័យនគរភ្នំប្រជាជនចេះរំលាយលោហធាតុសំរាប់ប្រើ ប្រាស់ក្នុងវិស័យសិល្បៈ ក៏ដូចក្នុងការបំរើជីវភាពប្រចាំថ្ងៃដែរ ។ សិល្បករចេះធ្វើចម្លាក់លើឈើ ។ ភាគខាងចុងនៃសម័យនគរភ្នំ បដិមាសិល្បៈធ្វើអំពីថ្មក៏ចាប់លេចរូបរាងឡើង ។ រាល់ ស្នាដៃសិល្បៈ បំរើខ្លឹមសារសាសនាពីរធំ : ពុទ្ធសាសនា និងព្រហ្មញ្ញសាសនា ។

២.១.១. សម័យចិនឡា " ចុងសតវត្សទី ៧ " : អាណាចក្រកម្ពុជា ស្ថិតនៅក្នុងស្ថានភាពពាក់កណ្តាល អាណាធិបតេយ្យ ។ ស្ថានភាព ស្រុកទេសបែបនេះ ជាមូលហេតុនាំអោយសិល្បៈស្រុតចុះយ៉ាងលឿនតែម្តង ។ សកម្មភាពច្នៃប្រឌិត រលត់រលី ។ ស្នាដៃសិល្បៈស្ថិតនៅលើការចម្លងតាមគំរូចាស់ៗ ប្រកបដោយ ការល្ងង់ខ្លៅ ។ អ្នកធ្វើការងារក្នុងវិស័យបដិមាសិល្បៈ មិនបានស្គាល់បច្ចេកទេស ហើយនាំអោយ មានការគប់ប្រមល់មុជមិនជ្រៅ ទៅមិនឆ្ងាយ ...

ក៏ប៉ុន្តែ ក្តីអស់សង្ឃឹមលើវិស័យនេះ មិនបានរលត់អស់ទាំងស្រុងនៅលើអាណាចក្រកម្ពុជាទេ មជ្ឈមណ្ឌលសិល្បៈខ្លះនៃអតីតចិនឡា ក៏បានរក្សាទុកព្រលឹងសិល្បៈ ភាពរស់រវើកក្នុងការច្នៃប្រឌិត និងបានផលិតស្នាដៃពិត ប្រកបដោយតម្លៃសាកលរបស់ខ្លួន : រូបសំណាក " ហរិហរៈ " សម័យប្រាសាទអណ្តែត ។

២.១.២. សម័យក្លួលែន " សតវត្សទី ៨ " : សម័យនេះកើតឡើងស្របគ្នាជាមួយនិងការមកដល់នៃជ័យវរ្ម័នទី ២ ។ ស្ថានភាពប្រទេសជាតិមិនទាន់មានស្ថេរភាពនៅឡើយ ក្នុងរយៈកាលពាក់កណ្តាលសវត្សខាងដើម ។ ការខិតខំប្រឹងប្រែង ទាំងស្ពានសេដ្ឋកិច្ច ទាំងប្រមូលកម្លាំង



រូបថតសហការរបស់ ប.ឡូបិន: ប្រាសាទបាយ័ន - មើលពីអាកាស - ប្រាសាទកសាងឡើងក្នុងឆ្នាំ ១២០០ គ.ស.។

Photo coopérée de Bell Lobban



រូបថត ប.ឡុបិន
Photo B.Lpbban

ពុទ្ធរូបដែលបញ្ជាក់បានអំពីការហូរចូលរបស់ពុទ្ធសាសនាមកក្នុងប្រទេសកម្ពុជា ។ បដិមាសិល្បៈនេះបង្ហាញអោយឃើញនិន្នាការខ្លះដែលភ្ជាប់ទៅនឹងសិល្បៈរបស់ឥណ្ឌា ក្នុងសម័យជិតកាលគ្នា ។ សិល្បៈគុងស.វ.ទី ៦ ។

និងការប្រកាសឯករាជ្យជាតិ ហើយនិងការបង្កើតអ្វីដែលថ្មី ដោយឈរលើមូលដ្ឋានចាស់ ជាការងារធំបំផុត ។

សិល្បៈរចនាសាស្ត្រថ្មី ជាប់មុខព្រួញទៅរកភាពធ្ងន់ ក៏ប៉ុន្តែគេបានសង្កេតឃើញមានចម្លាក់និយមខ្លះដែរ តែតិចតួចណាស់ ។ សិល្បៈរចនាសាស្ត្រតាមគំរូនេះបានសាយភាយរហូតមកដល់សម័យរលួសនាចុងសតវត្សទី ៨ ។ សម័យកាលនេះជាសម័យប្រើប្រាស់វប្បធម៌ប្រទេសក្រៅ តួបញ្ជៀជាមួយនូវសិល្បៈជាតិដើម្បីបង្កើតទំរង់ សិល្បៈជាតិមួយ ។ អ្វីដែលជាការច្នៃប្រឌិតថ្មី បានផុសឡើងនៅចុងសម័យនេះ ហើយនិន្នាការជំរុះចោល ឥទ្ធិពលសិល្បៈបរទេស ក៏លេចរូបរាងឡើង ។

២.១.៣. សម័យកកើតទីក្រុងអង្គរ : សម័យនេះត្រូវបានគេចាត់ទុកថាជា ជោគជ័យនៃនិន្នាការទៅរកអ្វីដែលរឹងថ្លល់ : សិល្បករចូលចិត្តឆ្លាក់រូបធំៗច្រើនជាងទំរង់ជីវិតធម្មតា ។ បដិមាសិល្បៈមានទ្រង់ទ្រាយធំៗ ដោយសិល្បករពុំបានផ្ដល់អ្វីដែលជាជីវិតនៅក្នុងរូបសំណាករបស់ខ្លួន គេខិតខំធ្វើយ៉ាងណាអោយរូបបដិមាមានទម្ងន់ខាងភាពគ្រអាញច្រើនជាងការធ្វើអោយមានសារីរធ្មេទនសាស្ត្ររបស់មនុស្ស ។

រីឯចរិយាសម្បត្តិ ខាងវិស័យអប់រំសង្កត់លើមនោគមវិជ្ជានៃលទ្ធិ ទេវ – រាជ ។ ប៉ុន្តែយើងអាចកំណត់បានថាសម័យនេះ ជាងទេស សិល្បករ ខិតខំពង្រីកសំណង់របស់ ខ្លួនអោយមានកិរិតលើសសម័យមុន ហើយ អោយតម្លៃទៅលើសិល្បៈស្ថាបត្យកម្ម ដែលបំរើប្រយោជន៍មនុស្សជាក់ស្ដែង[១៣] ។

២.១.៤. សម័យកោះកេរ " សតវត្សទី ១០ " : សម័យនេះ ជាសម័យបន្តនិន្នាការពិសិដ្ឋ ។ រូបបដិមានៅតែមានទ្រង់ទ្រាយធំៗ ចូលចិត្តតុបតែងលំអដោយគ្រឿងអលង្ការ ក៏ប៉ុន្តែគេសង្កេតឃើញសិល្បៈករបង្ហាញចំណង់ថ្មីមួយ ដែលពុំទាន់ដែលមាននៅក្នុងបដិមាសិល្បៈនៅឡើយ : ចំណង់ថ្មីនោះ គឺចលនា ។ សិល្បៈផលៈនេះ គឺពិសេសបំផុតនៅក្នុងបដិមាសិល្បៈរបស់ខ្មែរ : ចំបាប់ពាលី និង សុគ្រីព គ្រុឌ គូអង្គពីរចំបាប់គ្នា... ភាគខាងចុងនៃសតវត្សទី ១០ នេះ គេសង្កេត ឃើញមានការវិលត្រឡប់ទៅរករូបបន្ថចាស់ៗមកអនុវត្តនៅក្នុងសិល្បៈវិញ ។ គេបានខ្ចីរូបបន្ថសតវត្សទី ៧ ទី ៨

---

១៣ គេបានរកឃើញរូបសមួយកប់នៅប្រាសាទក្នុងខេត្ត : ភិមែល : ដើម្បីរលត់អង្គរនោយភាន់តែម្ដាស់



រូបថត ប.ឡូបិន : ហរិហរៈ ប្រាសាទអណ្ដែត រចនាបថព្រៃក្មេង ។ បដិមាសិល្បៈដែលអាច
Photo .B.Lobban ចាត់ទុកក្នុងកំរិតសិល្បៈខ្ពស់ នៃសាកលលោក ក្នុងវិស័យចម្លាក់ ។



រូបថត ប.ឡូបិន : បដិមាសិល្បៈសម័យបាខែង _ចុងស.វទី៩ _បដិមាសង្កត់ធ្ងន់លើទំហំធំ ។
Photo . B . Lobban ខោ ឬ សំពត់ បង្ហាញអោយឃើញការនិយមសំពត់ចាប់ផ្នត់ ។

និងសមាសធាតុសិល្បៈ របស់អ្នកស្រុកកោះថ្វា : ប្រាសាទបន្ទាយស្រី ដែលគសាង នៅក្នុងទីក្រុងឈ្មោះ ឥស្វរបុរៈ។

២.១.៥. សម័យបាពួន " សតវត្សទី ១១ " : សម័យនេះបានបន្តពីបន្ទាយស្រី ។ ក៏ប៉ុន្តែ ក្នុងបដិមាសិល្បៈ សកម្មភាពច្នៃប្រឌិតរបស់សិល្បករ បានបាញ់មុខព្រួញទៅកាន់ ការស្រាវជ្រាវរកសោភ័ណភាពហើយនិងភាពទ្រទ្រង់ពិសេសទៅលើតួអង្គស្ត្រីភេទ។ គេតែងសង្កេតឃើញសិល្បករខ្មែរ តែងពុំសូវគិតដល់ ការធ្លាក់ជើងរបស់តួអង្គទេ ច្រើនតែយកចិត្តទុកដាក់ទៅលើតែ រង្វង់មុខ ហើយនិងដៃ ប៉ុន្តែនៅសម័យបាពួននេះ យើងឃើញមានការចាប់ភ្ជិតច្រើនទៅលើការធ្លាក់ជើងរបស់រូបសំណាក។

២.១.៦. សម័យអង្គរវត្ត " សតវត្សទី ១២ " : បដិមាសិល្បៈ អោយតម្លៃទៅលើការតុបតែង ច្រើនជាងធម្មជាតិនិយម ហើយវិលត្រឡប់មករកភាពរឹង "គ្មានចលនា" ។ សិល្បករ ចូលចិត្តលំអរូបបដិមាដោយអលង្ការ និងក្បាំងសក់ ដោយក្បាច់យ៉ាងប៉ិនប្រសប់ ។ ស្នាដៃសិល្បៈគ្រុះបញ្ចាំងអោយឃើញគុណភាព ហើយនិងនិន្នាការរបស់បដិមាសិល្បៈ នៃរចនាបថ អង្គរវត្ត : រូបហើលធំពីមុខ ហើយរឹង បន្ថយទំហំរូប ប៉ិនប្រសប់ក្នុងការ ឆ្លាក់ ។

២.១.៧. សម័យបាយ័ន " សតវត្សទី ១៣ " : សម័យនេះប្រាប់ការប្រែប្រួលថ្មីមួយទាំង ស្រុង ។ ស្ថិតនៅក្នុងទស្សនៈពុទ្ធសាសនា បដិមាសិល្បៈគ្មានគ្រឿងតុបតែងលំអទេ ហើយសង្កត់ធ្ងន់លើសម្រស់មុខ ដោយបិទភ្នែក និង បបូរមាត់ញញឹម ហើយនិងកាយ វិការ ។ សិល្បៈសម័យជ័យវរ្ម័នទី ៧ ឆ្លុះបញ្ចាំងអោយឃើញនិន្នាការថ្មីមួយទៀត គឺការ ស្រាវជ្រាវទំរង់មុខពិត ។ បដិមាសិល្បៈ ធ្វើឡើងមិនធំណាះមុខ ហើយរូបភាពត្រូវ បានគេឆ្លាក់អោយស្ថិតនៅក្នុងបនោសញ្ចេតនាផ្សេងៗ ។ ធន្ធះនេះបាននាំអោយទៅ រកការស្រាវជ្រាវសត្ថភាពខាងសរីរវិទ្យទនភាព ដែលសិល្បករខ្មែរ មិនធ្លាប់បាន អនុវត្តតាំងពីល្បងយាយណាស់មកហើយ ។

២.១.៨. ចុងសម័យសតវត្សទី ១៣ : និន្នាការសិល្បៈថ្មីមួយទៀតបានកើតឡើង ហើយបាន ផ្លាស់ប្តូរសិល្បារម្មណ៍សាស្ត្រ របស់សិល្បៈសម័យជ័យវរ្ម័នទី ៧ អោយទៅរកសំណង់



រូបថត ប.ឡុបិន
Photo . B Lobban

ចម្លាក់សម័យកោះកេរពាក់កណ្ដាលស.វ.ទី ១០ សម័យនេះសិល្បករខិតខំរកការបានផលនាក្នុងបដិភាសិល្បៈដែលពុំទាន់ដែលមានក្នុងសម័យមុន ។ សម័យនេះសិល្បៈករបន្តអោយតម្លៃទៅលើភាព ស្ដីបន្ថែក្នុងចម្លាក់របស់ខ្លួន ។



រូបថត ប.ឡូបិន
Photo B.Lobban

សិល្បៈសម័យកោះកែរ - ពាក់កណ្តាល ស.វ.ទី ១០ ។ ក្នុងបដិមាសិល្បៈនេះសិល្បករបង្ហាញការច្នៃប្រឌិត ដើម្បីធ្វើអោយស្នាដៃមានទៅរកភាពមានចលនាផ្ទុយគ្នានឹង សិល្បៈសម័យមុនៗ ។



រូបថត ប.ឡូប៊ិន
Photo. B . Lobban

សិល្បៈសម័យបន្ទាយស្រី ស.វ.ទី ១០ ។ នេះជាព្រះកេស ព្រះសិរៈដែល បង្ហាញអោយឃើញ ការយកចិត្តទុកដាក់ទៅលើសំរស់ផ្ទៃមុខ ដែលបន្ត អំពីសម័យ បាពួន ។



រូបថត ប.ឡូប៊ិន
Photo . B . Lobban

សិល្បៈសម័យបាពួន ស.វ.ទី ១១ . បដិមាសិល្បៈខាងសិតលោហធាតុ ធ្វើជារូបធំៗ ឡើងដល់កំរិតខ្ពស់បំផុត ។ នេះជារូបវិស្ណុសាងអំពីសំរិទ្ធ ហើយនិងស្អាតស្អាមបង្ហាញអោយដឹងថា បដិមានេះលំអដោយត្បូងមានតម្លៃ ។

កសាងទៀងអំពី ត្រៀងឈើ ដែលអាចលើកល្វែងធំៗបានងាយស្រួលក្នុងការទទួលពន្លឺសាសនិកបានច្រើន ហើយនិងសង្កត់ធ្ងន់ទៅលើចម្លាក់លើឈើ ដោយលាបថ្នាំ និង ពិពរាស លើស្នាដៃសិល្បៈរបស់ខ្លួន ។ ក្បាច់ចនាខ្លះក៏មានទ្រង់ទ្រាយប្លែក អំពីសម័យចម្លាក់លើថ្ម នាសតវត្សមុនៗ ។

២.២. វិស័យស្ថាបត្យកម្ម :

ជាបនការក្នុងសិល្បៈសម័យមុនអង្គររុងរឿង ឬ ក៏មានខ្លះដែរ " តិចតួច " ក្នុងសម័យអង្គរ ចាប់តាំងពីរចនាបថជាខែងទៅ ត្រូវយកទីតាំងភ្នំធ្វើជាទីក្រុង ហើយនិងបានកសាងប្រាសាទ នៅលើខ្នងភ្នំនោះទៀតផង ។ ក្រោយមក ដោយសារកម្ពុជាតិឈប់អំណោយផលដល់ការធ្វើសេដ្ឋកិច្ច ហើយនិងការពិបាកក្នុងការរកទឹកសំរាប់ធ្វើកសិកម្ម " ទីខ្ពស់ " ដែលជាមូលហេតុនាំអោយមានការពិបាកក្នុងជីវភាពរបស់ប្រជាជន ប្រជាជនខ្មែរក៏បានសំរេចចិត្តនាំគ្នាមកតាំងទីនៅលើវាលរាបវិញ ងាយស្រួលក្នុងការធ្វើប្រព័ន្ធប្រឡាយទឹក សំរាប់ជំរុញសេដ្ឋកិច្ចសង្គម និងការរស់នៅ ក៏ប៉ុន្តែបាបនិក បានបន្តសាងសង់ប្រាសាទ អោយមានសណ្ឋានជាប្រាសាទ - ភ្នំ ជាជំនួសអោយភ្នំធម្មជាតិ ដែលគេសន្និដ្ឋានថា ជាទីពិសិដ្ឋ សំរាប់ការស្វែងរកគុណធម៌ផ្សេងៗ របស់ពួកតាបស ឫសី ។ ក្រៅអំពីសេចក្តីសន្និដ្ឋានថា ភ្នំជាទីពិសិដ្ឋ ប្រជាជនខ្មែរចាត់ទុកថា ភ្នំ គឺជាប្រភពសំរាប់ពហុផលភាព ។ គំនិតនេះ គឺជាគំនិតសាកលមៅហើយ ។ លោក ប្រូង់ប្បាត៍ បាននិយាយរឿងភ្នំនេះនៅក្នុងជំនឿរបស់ ប្រជាជនមេសូប៉ូតាមីថា " ក្នុងប្រទេសមេសូប៉ូតាមីអតីតកាល ភ្នំគឺជាទីតាំងប្រមូលផ្តុំបណ្តាសក្តានុពលអស្ចារ្យរបស់ព្រះធរណី ហើយនិងរាប់ជីវិតធម្មជាតិ ។ បើគេពិនិត្យទៅលើរូបអាទិទេព ដែលសាងអំពីដីដុត ប្រមាណ ២០០០ ឆ្នាំមុន គ.ស. នោះគេនឹងឃើញថា អាទិទេពនោះ គឺតំណាងអោយបញ្ចាក់ប្រាំងអាទិទេព តំណាងអោយព្រះធរណី ។ ខ្លួនអាទិទេពនោះងើបផុតអំពីភ្នំ ហើយក្បាលតាវល្លិផុះលូតលាស់តាមចង្កេះភ្នំ ហើយនិងផុះចេញអំពីព្រះហស្តអាទិទេពនោះ ។ សត្វពពែស៊ីស្លឹករុក្ខាទាំងឡាយនោះ រីឯទឹកដែលចាំបាច់សំរាប់ជីវិតមនុស្សលោកនោះ គឺតំណាងដោយអាទិទេពពីរអង្គ ចេញអំពីចង្កេះអាទិទេពធំនោះឯង ។ ដោយសារអាទិទេពទាំងអស់នោះស្ថិតនៅក្រោមទ្រង់ទ្រាយរបស់ជីវិតធម្មជាតិនោះ មនុស្សបានគិតថា អាទិទេពទាំងនោះគ្មានសមត្ថភាពទេក្នុងរដូវក្តៅ ពីព្រោះរដូវក្តៅជាបណ្តាលអោយក្រៀមស្វិតព្រៃព្រឹក្សានៅក្នុងប្រទេសមេសូប៉ូតាមីអស់ហើយ ហើយនិងអាចធ្វើ



រូបថត ប.ឡូបិន
Photo. B. Lobban

សិល្បៈសម័យអង្គរវត្ត -ស.វ. ទី ១២ ។ បដិមាសិល្បៈបង្ហាញអោយឃើញរិទ្ធាការ ទោកេការតុបតែងលំអដោយអលង្ការយ៉ាងច្រើន ប្រហាក់ ប្រហែលគ្នានិងសម័យកោះកែរ ។



រូបថត ប. ឡូបិន — រូបសំណាករបស់ជ័យវរ្ម័នទី ៧ _ក្បូត្រធុង ក្រោយនៃសម័យកសាងសំណង់អំពីថ្ម ។

Photo .B . Lobban



រូបថត ប.ឡូបិន ផ្លាក់មើលអំពីមុខរបស់ព្រះជ័យវរ្ម័នទី ៧ ដែលជាអ្នកដឹកនាំកសាង
Photo .B . Lobban សម័យអង្គររុងរឿង ចុង ក្រោយបង្អស់នៃប្រវត្តិសិល្បៈសំណង់ធំៗអំពីថ្ម ។

អោយមនុស្ស និងសត្វស្លាប់ផងដែរ ។ ទេវកថាបានសង្កត់ធ្ងន់ទៀតថា អាទិទេព " ស្លាប់ " ឬ ត្រូវបានគេឃុំទុកនៅក្នុងភ្នំ ។ អាទិទេពបានចេញមកអំពីភ្នំនៅរដូវឆ្នាំថ្មី កាលណាធម្មជាតិបានរស់រានមានជីវិតឡើងវិញ " ។ ដូច្នេះរឿងទេវកថាដែលកើតមាននៅមេសូប៉ូតាមី គឺមានភាពប្រហាក់ប្រហែលគ្នាទៅនឹង សិវៈ និងនាង ឧម៉ា នៅក្នុងរឿងទេវកថារបស់ប្រទេសកម្ពុជាយើងក្នុងសម័យមុនអង្គរ និងអង្គររុងរឿង ។ សិវៈលិង្គ គឺតំណាងអោយអានុភាពដែលមានជីជាតិរបស់សិវៈ " និមិត្តរូបពហុផលភាព " ។ ដីតំណាងដោយនាងឧម៉ា ។ សិវៈក៏ តំណាងអោយទឹកដែរ ។ ដូច្នេះទឹកបូកនិងដីកើតចេញឡើងនូវភោគផលធម្មជាតិ ។ យើងលើកឡើងអំពីនិន្នាការរួមមួយលើវិស័យស្ថាបត្យកម្មតាមរយៈរចនាបថ ពុំមែនផ្អែកលើប្រាសាទនិមួយៗនៅក្នុងរចនាបថនោះទេ ។ យើងធ្វើការសិក្សាយ៉ាងដូច្នេះ ដើម្បីមើលអោយឃើញអ្វីដែលជាសកម្មភាពច្នៃប្រឌិតក្នុងសិល្បៈ ហើយនិងបំផុសអោយឃើញ អ្វីដែលមិនធ្លាប់ដែលៗ ។ ចាប់តាំងពីរចនាបថភ្នំដា " សតវត្សទី ៦ " មកទល់រចនាបថព្រះគោ " ៨៧៥ - ៨៨៣ " គឺប្រហែល ៤០០ ឆ្នាំ ការសិក្សាសាកល្បង ក្នុងនិន្នាការ បង្កើនកំពស់ខឿនប្រាសាទ ទាំងក្នុងខឿនប្រាសាទធំ និង ប្រាសាទ - ភ្នំ ។ ក្ដីកង្វល់ក្នុងការរកសិល្បវិធីឬក៏សាស្ត្រក៏ដូចជាការកង្វល់ក្នុងការរកបច្ចេកទេស ដើម្បីធ្វើអោយប្រាសាទមាំល្អ បាននាំអោយស្ថាបនិកខ្មែរអនុម័តយកសកោសកម្មមួយសំរាប់ការកសាងខឿនប្រាសាទ ជាជាន់ ថ្នាក់ ។ ដំបូងឡើយ គេសាងខឿនទាប ទ្រប្រាសាទតែមួយនៅដាច់ៗតែឯង បន្ទាប់មកខឿនតែមួយ ទ្រប្រាសាទច្រើន ហើយសាកល្បងកសាងប្រាសាទ - ភ្នំ ជាដំបូងនៅលើវាលរាប ដែលតម្រូវអោយស្ថាបនិករិះរកធ្យោបាយសំរាប់ទប់ទល់និងការលំ ឬស្រុត អាស្រ័យដោយពុំមានគ្រឹះរឹងមាំ ដូចជាប្រាសាទដែលសង់នៅលើភ្នំ ធម្មជាតិ ។ បន្ទាប់មកជោគជ័យក្នុងសំណង់ប្រាសាទបាគង " ប្រាសាទ - ភ្នំ ដំបូង " ស្ថាបត្យករស្ថាបនិក បន្តបន្ទាប់នេះ មួយាំងសម័យអង្គររុងរឿង តាមវិធីបង្ហាំថ្ម យ៉ាក់ជាអណ្ដាតញីឈ្មោល បង្ហាំក្បាលរំឡែង ប្រើពន្ធឹមនិងដំណាប់ ប្រើបច្ចេកទេសបង្ហាំថ្ម តាមរបៀបប្រើឈើ ហើយនិងធ្យោបាយពង្រឹង ដោយប្រើឈើមានគុណភាពនៅក្នុងសាច់ថ្ម ឬ ទ្រុំ ។ល។ ប្រាសាទ-ភ្នំវិវត្តពីមានកំពូលមួយ " ប្រាសាទធំ " ទៅកំពូល ៥ និងកំពូលរាប់សិបដូចប្រាសាទ បាយ័ន " កំពូល ៥២ " ហើយនិងពីទំហំតូចទៅដល់ទំហំធំលាតលើផ្ទៃដីរាប់ហិកតា " អង្គរវត្ត " តាំងពីប្លង់សាមញ្ញ "បាគង" ទៅដល់ប្លង់ស្មុគ្រស្មាញ " អង្គរវត្ត - បាយ័ន " ។ ខ្សែតំនូសនៃការវិវត្តន៍នេះ បង្ហាញអោយដឹងថា



រូបថត ប.ឡូបិន
Photo B.Lobban

ពុទ្ធបដិមា កសាងអំពីសំរិទ្ធ ស.វ. ទី ១៦ ។ សិល្បករសម័យនេះ
ខិតខំស្មិតស្មូបអោយមានទំហំ ធំៗ ដែលបន្តពី ស.វ. ទី ១១ ។
រូបនេះបញ្ជាក់អំពីទំនាក់ទំនងជាមួយសិល្បៈថៃ - ឡាវ ។



រូបថត ប. ឡូប៊ិន
Photo.B.Lobban

ចម្លាក់ទេពប្រណម្យ កសាងអំពីឈើ ស.វ.ទី ១៥ - ១៦ ។ នេះជាសម័យមាននិន្នាការប្រើប្រាស់ឈើជាជំនួសថ្មដែលពេញនិយមក្នុងសម័យមុន។ រូបនេះបង្ហាញទំនាក់ទំនងខ្លះ ជាមួយសិល្បៈថៃ ។



វិធីភ្ជាប់ថ្មតាមរបៀបប្រើកន្ទើត និងឈក : ប្រាសាទតូចៗ
នៅតាមខឿនរបស់ប្រាសាទ ភ្នំបាខែង ~ ស.វ.ទី ១០ ។

សិល្បករ ស្ថាបត្យករ ឋាបនិក អ្នកច្រៃចំលាក់ និង ពលករខ្មែរ មានគំនិតច្នៃប្រឌិតឥតប្រកែកបាន ឡើយ ។ ប៉ុន្តែនៅពីក្រោយសកម្មភាពនេះ ប្រជាជនខ្មែរបានរក្សាទុកខ្លឹមសារមួយ ដែលមានតាំង ពីរធរាបផ្ទុំជា រហូតមកដល់សម័យបាយ័ន : នោះគឺលោកទស្សនៈបុរាណ នៃអារ្យធម៌ អូស្រូ ណេហ្ស៊ីត " ភ្នំព្រះមេរុរាជ " ដែលជាទស្សនៈមាននៅអាស៊ីខាងត្បូង – អាស៊ីអាគ្នេយ៍ អ្នកស្រុកកោះជ្វា កោះសៃឡែប និង អាស៊ីកណ្តាល ។

| |
|---|
| សិល្បៈគឺជាសកម្មភាពច្នៃប្រឌិត ។ អ្វីដដែលៗ អ្វីដែល គ្រោតគ្រាត អ្វីដែលចម្លង មិនមែនជាសិល្បៈខ្មែរទេ ។ |

២.៣. ប្លង់សំខាន់ពីរក្នុងសំណង់ប្រាសាទ .

២.៣.១. ប្លង់យកខ្សែបញ្ឈរ៍ជាមេ – ប្រាសាទព្រះវិហារ ប្រាសាទកោះកែរ ជាប្រាសាទ តំរូ ។ គេយកប្រាសាទធំ " ពុះចំកណ្តាលខ្លោងទ្វារមុខ ឬ យកកំពូលប្រាសាទធំ " ដែលសង់ចំខ្សែបញ្ឈរ៍ ជាមេសំណង់ដទៃទៀត ស្រះទឹក ត្រូវសង់នៅសង្ខាង ខ្សែបន្ទាត់បញ្ឈរ៍នេះ ។

២.៣.២. ប្លង់យកប្រាសាទធំកណ្តាលជាមេ– ប្រាសាទដែលសង់តាមប្លង់នេះ មានកំផែង ច្រើន ហើយមានប្រាសាទតូចៗច្រើនទៀតសង់នៅជុំវិញប្រាសាទធំ ។ គូទឹកធំ ឬតូច ព័ទ្ធនៅពីក្រៅ ។

ឋាបនិកប្រើប្រាស់របៀបទាំងពីរខាងលើ យោលទៅតាមស្ថានភាពភូមិ សាស្ត្រ ។ ប្លង់យកខ្សែបញ្ឈរ៍ជាមេ ច្រើនអនុវត្តនៅលើទីទួល ឬភ្នំដែលអនុញ្ញាត អោយគេសង់ជណ្តើរច្រើនកាំនិងព្រលានទៅតាមស្ថានភាពទីដីភ្នំ ដោយចំណង់ចិត្ត ។ គេក៏បានអនុវត្តប្លង់យកខ្សែបញ្ឈរ៍ជាមេនេះនៅលើដីរាបដែរ ដូចជាប្រាសាទ នៅកោះកែរ " ស.វ. ទី ១០ គ.ស. " ជាដើម ។

ឋាបនិកច្រើនអនុវត្តប្លង់យកប្រាសាទធំជាមេនៅលើទីដីរាបស្មើ ដែល អនុញ្ញាតអោយជាងសំណង់ អាចរៀបចំ សាលរវែងៗ ដៃ មណ្ឌបម័យ និង កំផែងបាន



វិធីភ្ជាប់ មេទ្វារ - មេបង្អួច ក្នុងសំណង់ថ្ម
សម័យអង្គរ




វិធីភ្ជាប់ថ្មតាមផ្ទៃផ្ដេក : ក. ប្រាសាទបាគង : ស.វ.ទី ៩
ខ. ប្រាសាទប្រែរូប : ស.វ.ទី ១០
គ. ប្រាសាទបាពួន : ស.វ.ទី ១១

ច្រើនហើយធំៗ នៅជុំវិញប្រាសាទធំ ពិសេសគឺ សំរាប់ការកសាងប្រាសាទ - ភ្នំ ដូច ជា ប្រាសាទបាគង ប្រែរូប តាកែវ " លើកលែង ប្រាសាទធំនៅកោះកែរ " ។

២.៣.៣. ប្លង់បញ្ចូលគ្នា "ប្លង់ ២.៣.១. ឬកប្លង់ ២.៣.២." ប្លង់នេះចាប់អនុវត្តពីសតវត្សទី១១ ។ មូលហេតុដែលនាំអោយស្ថាបនិកប្តូរប្លង់ទាំងពីរនេះ បញ្ចូលគ្នា គឺការចូលចិត្តពង្រីកសិល្បៈរឬពិសាស្ត្រសំរាប់ផ្លូវចូលធំទៅកាន់ប្រាសាទ : ប្រាសាទខ្នាសែនកែវ ប្រាសាទបឹងមាលា " បន្ថែមព្រលានច្រើន " ប្រាសាទអង្គរវត្ត " ផ្លូវចូលខាងលិច ប្រវែង ៥៥០ ម. " ឬ មួយសំរាប់ជាមធ្យោបាយទប់ទល់ល្បឿនទ័ពរបស់សត្រូវ ក្នុងករណីមានសង្គ្រាមវាយលុក " ច្រកតែមួយហើយត្រូវឆ្លងកាត់គូដីធំ : អង្គរវត្ត " ។ បច្ចេកទេសនេះអាចប្រៀបបានទៅនឹងស្ពាន - លើកចុះឡើងបានរបស់ សាតូធំៗ ដែលគេកសាងឡើងនៅក្នុងបច្ចិមសម័យរបស់ប្រជាជនអឺរ៉ុបដូច្នោះដែរ ។

២.៤. ការវិវត្តន៍របស់ប្រាសាទ -

២.៤.១. ការវិវត្តន៍ប្លង់ - នៅក្នុងការសិក្សាលំអិតផ្នែកបុរាណវិទ្យា បុរាណវិទូបានត្រិះរិះឃើ ការវិវត្តន៍នៃសមាសធាតុសំណង់ ពិសេស សសរបញ្ចោត ទ្វារបង្អួចមានតឹង ឬ គ្មាន ប្រហាក់ប្រហែលគ្នានឹងការវិវត្តន៍របស់ប្លង់ប្រាសាទដែរ ។ យើងបានពិចារណា បន្ថែមតាមបំនាំនេះដោយលើកយកការប្រែប្រួលតំរូប្លង់តាមសតវត្សនីមួយៗចាប់តាំងអំពី សម័យមុនអង្គររហូតកេដល់សម័យបោះបង់ចោលទីក្រុងអង្គរ។ យើងឃើញថាក្នុងរធនាបថនីមួយៗមានប្រាសាទច្រើនណាស់ ដែលជួនកាលកសាងឡើងតាមទំរង់ផ្នែប្រឌិត ថ្មី ជួលកាលរក្សាទុកតំរូចាស់ ។ ប៉ុន្តែយើងសិក្សានៅទីនេះ គឺស្រង់យកតែប្រាសាទតំរូណាមួយតូច ឬ ធំ ដែលតំណាងអោយការរកឃើញថ្មីរបស់សិល្បករ ស្ថាបត្យករ និង ឋាបនិក ។

នៅក្នុងស្ថាបត្យកម្ម មុនសម័យអង្គររុងរឿង ស្ថាបត្យករបានត្រួសត្រាយប្លង់ចំនួន ៣ ជាមូលដ្ឋាន ។ ដំបូងឡើយ សំណង់មានប្លង់ការេ បន្ទាប់មកយកប្លង់ការេ មកតភ្ជាប់ជាមួយបន្ទប់ខាងមុខដែលនាំអោយមានតំនិតប្លង់រាង ចតុកោណកែង ហើយនៅខាងចុងសម័យមុនអង្គរ គេក៏បានរកឃើញប្លង់ចតុកោណកែងផែ្លង ។ នាខាងចុងនៃសតវត្សទី ៩ " ៨៨១ " គេបានបោះបង់ចោលប្លង់ចតុកោណ

កែង ហើយយកប្លង់ការេវិញ ។ នាសតវត្សទី ១០ គេច្នៃប្រឌិតប្លង់ការេចេញតាអោយមានរាងជា ការេដោយលំអក្បាច់សារពើស្ទូត តាមជ្រុង " ប្រាសាទ បក្សីចាំក្រុង " ។ នាពាក់កណ្តាលទី ២ នៃ សតវត្សទី ១០ ស្ថាបនិកបានបង្កើតប្លង់មួយបែបទៀតក្នុងន័យបន្ថែមទំហំប្រាសាទ ម្យ៉ាងសំរាប់លំអ ផ្នែកសោភ័ណ ម្យ៉ាងទៀតជាសេចក្តីត្រូវការរបស់ប្រជាជន " ដាក់មនុស្សបានច្រើន " ។ នោះគឺ ប្លង់ការេ បន្ថែមមុខ ហើយនិងសាលវែងរាងចតុកោណកែងមួយខាងមុខហៅថា មណ្ឌប "ក្រុមកោះកេរ" ។ នៅដើមសតវត្សទី ១១ ជាងសំណង់បានវិលទៅរកប្លង់ការេ បន្ថែមមុខ ដែលជាដំរុយមួយសំរាប់អោយនិកឃើញដល់ប្លង់ កាកបាទ នាសតវត្សខាងក្រោយ " ប្រាសាទ តាកែវ " ។ ក្នុងសតវត្សដដែលនេះ គេបានច្នៃប្លង់កាកបាទបន្ថែមមុខខាងមុខ " ប្រាសាទព្រះថ្កុល " បន្ទាប់មកប្លង់កាកបាទបន្ថែមមុខ ហើយនិងសាលចតុកោណមួយពីខាងមុខ "ប្រាសាទវត្តឯកភ្នំ" ។ នាសតវត្សទី ១២ ស្ថាបនិកបានប្រឌិត ប្លង់ការេមួយមាន សារពើស្ទូត បន្ថែមមុខពីមុខហើយត ភ្ជាប់សាលចតុកោណកែងមួយទៀត " ប្រាសាទបន្ទាយសំរែ " ។ នៅខាងដើមសតវត្សទី ១៣ គេ ជ្រើសយកប្លង់កាកបាទបន្ថែមទេខ្ទប់តាមជ្រុងទាំង ៤ " រាងរុក្ខកែង " ហើយនិងសាលចតុកោណកែង " ប្រាសាទព្រះស្ទឹង : ព្រះខ័ន កំពង់ស្វាយ " ។ ក្នុងរជ្ជកាលជ័យវរ្ម័នទី ៧ ក្នុងសតវត្សទី ១៣ ដដែលប្លង់ មួយថ្មីបានប្រសូតឡើង : ប្លង់រាងមូល - ចែកជាគាំ ៨ ព័ទ្ធបន្ទប់កណ្តាលសំរាប់ដំកល់ព្រះ - ស្តេច បដិមា " ប្រាសាទបាយ័ន " ។

ប្រជាជន កម្ពុជានាសតវត្សទី ១៣ នេះបានកសាងប្រាសាទ បាយ័ននេះឡើង ដើម្បីឧទ្ទិស ចំពោះព្រះ សាសនាមហាយាន ដែលមានតួអង្គលោកិតេស្វ ព្រះនាម លោកេស្វរៈ ជាទិសក្តរៈ ។ អាស្រ័យដោយប្រាសាទនេះ តំណាងអោយព្រះពុទ្ធសាសនា យើងជាអ្នកសិក្សាក៏បានគាប់ភ្លឹកទៅ ដល់រាងប្លង់មូលរបស់ប្រាសាទធំកណ្តាលដែលបានចែកជា ៨ គាំ ដែលបង្ហាញប្រាប់អំពី អដ្ឋង្គិកមគ្គ " ផ្លូវទាំង ៨ ដើម្បីរំលត់ទុក្ខ ដែលមានចែងនៅក្នុងអរិយសច្ចៈទាំង ៤ នោះពិតប្រាកដណាស់ ។ ផ្លូវទាំង ប្រាំបីនោះគឺ ១ - សម្មាទិដ្ឋិ ២ - សម្មាសង្កប្ប ៣ - សម្មាវាចា ៤ - សម្មាកម្មន្ត ៥ - សម្មាអាជីវៈ ៦ - សម្មាវាយាមៈ ៧ - សម្មាសតិ ៨ - សម្មាសមាធិ [១៧] ។ ដូច្នេះប្រាសាទធំកណ្តាលដែលមានរាងមូលចែក ជា ៨ គាំនេះគ្មានអ្វីក្រៅពីការបង្ហាញពីធម្មចក្កប្បវត្តនសូត្រនោះទេ ។

សរុបសេចក្តីមកយើងឃើញថា ទិសដៅវិវត្តន៍នៃប្លង់ ប្រាសាទតាំងពី សតវត្សទី ៦ មកដល់សតវត្ស

---

១៧ " [illegible] " [illegible] Les éditions du Seuil [illegible] ១៩៧ [illegible] ។

ទី ១៣ មានយ៉ាងដូច្នេះ :

ការ ==> ចតុកោណកែង មុនអង្គរ ==> ការ ចតុកោណកែង " ស.វ.១១ " ==> ភាគបាទ " ស.វ.១១ " ==> ភាគបាទ + ចតុកោណកែង " ស.វ.១១ " ការ " មានសារពើស្មូត " + ចតុកោណកែង " ស.វ. ១២ " ==> ភាគបាទ + បន្ទប់ជ្រុង + ចតុកោណកែង " ស.វ.១៣ " ==>ប្លង់ប្លោ " ១៣ " ។

២.៤.២. ការវិវត្តន៍នៃសមាសធាតុសំខាន់ៗរបស់វិហារ :

- ផ្តែរទ្វារ

ការសិក្សារំពី ការវិវត្តន៍របស់ផ្តែទ្វារ ពោនសារសំខាន់ក្នុងការសិក្សាអំពីរចនាបថរបស់ប្រាសាទ ។ អ្នកសិក្សាស្រាវជ្រាវ បុរាណវិទូបានចាយទឹកខ្មៅច្រើនណាស់ ដើម្បីរកសច្ចៈភាពក្នុងការកំនត់លក្ខណៈសំគាល់របស់ផ្តែរទ្វារនៅក្នុងរចនាបថនិមួយៗ ។[18] យើងមានបំណងលើកឡើងនៅក្នុងស្នាដៃនេះ នូវគំនិតថ្លៃប្រឌិតខ្មែរ ដែលភាគខាងដើមរបស់សម័យ អង្គរបានទទួលឥទ្ធិពលបច្ចេកវិជ្ជា ហើយជាបន្តបន្ទាប់មកបានដោះបង់ចោលអ្វីដែលជាបរទេស ដើម្បីធ្វើសិល្បៈមួយអោយទៅជារបស់ខ្មែរសុទ្ធសាធ ។ យើងបានអោយសារៈសំខាន់ទៅលើផ្តែរដោយគាត់ទុកដូចជាកេតនភ័ណ្ឌជាតិ សំរាប់សំគាល់ថ្នត់ គំនិត និង អត្តភាពសង្គម ដូចជាកេតនភ័ណ្ឌជាតិនៃបច្ចុប្បន្នកាលនេះដែរ ។ ការសិក្សាលើការវិវត្តន៍នេះមិននេះ គឺ សំអាងទៅលើទស្សនៈមួយដែលលោក ឡាហ្សា ការឡូត៍ និយាយថា : " គេមិនកើតមកជាអ្នកបដិវត្តនោះទេ ក៏ប៉ុន្តែគេអាចក្លាយទៅជាជនបដិវត្ត "[20] រីឯប្រជាជនខ្មែរ ដែលបានរីកចំរើននៅក្នុងប្រវត្តិសាស្ត្រ ក៏អាស្រ័យដោយការខំប្រឹងប្រែង បង្កើនពុទ្ធិពីងលើខ្លួនឯង សន្សំបទពិសោធន៍ឆ្វេនបុរិដ្ឋាជីវៈតាមរយៈទុនក្នុងស្រុក និងទុនអំពីនាយសមុទ្រដែរ ។ ទស្សនៈនេះបានបង្ហាញភស្តុតាងជាក់ស្តែងទៅលើស្នាដៃឆ្លាក់ផ្តែរទ្វារតាំងពីសម័យសំបូរព្រៃគុករហូតមកទល់សម័យបាយ័ន ។

---

[18] សូមអានសៀវភៅ : " [illegible] " [illegible] ( Les éditions du seuil ) របស់អ្នកនិពន្ធ [illegible] ទំព័រ [illegible] បោះពុម្ពឆ្នាំ ១៩៨[illegible] ។

[19] ទស្សនាវដ្តីសិល្បៈអាស៊ី ក្បាលកិ VIII , ៤ ទំព័រ ២៩១ ... [illegible] - សិល្បៈខ្មែរ ទំព័រ ៨៣ ។ [illegible] ភាគ ១ ទំព័រ ១៩៦ ។

[20] : / [illegible] : មនុស្ស និងគំនិត - ការផ្សាយ [illegible] - ទំព័រ ៨ ។

២.៤.២.១. ក្នុងសម័យ ចិន - ឡា - :

យើងបានពិនិត្យថា ឥទ្ធិពលប្រពៃណីទេសបានជក់ជាប់នៅឡើយក្នុងទេសិការបស់ប្រជាជនខ្មែរ ។ ក្បាច់រចនានានា ទាំងរូបបដិមា ទាំងសមោសធាតុសំណង់ដទៃទៀត បានអោយដឹងអំពីទំនាក់ទំនងរវាងខ្មែរ និង ឥណ្ឌា ។ នៅលើទ្វារចូលទៅកាន់ប្រាសាទ នៅប្រទេស កម្ពុជា " ផ្តែរទ្វារ " និងនៅប្រទេសឥណ្ឌា គេបានឃើញរូបចម្លាក់សត្វមករ ប្រហាក់ប្រហែលគ្នា ។ អាស្រ័យដោយការវិវត្តន៍អំពីទស្សនៈ ខ្មែរបានច្នៃប្រឌិតត្រៀមរចនារបស់ខ្លួនដោយឡែកពោលគឺ ប្រឌិតរូបនាគ រូបគុជសិង្ហ៍ និង រឿងទេវកថា ជាជំនួសរូបមករ ហើយនឹងរំយោលទងផ្កា តាមបែបឥណ្ឌា ។ បន្តិចម្តងៗ សិល្បករខ្មែរបានឈានទៅរកភាពម្ចាស់ការនៅចុងសតវត្សទី ៧ " សម័យព្រៃក្មេង " ។ ក្នុងសម័យព្រៃក្មេង សិល្បករមានបំណងលុបបំបាត់តោរូបសត្វអំពីផ្តែរទ្វារ ហើយរំលេចតួអង្គមនុស្សអោយមានសារៈសំខាន់ឡើងនៅចុងផ្តែរទ្វារសង្ខាង ក៏ដូចនៅចំកណ្តាលផ្តែរបស់ផ្តែរទាំងអស់ ។

២.៤.២.២. នៅដើមសតវត្សទី ៨ " អាង ត.ស "

និន្នាការថ្មីមួយបានកើតឡើង ។ នោះគឺការច្នៃ ប្រឌិតទៅរករចនាបែប ផ្តែរទ្វារដោយសន្លឹក និងទងឈើទាំងស្រុង ។ នេះជាការវិលទៅរកការអោយសារៈសំខាន់ទៅគេធម្មជាតិដែលគ្រប់គ្រងអត្ថិភាពសង្គម ។

២.៤.២.៣. នៅសតវត្សទី ៩ : សម័យមកដល់របស់ជ័យវរ្ម័នទី ២ ដែលបានកសាងទីក្រុងថ្មីនៅនាទីភ្នំមហេន្ទ្របពិត ។ ក្នុងសម័យនេះ សិល្បករបានបែរមករកការប្តូរបញ្ចូលគ្នារបស់សិល្បៈជាតិ និងសិល្បៈរបស់ប្រជាជាតិក្រៅនៅអាស៊ីអាគ្នេយ៍នេះ ដើម្បីបង្កើតសិល្បៈរបស់ជាតិខ្មែរសំបូរបែប ។ គឺដែលមានតាំងអំពីរចនាបថសំបូរព្រៃគុក ព្រៃក្មេង និងកំពង់ព្រះ បានយកមកបញ្ចូលក្នុងក្បាច់រចនារបស់សម័យនេះ ។ ប៉ុន្តែគំនិតបំអង្គែកខាងលើរបស់ផ្តែរ ដោយក្បាច់ហៀនមួយជួរ ហើយនិងត្រូវគេយកផ្កាមួយជួរជាការរកឃើញថ្មីបន្ថែម ។ គំនិតធំ គឺ មនុស្សជាអ្នកធ្វើម្ចាស់លើរុក្ខជាតិ និងសត្វ ហើយនិងយក្សរាហូ ដែលតំណាងអោយ " អមតៈ " សំរាប់គ្រប់គ្រងអត្ថិភាពរបស់សង្គមខ្មែរ និងធម្មជាតិ ។

នៅក្នុងសម័យខាងដើមសតវត្សទី ៩ នេះ មគ្គុទ្ទេសក៍របស់ប្រទេសកម្ពុជា និតកំខ្លាំងណាស់ក្នុងការបំបាត់អំពីការត្រួតត្រារបស់កោះជ្វា ហើយនិងការប្រឹងប្រែងដើម្បីបង្រួបបង្រួមជាតិ បំពេញ

បណ្ណាល័យ LIBRARY BUDDHIST INSTITUTE

កម្លាំងអោយកងទ័ពជាតិ ហើយនិងការរកទិតាំងជាប់លាប់ដើម្បីធ្វើកសិកម្ម ។ ក្នុងន័យនេះឯងហើយ ទើបបានសិល្បករខ្មែរជំនាន់នោះបានបង្ហាញរូបភាពលោលខាងលើនេះ តាមរយៈក្បាច់គ្រប់កឈូក និងក្បាច់ផ្កា ព្រលិតមួយជួរខាងលើ ដើម្បីជានិមិត្តរូបរបស់កងកំលាំងទ័ព កំលាំងទ្រព្យសម្បត្តិជាតិ ហើយនិងរបស់សង្គមកសិកម្ម ។ ទោះនៅក្នុងព្រហ្មនិយម ក៏ដូចជាក្នុងពុទ្ធនិយមដែរ ផ្កាឈូកតំណាងអោយចក្រវាឡ ហើយទាំងដើម ទាំងផ្កាក៏តំណាងអោយទឹកដែរ[២១] ។ ដូច្នេះតម្លៃធម្មតារបស់ផ្កាឈូកទៅនិងនេះគឺ កសិកម្ម ទ័ព ទ្រព្យសម្បត្តិ រានធម្មជាតិជាដើមនោះ គឺស្ថិតនៅលើចក្រវាឡរបស់កម្ពុជានោះឯង ។

២.៤.២.៤. នៅក្នុងសតវត្សទី ៥ " សម័យព្រះគោ និង បាខែង " សិល្បករបានក្សាទុកគំនិតធំរបស់សម័យខ្មែរតូចមែន ។ សិល្បករពង្រីកគួរអង្គរាល " តំណាងអរុណៈ " នៅជាព្រលឹងដដែល ហើយទ្រទ្រង់សង្គមខ្មែរ និងធ្លាក់ធម្មជាតិចេញពីព្រអប់អាត់ ។ មនុស្សចាប់យកដី អកធ្វើជាអធ្យោបាយដើម្បីចំពីក្នុងជីវភាព ។ រូបនោះប្រណម្យមួយជួរទំនងជាបង្ហាញប្រាប់ការត្រេកអរ ឬស្វាគមន៍ ចំពោះជ័យនេះ ។ ត្រពកផ្កាឈូក ផ្ការមួយជួរ ឬ ពីរ ជួរខាងលើ និងខាង ក្រោមប្រាប់នូវការទ្រទ្រង់របស់កំលាំងទ័ព ហើយនិងកំលាំងសេដ្ឋកិច្ច ។

គំនិតរួមមួយក្នុងរចនាបថទាំងពីរនេះគឺធ្លាក់ក្បាច់គ្រប់កឈូកមួយជួរ ឬ ពីរជួរគឺសបញ្ជាក់អំពីកំលាំង ការការពារជាតិឯណោ ហើយក៏ប្រាប់អត្ថិភាពរបស់សង្គមដែលជាសម័យរីកលូតលាស់ខាងកសិកម្ម ដោយប្រព័ន្ធបង្ហូរទឹកនោះផងដែរ ។

២.៤.២.៥. ដើមសតវត្សទី ១០ សិល្បករបានគំនិតក្សាទុកផង បំបាត់ចោលផង ក៏ប៉ុន្តែ ក៏បានបង្កើតគំនិតថ្មីពន្លៃដោយអោយសារៈសំខាន់ទៅលើតួអង្គធំរបស់ផ្តែរ ។ សិល្បៈសម័យនេះ គឺពិតជាបានឆ្លុះបញ្ចាំងអំពីសង្គមខ្មែរដែលប្រេះឆារគ្នារវាងញាតិសន្តានខ្មែរ ។ តាមរយៈផ្តែរទ្វារសម័យកោះកែរ យើងឃើញថា គេបានក្សាទុកនូវមនោគមវិជ្ជារួមរបស់ប្រជាជនដែលស្ថិតនៅក្នុងរចនាសម្ព័ន្ធថ្នាក់លើ ។ ក៏ប៉ុន្តែ បានកាត់ផ្តាច់ចេញអំពីគ្នាយ៉ាងស្រឡះ រវាងសង្គមធម៌ក្នុងសម័យបាខែង ។ គេលុបបំបាត់ក្បាច់គ្រប់កឈូក " តំណាងទ័ព " ចេញ ។ ប្រជាជន " ទេពប្រណម្យ " មួយក្រុមបានស្វាគមន៍ចំពោះអំពើរបស់ជ័យវរ្ម័ន ទី ៤ ។ មនុស្សបាន ប្រើប្រាស់កម្លាំងសត្វដើម្បីតំរាញ់ឥលអំពីធម្មជាតិ " ដីក្បាល ៣ " ដីស្រស់បំព្រង ។ ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ

---

២១ វចនានុក្រមសំស្ក្រឹត - ជាវ៉ាធ ១៩៧២ - ទំព័រ ៩៣២



រូបលើ : ផ្តែរទ្វារប្រាសាទបាយ៉ង - ដើមសតវត្សទី ១១ បង្ហាញធម្មជាតិនិយម .



រូបក្រោម ផ្តែរទ្វារ ប្រាសាទ បាពួន - ពាក់កណ្តាល ស.វ ទី ១១ បង្ហាញមនុស្សនិយម .

ដាក់ស្នែងបានលាតត្រដាងអំពីហេតុការណ៍ដូចបានរៀបរាប់ខាងលើ ។

២.៤.២.៦. ពាក់កណ្ដាលទី ២ នៃសតវត្សទី ១០ " រចនាបថប្រែរូប និងបន្ទាយស្រី " ការបែកបាក់គ្នារវាងក្រុមគ្រួសារបានបួបត្រួមគ្នាវិញ ហើយបាននាំគ្នាកសាងទីក្រុងអង្គរ សារជាថ្មីឡើងវិញ ។ រាល់បនសិកាសង្គមនៅក្បាច់ផ្ដែលហើយការផ្សារភ្ជាប់រចនាសម្ព័ន្ធថ្នាក់ក្រោមក៏បានលេចរូបរាង សារជាថ្មីឡើងវិញទៅលើផ្ដាក់ផ្ដែរទ្វារ ។ រាល់រូបមនុស្ស សត្វ សុទ្ធតែសំដែងអោយឃើញ ការក្រេវក្រោរនិងសប្បាយរីករាយ ។ សត្វមករ សត្វនាគក្បាលច្រើន ដែលតំណាងអោយទឹកសំរាប់បរិភោគ ក៏បានប្រាកដឡើងនៅផ្ដែរទ្វារនេះដែរ ។ ព្រលឹងអមតៈ "រូបរាហូ" បានបង្កើនកាន់តែច្រើនឡើង ។ មនុស្សស្ថិតនៅជាម្ចាស់លើសត្វ និងធម្មជាតិ ។ ផ្ដែរទ្វារបន្ទាយស្រី បង្ហាញពីគំនិត "មនុស្ស" ជាម្ចាស់លើ សត្វ ទឹក និង ព្រៃភ្នំ ដ៏ធំល្វែកៗ ផងទៀត ។ កងកម្លាំងទ័ពបង្កើនកាន់តែខ្លាំងឡើង ។

២.៤.២.៧. សតវត្សទី ១១ " សម័យឃ្លាំង និង បាពួន " ជាសម័យរក្សាបន្តសាពេញ ហើយនិងអោយតម្លៃទៅលើជីវិតមនុស្ស និងសម្ផស្សរបស់ស្ត្រីភេទ ។ ផ្ដាក់លើផ្ដែរបានបង្ហាញ ការបន្ថយភ័យស្ពែកស្ពះដោយស្លឹកឈើ និងរូបមនុស្ស មកក្រវាញ្ចាំងផ្ដែរតួឆ្លាញលំអដោយសន្លឹក និងទងឈើ។ លើផ្ដែរសម័យបាពួន គេឃើញមានការយកចិត្តទុកដាក់លើមនុស្ស ស្ដីអំពីជីវិតក្នុងគ្រួសារ កលំអលើសម្ផស្សស្ត្រី ។ ទន្ទឹមនិងនោះ គេក៏សង្កេតឃើញមានការនិយមធម្មជាតិដែរ : ផ្ដាក់សត្វស្រុក ស្លឹក និងទងឈើ ហើយនិងសត្វស្លាប ។ គំនិតបង្ហាញ អំពីកម្លាំងសេដ្ឋកិច្ច និងកម្លាំងកងទ័ពនៅក្បាច់ផ្ដែល ។

២.៤.២.៨. សតវត្សទី ១២ បានបង្កើនិន្នាការ មនុស្សនិយម ដែលមានឡើងក្នុងសម័យបាពួន ។ ថ្វីត្បិតតែរឿងរ៉ាវទាំងនោះ ជារឿងរាមកេរ្តិ៍ ឬ មហាភារតៈ ក្ដីសាស្ត្រព្រហ្មញ្ញសាសនាក៏ដោយចុះ ក៏ប៉ុន្តែ វាឆ្លុះបញ្ចាំងអោយឃើញខ្សែជីវិតក្នុងសង្គម ព្រះរាម និង អតីតជាតិរបស់ព្រះពុទ្ធគោតមដែរ ។ ផ្ដែរទ្វារក៏ដូចក្បាច់ក្រឡោងទាំងនៅតាមប្រាសាទដែរ សម័យអង្គរវត្ត បានអោយតម្លៃទៅលើមនុស្ស និង រាសនាមនុស្ស មនុស្សនិងសង្គម មនុស្សនិងអាត្មាខ្លួន ។ សម័យនេះ ពីសង្គមធំ ហើយនិងវប្បធម៌មានគុណភាពនិងគ្នា ។ លើផ្ដាក់ផ្ដែរ ក៏យើងឃើញមានភាពសុខសាន្ត សេរីភាព ក្នុងជំនឿ ហើយនិងការសប្បាយក្នុងជីវភាព : ភ្លេងភ្លាត់-រាំលេងកំសាន្ត និងភោគផលក្នុងសង្គម ។

ប៉ុន្តែសិល្បៈសម័យនេះ ចូលចិត្តយកគ្រឿងរាងធម្មជាតិនិយម ។ កម្លាំងទំពត្រូវបានគេយកជាគំនិតធំ ហើយឆ្លាក់នៅផ្ទៃខាងលើរបស់ផ្តែរតែម្តង ។ ផ្តែរទ្វារប្រាសាទបឹងមាលា បង្ហាញរាល់ក្តាប់ជាប់រលកធម្មជាតិដោយច្នៃតាមក្តីប្រាថ្នា ។

២.៤.២.៩. សតវត្សទី ១៣ គឺជាសម័យរុងរឿងចុងក្រោយរបស់អារ្យធម៌សង្គម ។ ផ្តែរទ្វារសម័យនេះបង្ហាញអោយឃើញការច្នៃប្រឌិតថ្មី ស្របនិងសម័យកាលប្រវត្តិសាស្ត្រ ដែលទទួលយកពុទ្ធសាសនាមហាយានជាជំនឿរបស់ប្រទេសជាតិ ។ ក្នុងការការប្រៀបធៀបទៅនឹងសម័យអង្គរវត្ត ទ្រង់ទ្រាយផ្តែរសម័យបាយ័នប្រហាក់ប្រហែលគ្នាទៅនឹងសម័យនេះ ខុសប្លែកគ្នាតែក្បាច់រចនាប៉ុណ្ណោះ ។ ផ្តែរទ្វាររចនាបថបាយ័នក្លះបញ្ចាំងសង្គមបានតិចណាស់ មិនដូចជាក្នុងវិស័យស្ថាបត្យកម្ម និង ចម្លាក់សិល្បៈទេ ។ តែគំនិតបន្តភាពរបត់ៈតំណាងដោយរាហូនោះ[៥២] លេចឡើងកាន់តែច្រើនឡើង ។

.ជាធម្មតា វប្បធម៌របស់ប្រទេសមួយតែងមាន វប្បធម៌ពីរ : វប្បធម៌ក្នុងចង្កោមអ្នកប្រាជ្ញ និង វប្បធម៌របស់ប្រជាជន ។

ក៏ប៉ុន្តែ គំនិតមនុស្សនិយម ដែលធ្វើឲ្យស់លើកធម្មជាតិបានជ្រាតជ្រាបក្នុងសតិអារម្មណ៍ ដូចជាប្រព័ន្ធមួយ ឯតួអង្គរាហូក៏នៅតែជានិមិត្តរូបមិនចេះស្លាប់របស់ប្រជាជនខ្មែរដដែល ។ តួអង្គទាំងឡាយនៅលើផ្តែរដែលស្ថិតនៅក្នុងលោកជីវិតបានអបអរចំពោះគំនិតនេះ "ផ្តែរទ្វារព្រះខ័ន និងបន្ទាយក្តី"។ ជាទូទៅយើងបានពិនិត្យឃើញថា សិល្បករបានបង្កើត គំនិតសិល្បៈរចនាសាស្ត្រ មួយដែលមានតម្លៃ បែប អរូបិកម្ម: នោះគឺបង្កើតជាសំណាក " តំរូ " ដែលស្ថិតនៅក្នុងមូលភាពរបស់ "ភាពចំព្រួញ" ( la simplification ) នៃក្បាច់សាកលរបស់សិល្បៈ ។ ក្នុងរាល់ផ្តែរទ្វារស្ទើរតែទាំងអស់របស់រចនាបថបាយ័ន គេឃើញមានក្បាច់ផ្កាធ្វើតាមតែតំរូតែមួយ ហើយគោរពនូវភាពរបស់សមាមាត្រ និង សមតាបានយ៉ាងទៀងទាត់ផងដែរ ។

---

៥២. រាហូ [illegible]



រូបលើ : ផ្តែទ្វាររចនាបថអង្គរវត្ត - ស.វ.ទី ១២ បង្ហាញ គំនិតមនុស្សនិយម - និងសារៈសំខាន់ផ្នែកឃាថា .



រូបក្រោម : ផ្តែទ្វារប្រាសាទបន្ទាយក្តី - រចនាបថបាយ័ន - ដើមស.វ.ទី ១៣ .

# ជំពូក ២
# សារៈសំខាន់របស់ប្រាសាទខ្មែរ
## III - តម្លៃពិតរបស់ប្រាសាទ -

ទោះបីប្រាសាទខ្មែរដែលបានសង់ឡើងតាមសិល្បៈ ឬ សោភ័ណសាស្ត្រនិមិត្តរូបនិយម ដែលកាត់ផ្តាច់ សិល្បៈអំពីតថភាពនោះក៏ដោយចុះ ក៏ប៉ុន្តែ បុព្វបុរសខ្មែរ តែងមើលឃើញការទាំងគ្រប់ជានិច្ចអំពីជីវិតនៅក្នុងនិម្មិតកម្មសិល្បៈរបស់គាត់ជាដរាប ។ គាត់តែងបញ្ចូលគំនិតមនុស្សនិយមនៅពីក្រោយរាល់ទំរង់សិល្បៈ ។ តាំងពីបញ្ចប់សតវត្សខាងដើមរហូតមកទល់សតវត្សទី ១៣ ប្រាសាទខ្មែរកសាងឡើងសំរាប់តែផលប្រយោជន៍មនុស្ស និងសង្គមមនុស្សតែប៉ុណ្ណោះ ។ គំនិតនេះពិតជាជួយស្រាយបំភ្លឺអំពីសិល្បៈ ឬ សោភ័ណសាស្ត្រអនោតតិនិយម ដែលផ្តាច់សិល្បៈអំពីតថភាព ព្រោះវាមើលមិនឃើញអំពីការទាំងគ្រប់អំពីជីវិតនៅក្នុងនិម្មិតកម្មសិល្បៈសោះឡើយ ប៉ុន្តែវាជាការស្វែងឡើងអំពីប្រឌិតមនុស្ស ជាការក្លួចជ្រៅទៅក្នុងអនុមានសិការ ឬ ជាការបង្កើតឡើងនូវគោលការណ៍អនោតតិទេវនិយមសុទ្ធសាធ ។ ការលើកតម្កើងសិល្បៈអំពីតថភាព ជាគំនិតប្រឆាំងនឹងសិល្បៈ ឬ សោភ័ណសាស្ត្ររបស់ ហ្វ្រើត ដែលអះអាងថា : " សិល្បៈគឺស្មើតែស្មុគស្មាញពីស សិល្បៈគ្មានចំណងអ្វីជាមួយនឹងក្រពិតភាពស្រមើស្រមៃទេ ... សិល្បៈមិនបានខិតខំស្វែងយល់ទាល់តែសោះ ... " ផ្ទុយនឹងគំនិតខាងលើ សិល្បករខ្មែរបានធ្វើ អោយអ្នកមើលប្រាសាទរបស់ខ្មែរឃើញថា ជាការកើតឡើងអំពីពលកម្មរបស់មនុស្ស អំពីការពិតខ្មែរ ។ តាំងពីរាជជំនឿមួយដែលធ្វើអោយទេវក្លាយមកជាមនុស្ស " រាជិទេវស្តេច " នាការខាងដើមនៃសតវត្សទី ៤ " សម័យភ្នំពេញ " នោះមក ស្ថាបនិកសិល្បករបានបង្កប់តម្លៃ មនុស្សនិយមពាក់កណ្តាលទៅក្នុងគេតនកម្មជាតិ របស់អាណាចក្រដែលវាជួយស្រាយបំភ្លឺអំពីប្រាសាទនានា នៅប្រទេសកម្ពុជាដែលសំរាប់តែបូជាដល់រាជទេវតែប៉ុណ្ណោះ ។

> សិល្បៈគឺការឆ្លុះបញ្ចាំងពីឧត្តមជាតិរស់រវើកនៅជុំវិញខ្លួន ព្រោះបង្កើតដោយមនុស្សចបើជាតុត និងអាទ ម្ល ។

៣.១_ តម្លៃខាងនិមិត្តរូប _ ស្នាដៃសិល្បៈទាំងឡាយទោះនៅក្នុងបដិមាសិល្បៈ នៅក្នុងការគូបតែងលំអ ជាំ ឬ នៅក្នុងស្ថាបត្យកម្ម ។ ល ។ តែងបញ្ជាក់ប្រាប់អ្នកមើលដោយតួងតាមរយៈនិមិត្តរូបជានិច្ច ។ ចាប់តាំងពីសម័យ ចិនឡា រហូតដល់ចុងសម័យអង្គរ សិល្បករប្រើប្រាស់និមិត្តរូបស្របទិងព្រឹត្តិការណ៍សង្គមជាតិរបស់ខ្លួនជានិច្ច ។ ដូច្នេះទស្សនិកជនដែលអាចយល់បានជ្រៅជ្រះអំពីសិល្បៈរបស់ខ្មែរត្រូវស្គាល់ និងស្វែង យល់របៀបរបបរស់នៅ និងទំនៀមទំលាប់របស់សង្គមខ្មែរពុំនោះសោត គេអាចនិយាយបានថា " មើលដើរឿងមើលតែរ៉ូឡេក្រ " ។ ចរន្តសិល្បៈពីរដែលជាប្រភពនៃសិល្បៈខ្មែរបច្ចុប្បន្ន : សិល្បៈដែលគេឲ្យអំពីអដ្ឋជ្រានអ្នកចេះដឹងខ្ពស់ និងសិល្បៈរបស់ប្រជាជនសុទ្ធសាធ ។ ប្រភពទាំងពីរនេះក្ដី បញ្ជាំងពដ៍ះភាពដូចគ្នា ថ្វីត្បិតតែមានសុក្រិតភាពហើយនិងភាពគ្រោតគ្រាតផ្សេងគ្នានៅក្នុងសិល្បៈទាំងពីរនេះក៏ដោយ ។ និមិត្តរូបក្នុងសិល្បៈស្ថាបត្យកម្មក៏ដូចក្នុងជាំ និងបដិមាសិល្បៈដែរ តែងមាន ត្រួយពីរជានិច្ច ។ ត្រួយមួយបង្ហាញអំពីជីវិត ជីវិតប្រចាំធនិងធម្មជាតិ ជីវិតក្នុងធម្មជាតិ ហើយត្រួយមួយទៀតបង្ហាញប្រាប់ អនោតរវិជ្ជាប្បរបស់សម័យកាល ។

ក្នុងទស្សនៈខាងលើ ប្រជាជនគ្រប់ស្រទាប់វណ្ណៈរបស់មនុស្សជាតិ អាចមើលឃើញសិល្បៈខ្មែរ តាមរយៈតៃវត្រិសដោយឡែកពីគ្នា ។ អ្នកកាន់ជំនឿសាសនា មើលឃើញប្រាសាទបុរាណខ្មែរមានតម្លៃ និមិត្តរូប " ភ្នំមេរុ " មួយដោយឡែក ។ អ្នកប្រាជ្ញជនិយម មើលឃើញតម្លៃជីវិត និងពលកម្មមួយដោយឡែកផ្សេងទៀត ។

នៅក្នុងរាល្បូចពីរបស់សង្គមប្រជាជនដែលមានទីលំនៅជាប់លាប់ គេសង្កេតឃើញថាប្រជាជនមានគតិជឿជាក់លើខ្លួនឯងគ្រឹនជាងជឿលើពិភពក្រៅ ។ រឹងប្រព័ន្ធរាជាធិបតេយ្យអាទិទេពាបុតលភាព និង កសិកម្ម គឺតែងភ្ជាប់ទៅនឹងព្រះចន្ទ ។ ដូច្នេះហើយបានជានៅក្នុងរឿងព្រេងដែលទាក់ទងទៅនឹងសម័យនគភ្នំ ព្រះនាងសោម ឬ សោមានេះគឺតំណាងអោយខ្សែស្រឡាយខាងព្រះចន្ទ ។ អ្នកនិពន្ធឈ្មោះ តូត សាត់[២៣] បានពិនិត្យមើលឃើញហេតុការណ៍ ដូចខាងក្រោមនេះ នៅក្នុងបណ្ដារជាំ របស់សង្គមកសិកម្ម ផេរទៀត ។ ប្រជាជនដែលមានទីលំនៅជាប់លាប់គឺ ជាំរបស់ពួកគេ ជាប្រភពជាកិច្ចពិតប្រដែលសំដែងប្រាប់នូវអ្វីដែលជាចិត្ត ហើយពិនបើញរបស់មនុស្ស ។ វាជាការដាក់ស្ដែងមោស់ ហើយជាពិភពលោកផងដែរ កសិកម្មបាននាំមកនូវតម្លៃយ៉ាងខ្លាំង អំពីនិមិត្តរូបនិយម អំពីពោរពេញលភាព ហើយនិងបង្វែរអព្ទន់ទៅលើតួនាទីរបស់ស្ត្រីភេទ ហើយ

---

២៣ : ជាតិពិទ្ធសាស្ត្រ : គណក្រុម ឫស្សី ១៩៦១ - ទំព័រ ៨១

និងសារៈសំខាន់អំពើជំនឿលើទេវកថា របស់ព្រះចន្ទ ។ អ្វីដែល គួត សាក់ បាននិយាយគឺវាជាក់ស្តែង នៅក្នុងសង្គមយើងនេះតែម្តង ។ ឧទាហរណ៍ក្នុងជាំអប្សរា រជាំនេះរៀបរាប់តែអំពី ចក្រនៃជីវិតមនុស្ស និងធម្មជាតិ ក្នុងជំនឿលើ ស៊ីវៈ - ឧម៉ា គឺជាជំនឿលើពហុផលភាព ក្នុងជំនឿលើ វិស្ណុ និងព្រះព្រហ្ម គឺមានន័យថា អោយតម្លៃទៅលើ " ទឹក " ដែលជាប្រភពនៃជីវិត ក្នុងជំនឿលើព្រះអាទិត្យ ព្រះចន្ទ ព្រះអង្គារ ព្រះពុធ ព្រះរាហូ ។ ល ។ នោះ គឺជាជំនឿទៅលើសមាសធាតុទាំងឡាយដែលជាកម្លាំងធ្វើសហយោគសំរាប់បង្កើតបានជាសារីរាង្គ របស់សត្វលោកនេះឯង ។

## ៣.២. គម្ពីរសិល្បៈបំរើប្រយោជន៍

លោកទស្សនៈបុរាណដែលបានចារឹកទុកលើផ្ទាំងសិលានៅទីក្រុងអង្គរធំ បានរៀបរាប់អំពីទិដ្ឋភាពរបស់ប្រាសាទបាយ័នតាមបែបសាសនា ដែលប្រៀបធៀបកំពែងអង្គរធំ ទៅនិងជួរភ្នំដែលព័ទ្ធជុំវិញចក្រវាឡ ហើយនិងគូ ដែលព័ទ្ធពីក្រៅទីក្រុងទៅនិងមហាសមុទ្រ : " កំពូលភ្នំឡើងខ្ពស់ដល់មេឃ ដ៏ចាំងចិញ្ចែងរឹងសម្បុរ គានជំរៅរហូតទៅដល់ពិភពនាគ : ភ្នំជ័យជំនះ " ជ័យគិរី " ហើយនិងសមុទ្រជ័យជំនះ " ជ័យសិន្ធុ " ទាំងនេះបានកសាងឡើងដោយជ័យវរ្ម័ន ទី ៧ ... ។ សេចក្តីប្រៀបធៀបនេះ បានឆ្លុះបញ្ចាំងអោយឃើញគំនិតធំមួយដែលសង្គមកម្ពុជាជំនាន់នោះទទួលយកសំរាប់ជាត្រីវិស័យក្នុងរាល់ការសាងសង់វិមាននានា ។ ដូច្នេះប្រាសាទបាយ័ន ទុកដូចជាភ្នំ " ភ្នំព្រះសុមេរុ " រីឯគូព័ទ្ធជុំវិញទុកដូចជា មហាសមុទ្រ ។ ប៉ុន្តែ នោះមិនសេចក្តីរៀបរាប់ក្នុងសិលាចារឹក ដូចពោលខាងលើបានកំណត់ន័យធំរបស់ប្រាសាទបាយ័នយ៉ាងដូចនេះ ក៏ដោយ ឃ្លាខាងលើបានបង្ហាញនូវគតិភាពមួយដែលចង្អុលប្រាប់ពួកយើពីជាក់ស្តែងរបស់សង្គមខ្មែរ : នោះគឺជាការនិយមអ្វីដែលពិត រូបិយ៍ ហើយនិងការត្រិះរិះ ។ ក្នុងពាក្យជ័យគិរី និង ជ័យសិន្ធុ យើងអាចដកយកបានន័យពិតមួយ គឺជ័យវរ្ម័នទី ៧ ជាមួយនិងប្រជាជនបានព្រួតកម្លាំងគ្នា ដើម្បីចំរាញ់យកអោយផលអំពីធម្មជាតិ ដើម្បីកំណត់អត្ថិភាពសង្គមខ្មែរយ៉ាងជាក់ស្តែង ។ រូបចម្លាក់ ឃត្តូ និងទេវតាទៅទាញខ្សែនាគនេះ បញ្ជាក់នូវអត្ថន័យនេះ : ពស់នាគ និមិត្តរូបខ្សែក្រវាត់ ប្រាសាទបាយ័ន គឺភ្នំ " គំពាងធម្មជាតិ " ដែលវិលទៅក្នុងទឹកគូរបស់ទីក្រុងអង្គរធំប្រៀបបាននិងស្នាហរណ៍ដែលបញ្ចេញទឹកទៅក្នុងប្រព័ន្ធ ប្រឡាយ រត់ខ្វាត់ខ្វែងសំរាប់សំរឹតធារាសាស្ត្រ គឺដូច កំពិសេសប្រយោជន៍កសិកម្មដែរ ។ ក្រៅអំពីគូ ប្រជាជនបានកសាង



រូបថត សហការរបស់ ប.ឡូបិន : 
Photo cooperee de Bill Lobban

ប្រាសាទបាយ័ន កសាងក្នុងស.វ.ទី១៣ ពី ១២០០ .គ.ស.។ បង្ហាញប្រាប់នូវទស្សនៈលោកិយសត្វ និងពុទ្ធសាសនានិយម ។ ប្រាសាទដ៏ល្បីកសាងឡើងក្រោមការដឹកនាំរបស់ជ័យវរ្ម័នទី៧ ។

ស្រះទឹក អាងទឹកតូចធំ បារាយណ៍ឥន្ទ្រតតាកៈ បារាយណ៍ខាងកើត បារាយណ៍ខាងលិច ស្រះស្រង់ បារាយណ៍ប្រាសាទ ព្រះខ័ន ។ល។ ក្នុងចំណោងចំពីផលប្រយោជន៍សង្គមកិច្ចជីវភាពប្រចាំថ្ងៃ ក៏ដូចជាសំរាប់បំពីមុខព្រួញ សេដ្ឋកិច្ច ជាតិដែលមានមូលដ្ឋានលើវិស័យកសិកម្ម និង ចិញ្ចឹមសត្វ ដែលជាប្រពៃណីខ្មែរ តាំងពីបុព្វប្រវត្តិសាស្ត្រនោះមកម្ល៉េះ ។ សំណង់ដទៃទៀតដែលយើងចាត់ទុកថាជាវិមានប្រវត្តិសាស្ត្រដែរ ហើយមានតម្លៃចំពីសង្គមមនុស្សពិតនោះ ក៏មានចារិកនៅលើផ្ទាំងសិលារបស់ប្រាសាទព្រះខ័ន : សិលាចារឹក ហៅថា " ផ្ទះមានភ្លើង " ។ ផ្ទះរបៀបនេះ គឺសាលាសំណាក់មានចំនួន ៥៧ នៅតាម ផ្លូវទៅកាន់ ក្រុងវិជ័យ ចំនួន ១៧ សង់នៅតាមផ្លូវចេញពីអង្គរទៅកាន់ ភិម៉ៃ " កូរ៉ាត - ប្រទេសថៃបច្ចុប្បន្ន " ហើយចំនួន ៤៤ នៅតាមផ្លូវរត់ព័ទ្ធជុំវិញផ្ទៃប្រទេស ។ គេរកឃើញ មួយនៅភ្នំជីសូរ ហើយនិងពីរទៀត ស្ថិតនៅក្នុងការសិក្សានៅឡើយ ។ ទន្ទឹមនឹងការកសាងសាលាសំណាក់ គេក៏បានកសាងមន្ទីរពេទ្យ ចំនួន ១០២ ផងដែរទូទាំងស្រុកខ្មែរ អាស្រ័យដោយការល្បីល្បាស់ផ្លូវគមនាគមន៍ជើងគោក ។[២៨]

វិហារធំៗច្រើនទៀត ក៏មានមុខងារបំរើការងារទាក់ទងនឹងតម្រូវការប្រចាំថ្ងៃរបស់ប្រជាជនដែរ ដូចជា វិហារសំរាប់តម្កល់ខ្មោច " អង្គរវត្ត បាខែង បន្ទាយសំរ៉ែ ។ល។ " វិហារសំរាប់សំដែង របាំ ល្ខោន " "សាលធំៗមានសសរច្រើនស្ថិតនៅក្នុងបរិវេណប្រាសាទ " វិហារសង់សំរាប់បំរើការអប់រំ រៀនសូត្រ វិហារសំរាប់ជាវត្តអារាម វិហារអនុស្សាវរីយ៍ " សំរាប់លើកឧបការគុណដល់ឪពុកម្តាយ " ហើយនិង វិហារសំរាប់ជាជំណាក់ " វាំង " នៅអង្គរធំ។

## ៣.៣.- តម្លៃសិល្បារម្មណ៍សាស្ត្រ

គ្រប់ទំរង់សិល្បៈនៃប្រវត្តិសាស្ត្រនិងរឿងសំរាប់ព័ពីជីវភាពស្ងាត់ ។មុខងារសំខាន់នៃទំរង់សិល្បៈគឺបង្ហាញប្រាប់ខ្លឹមសារមួយដែលផ្ទុះចេញពីបញ្ញាញាណនៃ បាតុភូតជាក់ស្តែងរបស់គមនាគមន៍ ។ គំនិតសិល្បារម្មណ៍សាស្ត្រ ហើយនិងវិទ្យាសាស្ត្របង្កើតបានខ្លឹមសារមួយ ដែលលាតត្រដាងអោយទស្សនិកជនដឹងអំពីទស្សនវិជ្ជា ភាសា ហើយនិងដំណោះស្រាយនៃបញ្ញាញាណទាំងឡាយ ។

---

២៨ សឺដេស Coedès : [illegible] ទំព័រ ២០៣ - ២០១

១ _ គំនិត
សិល្បៈ
រូបណ៍ — ទស្សនវិជ្ជា
សាស្ត្រ
ទំរង់ បង្ហាញ : — លោកតូតូដាង — ភាសា
ខ្លឹមសារ — ២ _ វិទ្យាវិចារ — ជំនោរការរូបណ៍

យើងបានយល់ដឹងខ្លះៗហើយនៅក្នុងជំពូកខាងដើម ហើយនិងបានយល់ដឹងបន្ថែម នៅជំពូកខាងក្រោយ អំពីរូបភាពរបស់ប្រាង្គប្រាសាទរបស់ខ្មែរយើង ។ ឆ្លងតាមរយៈនេះយើងត្រូវពិចារណាមើលអោយឃើញនូវគំនិតសិល្បៈរូបណ៍សាស្ត្រដែលស្ថិតនៅខាងក្នុងនៃទំរង់ស្ថាបត្យកម្មដែលចាប់ផ្តើមកសាងឡើងតាំងពីពាក់កណ្តាលនៃសតវត្សទី៩ " ពិសោធន៍នៅទាប " រហូតឈានដល់មានបទពិសោធន៍ប្រើប្រាស់ច្នៃប្រឌិតខ្ពស់ក្នុងសំណង់ ។ គំនិតផ្តួចផ្តើមធ្វើអ្វីៗ ដែលជា សំភារៈអោយងើបឡើងក្នុងជំហរត្រង់ ហើយចាក់ឆ្ពោះទៅលើជានិច្ច ដែលអាចជាសញ្ញាណគ្រប់អោយដឹងអំពីការវិវត្តន៍មិនឈប់ឈរនៃលោកសង្ខារៈ ។ ទាំងក្នុងចម្លាក់សត្វតោ ឬនាគ ទាំងផ្នែកក្នុងកំពូលប្រាង្គប្រាសាទ តិចានស្ពានរៀវពីធំទៅតូចហើយស្រួចចាក់ឆ្ពោះទៅអវកាសទាំងអស់ ។ ទស្សនវិជ្ជានេះកំណត់បានថាប្រជាជនខ្មែរមានទស្សនៈសច្ចៈនិយម មនុស្សនិយមជានិច្ច ។ ជាងចម្លាក់បានប្រកាន់យកអង្គរូបភាពរូប ដើម្បីសាងសង់ នោះគឺការរកសមាមាត្រ រវាងសំណង់ ហើយនិងខ្សែពេជ្ឈៈ ភាពសមតារវាងខ្សែបន្ទាត់ផ្ដេក និងខ្សែបន្ទាត់បញ្ឈរ សមាមាត្ររបស់អាការទាំងមូលរបស់ប្រាសាទ រកឃើញនៅពិភពក្នុងការតុបតែងហោជាងបន្ទាយស្រី រឺរកនៅក្រានស្បែ ហើយនិងវិធីសាងសង់កំពូលទាំង៥ របស់សំណង់ធំៗតាមបែបគណិតវិទ្យាត្រីមាត្រ ។ អាស្រ័យដោយធាតុអាកាសរបស់ស្រុកទេស ដែលជាប្រទេសក្តៅ ការប្រើប្រាស់វិធីសំណង់ អោយមានប្រព័ន្ធស្រូបយកខ្យល់ "ទ្វារ បង្អួចច្រើន ផែរ" គឺជាការចាំបាច់ ហើយក៏ជួយលំអរសោភ័ណរូប ។ អាថ៌កំបាំងក្នុងសំណង់គឺជាវិធីមួយរបស់សិល្បករដែរ ។ ទស្សនិកជនមិនអាចបានស្គាល់ ឬ ដឹងអ្វីដោយមិនបានដើរចលនាអោយបានសព្វទិសទីក្នុងបរិវេណរបស់ប្រាង្គប្រាសាទ ហើយឃើញត្រង់នេះ ហើយមិនអាចពិនបង្ខំចិត្ត

អោយដឹងត្រង់នោះទៀតបានទេ ឃើញត្រង់នេះហើយត្រូវតែឃើញត្រង់នោះទៀត ។ ការរចនាដោយក្បូរក្បាច់ផ្សេងៗ បានបន្ថែមសំរស់ទៅលើសំណង់ថ្ម យោលទៅតាមពេលម៉ោងរបស់ដំណើរព្រះអាទិត្យ ។ សំរស់ទាំងមូលរបស់ប្រាសាទ ដែលមាននវានុវត្តន៍ក្នុងការប្រើប្រាស់សម្ភារៈសំណង់ "ថ្ម - ថ្មភក់ - ថ្មបាយក្រៀម" ប្រែប្រួលទៅតាមពេលវេលា ។ ព្រលឹមមានសំរស់ផ្សេង ថ្ងៃត្រង់ល្អមួយបែប ល្ងាចល្អដោយឡែក ពេលយប់មាន ឬ គ្មានពន្លឺដួងខែល្អខុសគ្នា ។ ប្រសិនបើទស្សនិជនមើលក្បាច់ចម្លាក់ក្នុងប្រាសាទក្នុងវេលាយប់ដោយ ពន្លឺភ្លើងចន្លុះ នោះគេនឹងឃើញល្អមួយបែបទៀត ។ ប្រសិនបើបច្ចុប្បន្នកាលនេះ គេប្រើអំពូល អគ្គិសនីកម្លាំងច្រើន វាត់សំរាប់បញ្ចាំង ដោយប្រើល្បែង " ស្រមោល និងពន្លឺ " នោះ គេឃើញប្រាង្គប្រាសាទ " ពិសេសអង្គរវត្ត " ហាក់អណ្តែតនៅក្នុងផ្ទៃអាកាសវេហាស៍ ប្រៀបបានទេវវិមានឋានសួគ៌ក្នុងក្តីស្រមៃ ។

| |
|---|
| សច្ចៈធម៌ ត្រូវផ្អែកទៅលើលក្ខណៈសម្បត្តិប្រវត្តិសាស្ត្រជាក់លាក់តាមទីកន្លែង និងពេលវេលានីមួយៗ ។ |

## ៣.៤.- សញ្ញាណសាមគ្គី - ការបង្រួបបង្រួម ក្នុងទំរង់ស្ថាបត្យកម្ម

តាំងពីភាគខាងដើមនៃគ្រិស្តសករាជ សាសនាពីរបានចូលមកដល់ប្រទេសកម្ពុជាដូចជា [illegible] : ព្រហ្មញ្ញសាសនា និង ពុទ្ធសាសនា ។ សាសនាទាំងពីរនេះ តែងរស់នៅជាមួយគ្នាបញ្ចូល ទោះប្រជាជន កម្ពុជាប្រកាន់និកាយណាខ្លាំងជាងនិកាយណាក៏ដោយ ។ នាសតវត្សទី ៨ នៃគ្រិស្តសករាជ ប្រទេសជាតិត្រូវបែងចែកជាពីរ : ចិនឡាដែនគោក និង ចិនឡាដែនទឹក ។ ដោយសារមានអស្ថេរភាពទាំងវិស័យនយោបាយ សេដ្ឋកិច្ច និងសង្គមកិច្ចក្នុងសង្គមជាតិ វិស័យសិល្បៈក៏បានធ្លាក់ចុះ អន់ថយបាត់បង់អស់នូវសញ្ញាណខ្មែរពិត ។ អនេកភាពសង្គមខាងវិស័យជំនឿសាសនា បានបែងចែកជានិកាយដែលនាំអោយមានការបែងចែកមនុស្សក្រុមៗ ប្រកាន់ជំនឿផ្សេងគ្នា ។ ដោយយល់ឃើញថាការបង្រួបបង្រួមនិកាយផ្សេងៗទាំងអស់ក្នុងអនេកភាពប្រមូលផ្តុំតែមួយ ជៀសវាងការបែកបាក់គ្នា

សិល្បករចាស់ៗដែលចេះចាំស្ទាត់ មានសប្បជញ្ញៈជំនាញនៃសាលា សិល្បៈធំណានៗដែលអាចរក្សាបានប្រពៃណីល្អៗរបស់អ្នកចិនឡា បានច្នៃប្រឌិតបដិមាដ៏ល្អឈ្មោះ " ហរិហរៈ " ដើម្បីបង្រួបបង្រួមនិកាយពីររបស់ព្រហ្មញ្ញសាសនាអោយមកតែមួយ ។ បក្សពួកដែលបានបែកបាក់គ្នា កន្លងមកអាចឱតជិតគ្នាឡើងវិញ អាស្រ័យដោយក្រុមហោរាក៏បាន មើលឃើញបដិមាដែលគេគោរពនោះមានតួតែមួយ ហើយស្ថិតនៅក្នុងបូជនីយដ្ឋានតែមួយគ្រប់ ទីកន្លែងរបស់ទឹកដីកម្ពុជា ។ ប្រាសាទបាយ័ន ដែលកសាងឡើងនៅដើមសតវត្សទី ១៣ បានឆ្លើយតបទៅនឹងគំនិតខាងលើនេះដែរ ។ នៅនាដើមសតវត្សទី ១០ យសោវរ្ម័ន ដែលជាអ្នកបានកសាងទីក្រុងអង្គរមុនគេ និងមើលឃើញនូវមេរៀនប្រវត្តិសាស្ត្រ ដែលប្រាប់អំពីការប្រេះឆាក្នុងសង្គម ដោយសារកត្តាសាសនា និងកត្តាដទៃទៀតនៃរបបនយោបាយ និងសេដ្ឋកិច្ច បានចាប់ភ្លឹកជាបឋមក្នុងការបង្កើតការគិតគូរដល់មូលដ្ឋានកសិកម្ម ហើយនិងមូលដ្ឋាននៃជំនឿ ។ យសោវរ្ម័នបានចាត់អោយគេសាងសង់វត្តអារាម ៣ សំរាប់បំរើនិកាយវិស្ណុ និកាយសេវៈ ហើយនិងវត្តពុទ្ធសាសនា នៅក្នុងរដ្ឋធានី តែម្តង ។ ក្រៅអំពីនេះ ក៏មានជំនឿលើការបង្រួមនិកាយសិវៈ និងវិស្ណុ ហើយនិង និកាយសិវៈ និងពុទ្ធសាសនា ។

ប្រាសាទបាយ័ន បានបង្កប់ទស្សនៈពីរសំខាន់ : ទស្សនៈសាសនា និងទស្សនៈនយោបាយ ។ ប្រជាជនគ្រប់ស្រទាប់របស់សង្គម អាចទទួលយកបានប្រាសាទនេះថាជារបស់ខ្លួន ព្រោះទោះបីជនណាក៏ដោយអាចគោរពបូជាបាយ័នតាមជំនឿតែរៀងៗខ្លួន ។ ក្បាលមានមុខបួន បង្ហាញប្រាប់គំនិតពីរ : ពួកព្រហ្មនិយម ទទួលស្គាល់ថាជាមុខព្រហ្ម រីឯពួកពុទ្ធនិយម ទទួលស្គាល់ ថាជា មុខពោធិសត្វលោកេស្វរៈ ។ រាល់ជំនឿដទៃទៀតដែលមាននៅតាមខេត្ត ខ័ណ្ឌ ក៏ត្រូវបានប្រមូលផ្តុំមកដាក់នៅតាមបន្ទប់តូចៗ សំរាប់ទទួលពួកអ្នកមកអំពីជនបទ ។ ចំពោះអ្នកលោកិយនិយម បានមើលឃើញកំពូលប្រាសាទទាំង ៥២ គឺតំណាងអោយបណ្តាខេត្តទាំងឡាយរបស់កម្ពុជា នាសម័យនោះ ។ អាស្រ័យដោយប្រាសាទបាយ័នជាប្រាសាទឧទ្ទិសចំពោះពុទ្ធសាសនានោះ យើងជាអ្នក សិក្សាស្រាវជ្រាវបានពិនិត្យទៅលើរូបភាពរបស់កំពូលទាំង ៥២ នៃប្រាសាទបាយ័ន ក្រៅពីមុខបួនផ្សេងទៀត ។ នៅក្នុងសង្គមខ្មែរ យើងបានស្គាល់ពាក្យថា ចេតនា ដែលមានល្អ និងអាក្រក់ ដែលគេអោយឈ្មោះថាកម្ម ។ ចេតនាគឺជាសកម្មភាពរបស់ខួរក្បាល បង្កើតឡើងដោយខួរក្បាល ។ មុខងាររបស់វា គឺ បញ្ជូនចិត្ត ទៅក្នុងអំពើល្អ ឬ អាក្រក់ ឬ អព្យាក្រិត ។ នៅក្នុងពុទ្ធនិយម គេរាប់បាននូវសកម្មភាពរបស់

ខួរក្បាលមានចំនួនប្រមាណ ៥២ ដែលបង្កើតបានជាសង្ខារខន្ធ ។ ក្នុងចំណោមចេតនាទាំង ៥២ នោះ យើងអាចដកស្រង់បានខ្លះៗ ដូចតទៅនេះ : ១ វេទនា ២ ឆន្ទៈ ៣ អធិមោក្ខ ៤ សទ្ធា ៥ សមាធិ ៦ បញ្ញា ៧ វិរិយៈ៨ រាគៈ៩ បដិឃៈ "គំហិង"១០ អវិជ្ជា១១ អំនួត១២ សក្កាយទិដ្ឋិ "គំនិតផ្ទាល់ខ្លួនម្នាក់ៗ" ។ល។

តាមការកត់ចំណាំរបស់បេសកជនជាវតា គួន នៅក្នុងឆ្នាំ ១២៩៦ ប្រទេសកម្ពុជាយើងមានអាណាខេត្តទាំងអស់ចំនួន ៩០ ឯណោះ ។ ម៉្យាងទៀត បណ្តាផ្ទាំងរឿងជាចម្លាក់ ក្រឡោតទាបក៏បង្ហាញប្រាប់អំពីជីវភាពប្រជាជនពិតៗ នៃសម័យ នោះដែរ ។ ក្នុងទស្សនៈទំនាក់ទំនងសង្គម បាយ័នដែលជាបេះដូងរបស់រដ្ឋកម្ពុជា បានសំដែង អោយឃើញអំពីការបើកផ្លូវស្វាគមន៍ចំពោះបណ្តាមិត្តជិតឆ្ងាយដែលមកអំពីទិសធំទាំងបួន ។ ទិសខាងកើត គឺ កំណត់ យកមាតាបិតា ទិសខាងត្បូងគ្រូបាធ្យាយ ទិសខាងលិច ប្រពន្ធ - កូន ឯទិសខាងជើងគឺញាតិសន្តាន អ្នកជិត ខាង ។ តើបបូរមាត់ញញឹម ភ្នែកបិទពាក់កណ្តាល នោះបានបង្ហាញប្រាប់អំពីអ្វីដែរ ? ចំពោះសំនួរនេះអ្នកនិពន្ធ អ្នកស្រាវជ្រាវ ជាច្រើនបានអោយតម្លៃប្លែកៗតាមការយល់ឃើញ និងការរំភើបដោយឡែកៗ អំពីគ្នា ។ ការយល់ឃើញមួយចេញអំពីអ្នកស្រាវជ្រាវច្រើនគ្នា បានអោយតម្លៃទៅលើ ការស្ងប់ក្នុង ដំណើរធ្វើសមាធិ ដែលគេអោយឈ្មោះថា " ញញឹមអាថ៌កំបាំង " ។

យើងពិចារណា និងឆ្លុះបញ្ចាំងតាមទស្សនៈរូបីយ៍របស់យើងនូវស្នាមញញឹមនៃព្រះភក្ត្រ លោកេស្វរៈនេះ ។ នេះគឺទំនងជាការញញឹមនៅពីលើជីវិត ឥតភ័យខ្លាច ឬ តក់ស្លុតនិងសេចក្តីស្លាប់ ពី ព្រោះវាជាការធម្មតាទៅហើយ របស់លោកេស្វរៈនេះ ។ អ្វីៗ ពុំស្ថិតនៅហ្នឹងមួយកន្លែងបានទេ បើមានកំណើតឡើងហើយ តែងតែវិនាសទៅវិញ ជាធម្មតា ។ ស្នាមញញឹមនេះពិតជាបញ្ជាក់បាន ក្តីសង្ឃឹមទៅអនាគត សង្ឃឹមលើការយកជ័យជំនះលើធម្មជាតិ និង បណ្តាជាតុភូតក្នុងសង្គម ដោយសារកម្លាំងពលកម្មរបស់ខ្លួន ញញឹមជឿលើកម្លាំងអត្តនោរ៉ត ដែលមិនត្រូវផ្តេកផ្តួលលើ វាសនា ពោល គឺត្រូវស្គាល់ខ្លួនឯង ដែលជាសន្ទស្សន៍វាប់វាស់ការរីកចំរើនរបស់បុគ្គល និងសង្គម ។ រីឯភ្នែកបិទទំនងជាបង្ហាញអោយយើងដឹងអំពីការប្រើប្រាស់បញ្ញាចក្ខុ ដែលអាចមើលឃើញបានវែងឆ្ងាយច្រើនជាងការប្រើប្រាស់មំសចក្ខុដែលអាចមើលឃើញបានរយៈចម្ងាយតែមួយយោជន៍ប៉ុណ្ណោះ ។

ពុទ្ធសាសនិកជនពិតប្រាកដ គឺតែងរីករាយជាងអ្នកដទៃ ។ ព្រោះគេគ្មានខ្លាច និងព្រួយបារម្ភអ្វីទេ ។ គេតែងស្ងប់ និង ជ្រះថ្លាជានិច្ច ។ មនុស្សដែលកើតទាន់សម័យពោធិសត្វ តែងនិយាយថា លោក

"ញញឹមជានិច្ច" ។ ដូច្នេះហើយបានជាមុខទាំង ៤ របស់ប្រាសាទបាយ័ន បង្ហាញអោយឃើញនូវទំរង់មុខរីករាយ បរិសុទ្ធ ត្រេកអរ និងករុណា ក្នុងរាល់ស្នាដៃសិល្បៈដែលឧទ្ទិសចំពោះ ពុទ្ធសាសនា តែងតែងផ្តល់បរិយាកាសស្ងប់ ហើយនិងសេចក្តីសប្បាយមួយ ។ អត្ថន័យពិតដូចមានចែង ខាងលើនេះ គឺ ជាចម្លើយទៅនឹងសំនួរ បបូរមាត់ញញឹម ភ្នែកបិទ របស់ស្នាដៃសិល្បៈ នៃសតវត្សទី ១៣ របស់សម័យអង្គររុងរឿង ។

| |
|---|
| អតីតកាលមានប្រយោជន៍ខ្លាំងណាស់សំរាប់បច្ចុប្បន្នកាល ។ |

# IV - រចនាបថសំខាន់ៗក្នុងស្ថាបត្យកម្ម របស់ពិមានប្រវត្តិសាស្ត្រ

អ្នកសិក្សាស្រាវជ្រាវបានតម្រូវអោយចែកប្រវត្តិវិមានស្ថាបត្យកម្មជារចនាបថ ដើម្បីធ្វើការសិក្សាច្បាស់លាស់ អំពីដំណាក់កាលវិវត្តន៍សំខាន់របស់សំណង់ ។ គេមិនត្រូវកំណត់រចនាបថទាំងឡាយនេះថាជាប្លុកមួយកំរងក្នុងក្របខណ្ឌ រឹងកំព្រឹះនោះទេ ក៏ប៉ុន្តែ ត្រូវទុកដូចជាការបត់ចុះឡើងដ៏ទន់ភ្លន់មួយ ។

៤.១. រចនាបថមុនសម័យអង្គរ [២៥]

៤.១.១. រចនាបថភ្នំដា : ឆ្នាំ ៥៤០ - ៦០០ " ទីតាំងសព្វថ្ងៃក្នុងស្រុកអង្គរបុរី "

៤.១.២. រចនាបថសំបូរព្រៃគុក : ឆ្នាំ ៦០០ - ៦៥០ " ស្រុកកំពង់ស្វាយ - កំពង់ធំ "

៤.១.៣. រចនាបថព្រៃក្មេង : ឆ្នាំ ៦៣៥ - ៧០០ " សៀមរាប "

៤.១.៤. រចនាបថកំពង់ព្រះ : ឆ្នាំ ៧០៦ - ៨០០ " កំពង់ឆ្នាំង "

៤.២. រចនាបថចន្លោះ : រចនាបថសម័យគូលែន : ឆ្នាំ ៨២៥ - ៨៧៥ .

៤.៣. រចនាបថសម័យអង្គរ

៤.៣.១. រចនាបថព្រះគោ : ឆ្នាំ ៨៧៥ - ៨៩៣

៤.៣.២. រចនាបថបាខែង : ឆ្នាំ ៨៩៣ - ៩២៥

---

២៥ : ពិសិដ្ឋលោ : អាស៊ីអាគ្នេយ៍ - កម្ពុជា - ទំព័រ ៤២

៤.៣.៣. រចនាបថកោះកេរ ឆ្នាំ ៩២១ - ៩៤៥

៤.៣.៤. រចនាបថប្រែរូប " រចនាបថចន្លោះ : ឆ្នាំ ៩៤៧ - ៩៦៥

៤.៣.៥. រចនាបថបន្ទាយស្រី : ឆ្នាំ ៩៦៧ - ១០០០

៤.៣.៦. រចនាបថ ឃ្លាំង : ឆ្នាំ ៩៦៥ - ១០១០

៤.៣.៧. រចនាបថ បាពួន : ឆ្នាំ ១០១០ - ១០៨០

៤.៣.៨. រចនាបថ អង្គរវត្ត : ឆ្នាំ ១១០០ - ១១៧៥

៤.៣.៩. រចនាបថ បាយ័ន : ឆ្នាំ ១១៧៧ - ១២៣០

៤.៤. រចនាបថក្រោយអង្គរ - រចនាបថនេះ គិតចាប់តាំងពីឆ្នាំ ១៤៣១ នៃគ្រិស្តសករាជ។ យើងអោយនិយមន័យថ្មីមួយហៅថា រចនាបថថ្មី ដោយសារការបាត់បង់ការរចនាតាមបែបស្ថាបត្យកម្ម ជាប្រពៃណីស្ទើរតែទាំងអស់ ។ សម័យនេះបញ្ជាក់បានអំពីការឆ្លងអំពីស្ថាបត្យកម្មកសាងឡើងអំពីថ្ម ទៅកាន់ស្ថាបត្យកម្ម កសាងឡើងអំពីគ្រឿងឈើ ឬ អំពីសម្ភារៈសំណង់ធុះ ។

ព្រឹត្តិការណ៍ពីរជាក់ស្តែងបានបញ្ជាក់ប្រាប់អំពីការបោះបង់ចោលស្ថាបត្យកម្មអំពីថ្ម :

១ - កន្លែងយកថ្មសំរាប់ធ្វើជាសម្ភារៈសំណង់ត្រូវអស់ នាកាលខាងចុងនៃសម័យជ័យវរ្ម័នទី ៧ ។

២ - សំណង់អំពីគ្រឿងឈើ និងសម្ភារៈសំណង់ធុះចិសបស្របទៅនឹងការបំរើពុទ្ធសាសនាហីនយាន ។ រាល់សំណង់ត្រូវបានលើកល្វែងធំៗ សំរាប់ទទួលឧបាសក ឧបាសិកាបានច្រើន ដែលផ្ទុយអំពីសាលទាំងឡាយក្នុងស្ថាបត្យកម្មប្រពៃណីដែលកសាងឡើងអំពីថ្ម ។

ក្នុងសម័យសៀមកាន់កាប់ទីក្រុងអង្គរជាបណ្ដោះអាសន្ននាឆ្នាំ ១៤៣១ ប្រពៃណីខ្មែរ ជាច្រើនបានបន្ត និងរក្សាការរស់រវើករបស់ខ្លួននៅក្នុងមជ្ឈមណ្ឌលថ្មីៗ ជាច្រើន នៅ ស្រី - សន្ធរ ។

ជីវិតថ្មីរបស់សិល្បៈខ្មែរបានរស់រានឡើងវិញនាសតវត្សទី ១៦ ក្រោយពីបានដេញពួកថៃឈ្លានពានចេញអំពីស្រុក ។ គេសង្កេតឃើញមានការជួសជុលប្រាសាទនៅអង្គរវត្ត - ប្រាសាទវត្តនគរ នៅកំពង់ចាម ។

## ៤.៥. រចនាបថភ្នំដា -

របកគំហើញបុរាណវិទ្យានៃសម័យនេះ ស្ថិតនៅក្នុង ស្រុកអង្គរបូរី ខេត្តតាកែវ សព្វថ្ងៃនេះ ។

ប្រាសាទជាក់បែកអស់រលីង ប៉ុន្តែបដិមាជាច្រើននៅសេសសល់រហូតមកដល់សព្វថ្ងៃ ។ បដិមាករ ចែកចេញជាពីរ :

១ - ពុទ្ធបដិមា ដែលមានស្លាកស្នាម រំឭកបិតុភ្នំ - គ្រិច

២ - ព្រហ្មញ្ញបដិមា ដូចជាវិស្ណុ ៨ ដៃ រូបព្រះរាម រូបពលរាម ។

ក្នុងរចនាបថនេះ សិល្បករបានចាប់អារម្មណ៍ទៅលើការបូកបញ្ចូលគ្នា របស់សិល្បៈរាមណ៍ សាស្ត្រ ធម្មជាតិ និយម ហើយនិងពិសិដ្ឋនិយម នៅក្នុងបណ្ដារូបបដិមាទាំងឡាយនេះ ។ បដិមាទី ១ - ទី ២ បានដាក់តាំងនៅក្នុងសារមន្ទីរវត្ថុបុរាណនៅភ្នំពេញ ។

## ៤.៦.- រចនាបថសំបូរព្រៃគុក . ក្នុងសម័យចិន - ឡា ពាក់កណ្ដាលទី ១ ស.វ. ទី ៧

ទីតាំងសព្វថ្ងៃនៅក្នុងស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ។ ប្រាសាទសង់ឡើងអំពីឥដ្ឋ លើកលែង តែសមាសធាតុតុបតែងមួយចំនួនដូចជា ផ្ដែរទ្វារ សសរពេជ្រ មេទ្វារ ។ល។ ដែលកសាងអំពីថ្មភក់ ។ ក្នុង ចំណោមប្រាសាទមានប្លង់ការេ គេសង្កេតឃើញមានប្រាសាទខ្លះ កសាងឡើងតាមប្លង់រាងចតុ កោណកែង ។ សមាសធាតុស្ថាបត្យកម្មមានជាប់ស្លាកស្នាមទំនាក់ទំនងជា មួយសមាសធាតុតុបតែង លំអរបស់ឥណ្ឌា ដែលកសាងឡើងតាំងពីសម័យកសាងប្រាសាទអាហ្សង់តាចោះលុង ចូលទៅក្នុង សាច់ថ្មភ្នំ " សតវត្សទី ៥ - ៦ - គ.ស. ហើយនិងប្រាង្គប្រាសាទនាសតវត្សទី ៧ ។ ប្រាសាទកសាង ឡើងក្នុងអំឡុងដំណាលគ្នា : ក្រុមប្រាសាទសំបូរព្រៃគុក ប្រាសាទភ្នំធំ " កំពង់ធាម " ប្រាសាទ ដំបងដែក " កំពង់ធាម " ។

## ៤.៧.- រចនាបថព្រៃក្មេង. ក្នុងសម័យ ចិន-ឡា ពាក់កណ្ដាលទី ២ ស.វ. ទី ៧

សិល្បៈក្នុងសម័យនេះ បង្ហាញការឲ្យតម្លៃទៅលើមនុស្សច្រើនជាងធម្មជាតិនៅជុំវិញខ្លួន ។ គេបានកំណត់ថា រចនាបថព្រៃក្មេងជាសម័យសិល្បៈឡើងដល់កំពូល ។ នៅក្នុងបដិមាសិល្បៈ សិល្បករបានឈានទៅដល់ភាពសុក្រិតនៃសមាមាត្រ សមតា និង ស្គាល់សារវិទ្យាច្នៃទនសាស្ត្រ

សូមអានទំព័រ ក

សូមអានទំព័រ ខ

របស់មនុស្សយ៉ាងត្រឹមត្រូវ ។ រូប ហរិហរៈ របស់ប្រាសាទអណ្តែត សព្វថ្ងៃ នេះតាំងនៅក្នុងសារៈមន្ទីរវត្ថុបុរាណ ភ្នំពេញជាភស្តុតាងនៃបដិមាសិល្បៈសម័យនោះហើយនិងមានតម្លៃយ៉ាងខ្ពស់ ក្នុងចំណោមរូបល្អៗនៃចម្លាក់ពិភពលោក ។

ប្រាង្គប្រាសាទដែលកសាងឡើងក្នុងអំឡុងដំណាលគ្នា : ប្រាសាទព្រៃក្មេង " សៀមរាប " ប្រាសាទស្វាយព្រាប " ផ្នែកចាស់ៗខ្លះរបស់ប្រាសាទ " ប្រាសាទបាសិត " ទ្វារខាងកើត " ប្រាសាទព្រៃប្រាសាទ " ប្រាសាទខាងត្បូង " ប្រាសាទអណ្តែត ប្រាសាទភ្នំបាយ៉ង ។

នៅក្នុងសម័យចិនឡារុងរឿងយើងសង្កេតឃើញមានទ្រង់ទ្រាយប្រាសាទខ្លះដែលកសាងឡើងតាមគំរូប្លង់ប្លែកខុសគ្នា ដូចជាប្រាសាទអាស្រមមហាឫស៊ី " តាកែវ " ប្រាសាទតុកព្រះធាតុ និងប្រាសាទហាន់ ជ័យ " ក្នុងខេត្តកំពង់ចាម " និងប្រាសាទអដ្ឋកោណ " ក្នុងក្រុមប្រាសាទសំបូរ ។

## ៤. ៨ រចនាបថកំពង់ព្រះ សម័យចិន- ឡា រំបែកបាក់ : ដើមសតវត្ស ទី ៨ : ៧១៣

ក្រោយពីជ័យវរ្ម័នទី ១ សុគតទៅដោយគ្មានកូនបន្តតំណែង អាណាចក្រចិន-ឡាស្ថិតនៅក្រោមការគ្រប់គ្រងរបស់ស្តេចស្រីព្រះនាម ជ័យទេវី ជារាជនិទេម៉ាយរបស់ជ័យវរ្ម័នទី ១ ។ ប្រទេសកម្ពុជា ចាប់ផ្តើមមានទំនាស់គ្នារវាងបណ្តាមណ្ឌលកណ្តាល និង បណ្តាមណ្ឌលខាងរស្មីម និងតំបន់សមុទ្រ ។ ក្រោយមកអាណាចក្រចិន - ឡា ទាំងមូលបែកចេញទៅជារដ្ឋពីរ : រដ្ឋចិន - ឡា ដែនគោក និង ចិន- ឡា ដែនទឹក ។ អាស្រ័យដោយការមានសង្គ្រាមក្នុងស្រុក សិល្បៈក្នុងសម័យនោះចុះខ្សោយបាត់បង់អស់សកម្មភាពច្នៃប្រឌិត ។ បដិមាសិល្បៈជាច្រើនបានបង្ហាញភាពល្ងង់ខ្លៅក្នុងបច្ចេកទេសឆ្លាក់ថ្ម ។ ទេពកោសល្យដែលមានពន្លកររកហើយក្នុងសម័យព្រៃក្មេង បានរលប់បាត់ពីក្នុងព្រលឹងរបស់សិល្បករ ហើយសកម្មភាពសិល្បៈបានក្លាយទៅជា ការចម្លងតាមគ្នា ដោយងងឹតងងល់បំផុត ។ ពេលមានសង្គ្រាម សិល្បៈត្រូវតែផ្អាកដំណើរ ។

ក្នុងសាកលធាតុសំណង់មានជាប់ស្លាកស្នាមសល់ភ្ជាទៅឡើយ ។ តែចម្លាក់លើផ្តែទ្វារមានទិន្នាការមួយបំបាត់រូបចម្លាក់សត្វ " មករ - គិរតិមុខ " ហើយពន្លេចក្បាច់ស្លឹកនិងទងឈើ ប្លែកទាំងស្រុងអំពីរចនាបថមុនៗ ។

ប្រាង្គប្រាសាទដែលកសាងឡើងដំណាលគ្នា : ប្រាសាទកំពង់ព្រះ " កំពង់ឆ្នាំង " ប្រាសាទអកយំ " ថ្មែកចាស់ៗ " ប្រាសាទត្រពាំងផុង " ថ្មែកចាស់ៗ " ប្រាសាទ បាសិត " ទ្វារលិច " ប្រាសាទភូមិ ប្រាសាទ " ៧០៦ - កំពង់ធំ " ។

## ៤.៩. រចនាបថ គូលែន. រចនាបថចន្លោះ ៨២៥-៨៧៥

សម័យនេះគឺជាការចាប់ផ្តើមសិល្បៈ " អង្គរ " ។ ជ័យវរ្ម័នទី ២ ជាពូជពង្សខ្មែរស្ថិតនៅក្នុងរដ្ឋចិន-ឡា ដែនទឹកដែលត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់សន្តតិវង្សសៃលេន្ទ្ររបស់កោះជ្វានាចុងសតវត្សទី ៨ ។ ពួកសៃលេន្ទ្របានចាប់ត្រូសារជ័យវរ្ម័នទី ២ ទៅរស់នៅលើ កោះជ្វា ។ ពេលព្រះអង្គគេចពីកោះជ្វាមកវិញ ព្រះអង្គបានខិតខំបំពេញគោលដៅពីរ : ១ - រំដោះជាតិចេញអោយផុតពីកោះជ្វា ២ - បង្រួបបង្រួមជាតិ ដោយពីងផ្អែកលើរដ្ឋតូចៗជាទៀតដែលបែកបាក់គ្នាក្នុងសម័យចិន-ឡា ។ រដ្ឋកាលនេះគឺជា ការប្រយុទ្ធមួយយ៉ាងវែង ដើម្បីប្រមូលកម្លាំង ហើយនិងការកសាងទីក្រុងជាច្រើននៅតាមតំបន់ទាំងឡាយដែលបានបង្រួបបង្រួមរួច ហើយ ។ ចាប់តាំងពី ឥន្ទ្របុរី "បន្ទាយព្រៃនគរ : កំពង់ចាម" ទៅដល់តំបន់ភ្នំ គូលេន ព្រះអង្គបានកសាងទីក្រុង ៥ ដែលជាការចាប់ផ្តើមនៃសិល្បៈសម័យអង្គរ ដោយបង្ហាញទ្រង់ទ្រាយប្រាង្គប្រាសាទដ៏ច្រើន ហើយនិងបដិមាសិល្បៈ។

ស្ថាបត្យកម្មសម័យនេះស្ថិតនៅក្បែរនិងស្ថាបត្យកម្មសំបូរព្រៃគុក ។ ក្បាច់ចម្លាក់លើផ្តែរទ្វារចម្លងយកគំរូចាស់ និង គំរូអំពី កោះជ្វា មកប្រើប្រាស់ ។ បដិមាសិល្បៈបង្ហាញស្នាកស្នាមឥណ្ឌាតិចតួចនៅឡើយនាភាគខាងដើម ប៉ុន្តែមាននិន្នាការមួយទៅរកអ្វីដែលជាខ្មែរនៅភាគខាងចុងនៃ សម័យនេះ។

ប្រាង្គប្រាសាទដែលកសាងឡើងក្នុងអំឡុងដំណាលគ្នា : ប្រាសាទ ព្រៃប្រាសាទ " ខាងជើង " ប្រាសាទសំបូរ សេ ១ ប្រាសាទដីក្រហម ប្រាសាទអូផ្អុង ប្រាសាទខ្ចឹងស្លាប់ ប្រាសាទរូបអារក្ស ប្រាសាទ ថ្មដាប់ ប្រាសាទតគិរ ប្រាសាទក្រហម ប្រាសាទអ្នកតា ។

## ៤.១០. រចនាបថព្រះគោ ចុងសតវត្សទី ៩ :

## ៨៧៥-៨៩៣

ថាបទិកនៅតែប្រើប្រាស់ឥដ្ឋជាសំភារៈសំណង់នៅឡើយ សំរាប់ការសាងសង់វិមានប្រវត្តិសាស្ត្រ ។ ពន្លកនៃការច្នៃប្រឌិតថ្មី បានផុសចេញយ៉ាងជាក់ស្តែង នៅក្នុងការតុបតែងលំអខឿនប្រាសាទ ផញ្ចាំង ហើយនិងការបន្ថែមចំនួនប្រាសាទនៅលើខឿនតែមួយនិង ពង្រីកបច្ចេកទេសសំណង់តាមរយៈការ សាកល្បងកសាងប្រាសាទ-ភ្នំ ដំបូងក្នុងរចនាបថនេះ ។ បន្ថែមពីលើនេះគេសាកល្បងឆ្លាក់រូបត្រុឌ មានចលនា និង ក្បាច់ក្រឡោត-ទាប " រូបយក្ខ " ជាដំបូងបង្អស់នៅខឿនខាងលើរបស់ប្រាសាទបាគង ។ រូបភាពសិល្បៈបានក្លាយមកជាទ្រង់ទ្រាយខ្មែរពិតប្រាកដ ហើយបង្ហាញការវិវត្តន៍យ៉ាងខ្លាំងក្នុងស្ថាបត្យកម្ម : បោះបង់ចោលសំណង់ទោល បន្ថែមចំនួនប្រាសាទលើខឿនតែមួយ " ប្រាសាទព្រះគោ ៨៧៩ " និង ប្រាសាទលលៃ ៨៩៣ ហើយនិងប្រាសាទ-ភ្នំ "បាគង ៨៨១" ។

ប្រាង្គប្រាសាទ ដែលកសាងឡើងក្នុងអំឡុងដំណាលគ្នា : ប្រាសាទព្រះគោ ប្រាសាទបាគង ប្រាសាទលលៃ ។

| |
|---|
| វឌ្ឍនភាពសិល្បៈ ស្ថិតនៅត្រង់លទ្ធភាពទាំងឡាយដែលសម័យកាលជាក់ស្តែងផ្តល់អោយសំរាប់សិល្បៈ |

## ៤.១១. រចនាបថ បាខែង ចុងសតវត្សទី ៩ - ដើមសតវត្សទី ១០

សម័យនេះ គឺ សិល្បៈខ្មែរបានស្ថិតនៅក្នុងរង្វង់អាទ្យធិបតីមួយឈ្មោះថា " អង្គរ " ។ ព្រះបាទយសោវរ្ម័នជាស្តេចទី ១ ដែលបានកសាងទីក្រុងអង្គរដំបូងបង្អស់ដែលមាន ប្រាសាទភ្នំ បាខែង ជាមេដ្ឋាន បន្ទាប់ពីការវិលត្រឡប់របស់ជ័យវរ្ម័នទី ២ មកតាំងទីក្នុងទីក្រុង ហរិហរាល័យ " រលួស " ជាលើកទី ២ ។ យើងសង្កេតឃើញសកម្មភាពច្នៃប្រឌិតសិល្បៈដែលផុសឡើងក្នុងសម័យព្រះគោ បាន

សូមអានទំព័រ ត

បន្តមកក្នុងរចនាបថនេះទៀត ដោយបានគោរពទ្រង់ទ្រាយរចនាបថព្រះគោ ប៉ុន្តែបានបោះបង់ចោលឥដ្ឋ [២៣] ដោយយកថ្មភក់និងថ្មបាយក្រៀមសំរាប់កសាងប្រាសាទមកជំនួសវិញ ។ វិស័យបដិមាសិល្បៈបានបន្តភាពថ្មីងនៃសម័យព្រះគោ ប៉ុន្តែ ប្រឌិតសំលៀកបំពាក់ចាប់ក្បិជាដំបូងក្នុងសម័យនោះ ។

ប្រាង្គប្រាសាទដែលកសាងឡើងក្នុងអំឡុងដំណាលគ្នានេះ ប្រាសាទភ្នំ បាខែង "ប្រាសាទភ្នំ" ប្រាសាទភ្នំក្រោម " ប្រាសាទ ៣ លើខឿនតែមួយ " និង ប្រាសាទភ្នំបូក ។

## ៤.១២. រចនាបថ កោះកែរ ពាក់កណ្តាលទី ២ សតវត្សទី ១០ : ៩២១ . ៩៥៤

វិបត្តិនយោបាយបានកើតឡើងក្រោយទំរង់តូចតាចនៅឡើយ នៅក្នុងរជ្ជកាលនៃព្រះរាជបុត្ររបស់យសោវរ្ម័ន ។ វិបត្តិនោះគឺការប្រឆាំងរបស់អភិជនសក្តិភូមិជានាម៉ឺន និង អភិជនសក្តិភូមិជាបព្វជិត ។ ព្រះបាទ ជ័យវរ្ម័នទី ៤ ជាឪពុកមាបានខិតខំសាកល្បងបង្ក្រាបការ គស្មីខាងលើនេះ ។ សកម្មភាពរបស់ជ័យវរ្ម័នទី ៤ នាំអោយមានវិបត្តិជាមួយព្រះបាទ ហស៌វរ្ម័នទី ១ និង ឦសានវរ្ម័នទី ២ ដែលជាក្មួយ ។ វិបត្តិនេះទំនងជាបានទាក់ទងទៅនឹងការប្តូរជំនឿ អំពីនិកាយឥស្វរ មកនិកាយវិស្ណុវិញ។ ព្រះបាទជ័យវរ្ម័នទី ៤ បានប្រកាន់វិយាបថប្រឆាំង និងក្មួយ ហើយបានចាកចេញអំពីយសោធរៈ "ក្រុងអង្គរទី ១ " ទៅតាំងទីនៅតំបន់គោក គគិរ " កោះកែរ " ។

ក្នុងបំណងពង្រឹងរដ្ឋអំណាច ជ័យវរ្ម័នទី ៤ បានកសាងទីក្រុងថ្មីនៅកោះកែរ ដែលមានប្រាង្គប្រាសាទច្រើន ហើយធំៗផងសំរាប់តំកល់រាជលិង្គត្រីភូវនេស្វរៈ ដោយឥតគិតដល់តម្លៃនៃប្រព័ន្ធទំនាក់ទំនងខាង សង្គមកិច្ចឡើយក្នុងការសំដែងមហិទ្ធិឫទ្ធិរបស់ មហារាជនេះ ។

ប្លង់សំខាន់របស់ប្រាសាទនៅ គោកគគិរ គឺអនុវត្តយកខ្សែបន្ទាត់ បេដ្យាអំរជាមេ នៅលើវាលរាបខុសប្លែកអំពីសម័យខាងដើម ។ បដិមាសិល្បៈបង្ហាញអោយឃើញការរិះរកចលនាថ្មីមួយ ។ រូបចម្លាក់នោះគឺ ការឆ្លាក់រូប អោយមានចលនា ដែលយើងឃើញមានពន្លកខ្លះរួចមកហើយ នៅក្នុងរចនាបថព្រះគោ : ឧទាហរណ៍ រូប ស៊ីវៈរាំ រូបគ្រុឌដើរ រូបតំបាច់រវាងសុគ្រីព និង ពាលី រូបតំបាច់រវាងយក្ខនិងទេវតា ។ ល ។ របៀបស្លៀកពាក់នៅក្បាលសំពត់ចាប់ក្បិដូចសម័យបាខែង ។

---

២៣ ប្រាសាទ សាងពីថ្មភក់ចំនួន ៥៥ ទៀត នៅលើទីជុំវិញប្រាសាទភ្នំ ។ ប៉ុន្តែគេចាត់ទុកថា ជាប្រាសាទបន្ទាប់បន្សំ ព្រោះសម័យនេះ ក្លាក់ចម្លាក់ជាធំបង់ ដ៏ ពរកឃើញកសាងខាងកើត ហើយនិងស្រាវជ្រាវកម្មវិធីដែលធំសំរេចសំរាប់រចនាបថនេះ ។

សូមអានទំព័រ ឃ

ប្រាង្គប្រាសាទដែលកសាងឡើងក្នុងអំឡុងដំណាលគ្នា : ប្រាសាទធំ ប្រាង្គ ប្រាសាទនាងខ្មៅ ប្រាសាទជីរ ប្រាសាទក្រហម ប្រាសាទចិន ប្រាសាទបូក ប្រាសាទជ្រាំ ...

នៅគ្រប់សម័យកាលទាំងអស់ សិល្បៈ " ធំទិត ខ្ជីបងារ ...ចំដែង " គឺជាលទ្ធផលរបស់សម័យកាលជាក់ស្ដែង។

## ៤.១៣. រចនាបថប្រែរូប រចនាបថបន្ទាយស្រី ៩៤៧ - ៩៦៥

ក្រោយពីមរណភាពរបស់ជ័យវរ្ម័នទី ៤ វិបត្តិក្នុងតំណរក្នុងរដ្ឋបានកើតឡើងក្នុងរង្វង់អភិជន សក្តិភូមិដែលគាំទ្រព្រះរាជបុត្ររបស់ជ័យវរ្ម័នទី ៤ ព្រះនាមហស៌វរ្ម័នទី ២ ហើយនិងអភិជនសក្តិភូមិគាំទ្រព្រះបាទរាជេន្ទ្រវរ្ម័នទី ២ ដែលត្រូវជាបងប្អូនជីដូនមួយនឹងគ្នា[២៣] ។ ប៉ុន្តែជ័យជំនះត្រូវបានទៅបក្សពួកខាងរាជេន្ទ្រវរ្ម័នទី ២ ។ អាស្រ័យដោយស្ដេចខាងក្រោយនេះត្រូវបានទទួលការគាំទ្រអំពីអភិជនដែលរស់នៅក្នុងទីក្រុង យសោធរៈការបោះបង់ចោលទីក្រុងកោះកែរ បានប្រព្រឹត្តឡើងក្នុងរជ្ជកាលរាជេន្ទ្រវរ្ម័នទី ២ ហើយទីក្រុងយសោធរៈ ក៏បានរស្មីជាលើកទី ២ ឡើងវិញ ដែលយើងហៅថា " អង្គរទី ២ " ។ ក្នុងរជ្ជកាលរាជេន្ទ្រវរ្ម័នទី ២ និង ព្រះរាជ បុត្រព្រះនាម ជ័យវរ្ម័នទី ៥ គឺជាដំណាក់កាលផ្ដើមសម័យរុងរឿងរបស់ចក្រភព កម្ពុជា ។

ប្រាសាទសាងសង់ក្រោមទ្រង់ទ្រាយប្រាសាទ-ភ្នំដែលមានខឿនសាងអំពីថ្ម ទ្រប្រាសាទធំ ៥ សាង អំពីឥដ្ឋ ។

រចនាបថនេះ បានយកគំរូបន្តចាស់ មកអនុវត្តនៅក្នុងពេលមួយ ដែលមានការសន្សំសំចៃថ្មកក់ ក្នុងសំណង់ ។ ប្រាសាទប្រែរូបជាស្នាដៃដ៏ធំ និងមានសមាមាត្រដ៏ល្អបំផុត ហើយសាងឡើងអំពីថ្មបាយក្រៀម និងឥដ្ឋ ដែលជាសំភារៈមានពណ៌ក្ដៅ ។

សំរស់របស់ប្រាសាទបានកើតឡើងនាពេលព្រលឹមថ្ងៃរះ និង ពេលព្រះអាទិត្យហៀបអស្ដង្គតទៅវិញ ។

---

២៣ ឯកសារប្រវត្តិសាស្ត្រសរសេរដោយស្ដេចវៀតណា : ហស៌វរ្ម័នទី ២ ជាបងប្អូនជីដូនមួយ និងរាជេន្ទ្រា វរ្ម័នទី ២ ។ តាមឯកសាររបស់ជាតិឯទៀត រាជេន្ទ្រាវរ្ម័នទី ២ ត្រូវជាកូនប្រុស របស់ជ័យវរ្ម័នទី ៤ ។ តែយ៉ាងណាក៏ដោយគួរចង្អុលបង្ហាញថា [illegible]



រូបថតសហការរបស់.ឡូប៊ិន ៈប្រាសាទប្រែរូប កសាងអំពីថ្មភក់ និង ឥដ្ឋក្នុងស.វ.ទី ១០ បន្ទាប់ពី កោះកែរ ។ ប្រាសាទនេះបានបង្ហាញ អោយឃើញសមាត្រដ៏ល្អ ហើយ និងបច្ចេកទេសប្រើសំភារៈសំណង់ដើម្បីធ្វើ អោយប្រាសាទល្អ តាមដំណើរនៃព្រះអាទិត្យ ។

photo.coopérée de Bill Lobban

រាល់ស្នាដៃមានទិន្នាការទូទៅវិលទៅរកសម័យដើម តែខុសប្លែកខ្លាំងអំពីសម័យកោះកែរ និងបន្ទាយស្រី ។

ប្រាង្គប្រាសាទ ដែលកសាងឡើងក្នុងអំឡុងដំណាលគ្នា : ប្រាសាទមេបុណ្យ ៩៥២ ,ប្រាសាទប្រែរូប ៩៦១ ,ប្រាសាទឈាក់នាង ៩៦០ ។

## ៤.១៤. រចនាបថបន្ទាយស្រី :

ជាមួយនិងការវិលត្រឡប់មកកាន់ប្តីរីនៅអង្គរវិញ ប្រាសាទភ្នំ បានឈានទៅដល់ទំហំដ៏ស្តឹមស្តៃ ប្រកបដោយសុក្រិតភាពក្នុងសមាមាត្រ : ប្រាសាទប្រែរូប ។

ប្រាសាទបន្ទាយស្រី " ៩៦៧ " ជាប្រាសាទតូចសង់អំពីថ្ម ភក់ ពណ៌ផ្កាឈូក ប្រកបដោយចម្លាក់យ៉ាង ថ្មីតផ្ទង់ពេញពាសទាំងតួប្រាសាទ និងមានវិភ័តក្នុងការតុបតែងហោជាង ជាចម្លាក់រឿងហើយ និងរូប ទេវតា ទ្វារបាល គួរអោយស្រឡាញ់ ។ រូបមន្តចាស់ក៏ត្រូវបានយកមកប្រើប្រាស់វិញ :១-ប្រពៃណីនិយមតបន្តសម័យកោះកែរ និងប្រែរូប។២-វិលទៅរកបុរាណហួសសម័យ និងបង្កើតថ្មីក្នុងពេលជាមួយគ្នា : យកតំរូសតវត្សទី VII - VIII មកប្រើប្រាស់វិញ ។ រចនាបថនេះជះឥទ្ធិពលខ្លាំង ដល់រចនាបថ ជាពួន ។

សិល្បករឬណ៌សាស្ត្រថ្មីតិ ស្រាវជ្រាវរក សារៈផ្ទេមនសាស្ត្រពិត តរិយាបថទន់ភ្លន់ ។ ប្រាសាទសាងតាមលំនាំប្រាសាទភ្នំ វិក្សបតាមខ្សែបន្ទាត់ផ្តេក ។

ប្រាង្គប្រាសាទដែលសាងឡើងក្នុងអំឡុងដំណាលគ្នា : ប្រាសាទបន្ទាយស្រី ៩៦៧ , ប្រាសាទស្រឡៅ , ប្រាសាទតូចមួយនៅខាងក្រោយប្រាសាទឃ្លាំងខាងជើង ។

## ៤.១៥. រចនាបថឃ្លាំង :

ក្នុងរចនាបថនេះប្រាសាទភ្នំមានទ្រង់ទ្រាយយ៉ាងពេញលេញ ដោយយកបទពិសោធន៍ ក្នុងការកសាងសាលវែងៗ នៅក្នុងសម័យមុនមកសាកល្បង ជាដំបូង ដើម្បីបង្កើតបានជាថែវ មានដំបូលជាវូតអំពីឥដ្ឋ , រួចអំពីថ្ម រត់លើព្រលាននៃខឿនព័ទ្ធ ជុំវិញប្រាសាទចំកណ្តាល ។ ផ្នែកសិល្បករឬណ៌សាស្ត្រក្នុងវិស័យបដិមាសិល្បៈ រូបបដិមា មានឥរិយាបថថ្នឹងដោយទទួលឥទ្ធិពលអំពីប្រពៃណីសម័យ

ប្រែរូប និងបន្ទាយស្រី ក៏ប៉ុន្តែមានដងខ្លួន តូរស្រឡាញ់ , ទឹកមុខស្លូតបូត ។ សំពត់ដែលមានហោជើពីរនៅលើភ្លៅទាំងពីរ គឺជាការថ្មី ប្រឌិតក្នុងរចនាបថនេះ ។

ប្រាង្គប្រាសាទដែលកសាងក្នុងអំឡុងជំណាលគ្នា : ប្រាសាទតាកែវឆ្នាំ ១០០០ , ប្រាសាទវិមានអាកាស ចុង ស.វ.ទី ១០ , ប្រាសាទឃ្លាំង , ប្រាសាទព្រះវិហារ ។

## ៤.១៦. រចនាបថបាពួន :

ប្រាសាទ-ភ្នំ នាសម័យនេះក្លាយទៅជាស្ថាបត្យកម្មគួរអោយរំភើប ។ គេអោយឈ្មោះប្រាសាទបាពួនថាជា " ប្រាសាទស្ពាន់ " នាសតវត្សទី ១៣ ដែលជាសមិទ្ធិទី ១ នៅអង្គរ ដែលមានថែវច្រើនអំពិថ្ម ព័ទ្ធជុំវិញប្រាសាទចំកណ្តាល មានកំផែង មានគោបុរៈជាច្រើន ហើយនិងវិហារ នៅតាមជ្រុង។

ផ្នែកបដិមាសិល្ប: គឺ ការស្រាវជ្រាវភាពសង្ហារ រកចម្លងជាតិនិយម អោយតម្លៃច្រើនទៅលើសំរស់ នារីភេទ ដៃជើងសមសួន ។ ចម្លាក់ក្រឡោត-ទាប ឆ្លាក់នៅលើសាច់ថ្ម ចែកជាផ្ទាំងតម្រួតលើគ្នា ដូចគ្នា និងចម្លាក់នៅអារក្សធំ បេស្សប៉ូតាមិ ដូច្នោះដែរ ។

ប្រាង្គប្រាសាទដែលកសាងឡើងក្នុងអំឡុងជំណាលគ្នា : ប្រាសាទបាពួន ១០៦០ , ប្រាសាទបេងមាលាខាង លិច , ប្រាសាទខ្នាសែនកែវ ។

## ៤.១៧. រចនាបថអង្គរវត្ត :

ប្រាសាទជាច្រើនក្នុងរចនាបថនេះ សុទ្ធសឹងតែសាងឡើងអំពិថ្មទាំងអស់ ទំហំធំ ឬ តូចយោលទៅតាមពេលវេលាខុសគ្នា ។ អាស្រ័យដោយបទពិសោធន៍ក្នុងការសាងសង់កាន់តែមានច្រើនឡើងៗ ស្ថាបនិកបានសាកល្បងសាងប្រាសាទមួយនៅផ្ទាល់លើដីសិន " ប្រាសាទបឹងមាលា " [២៨] មុននិងឈានដល់សំណង់ប្រាសាទអង្គរវត្តដែលចាត់ទុកថាជាអច្ឆរិយមួយកំពូល ក្នុងចំណោមអច្ឆរិយទាំងប្រាំពីររបស់ពិភពលោក ។ រចនាសម្ព័ន្ធនៃសំណង់ត្រូវបានប្រមូលផ្តុំពីសម័យមុនៗដើម្បីបង្កើតបានជាសំណង់ថ្មីដ៏ឯកនេះ ។ បទពិសោធន៍ទាំងឡាយនៅប្រាសាទបឹងមាលា ដូចជាការសាកល្បងសាងសង់ថែវ ការរក្សាបន្ទប់ពិធី ប្រាសាទសាជីហើយនិងប្រាសាទសង់ផ្ទាល់លើដី " ថែវ

---

២៨ - ឯកសារចាស់ [illegible] ប្រាសាទបឹងមាលា កសាងក្នុងរជ្ជកាលរបស់ [illegible] ទី ២
[illegible]

ជាប់គ្នាបែរមុខមកខាងក្នុង " ត្រូវបានយកមកអនុវត្តនៅលើប្រាសាទអង្គរវត្ត ។ អាស្រ័យដោយប្លង់មានសមតាដ៏សុក្រិត ដោយមនោរតីនៃសមាមាត្រហើយនិងសុចិភាពខាងខ្សែបន្ទាត់ ដោយការផ្ចិតផ្ចង់ក្នុងសំណង់ ប្រាសាទអង្គរវត្តត្រូវបានគេចាត់ទុកថា បានឡើងដល់កំរិតខ្ពស់ ក្នុងសិល្បៈដែលធ្វើអោយគេភ្ញាក់ផ្អើល ដោយសារទេពកោសល្យនៃស្ថាបត្យនេះ ។ ឈរនៅលើ ទស្សនៈឯកភាពមួយហើយនិងប្រពៃណី ដែលកើតចេញអំពីសមប្បមាណជាមួយនិងខ្សែមេដ្យាន័រ ដែលជាគោល " ដូចគ្នាទស្សនៈនៅអឺរ៉ុបដែរ " អង្គរវត្តជាស្នាដៃដ៏ខ្លាំងក្លា និង មានការពិចារណា ។ ចំណោទជាច្រើនបានកើតឡើងក្នុងខួរក្បាលរបស់អ្នកទិទ្ធនានាដែលបានមកដល់ទីនេះ ដោយសារប្រាសាទអង្គរវត្តបែរមុខទៅទិសខាងលិច ផ្ទុយអំពីប្រាសាទទាំងឡាយដែល ជាទម្លាប់បែរទៅទិសខាងកើតនោះ ។ ការដោះស្រាយមានពីរ :

១ - ពួកនិយមប្រពៃណី ស្រាយតាមបែបសាសនានិយម គឺ យកប្រទក្សិណ និង ប្រសវ្យៈ ដែលជាប្រពៃណីក្នុង ស្រុក ហើយនិងអាសនៈរបស់វិស្ណុ ដែលមានទីតាំងនៅខាងទិសខាងលិច ហើយ និងការប្រៀបធៀបប្រាសាទនេះទៅនិងផ្នូរខ្មោច ឮ ពាររបស់បេសកៈជនបរទេសនាសតវត្សទី ១៣ សំរាប់ធ្វើជាបង្អែក ។

២ - ពួកអ្នកប្រកាន់តាមបានលេខវិទ្យា គឺ ដោយសារទីក្រុងយសោធរៈត្រូវកសាងឡើងនៅចន្លោះស្ទឹងសៀមរាបខាងកើត ហើយនិងទំនប់ជាវាយណ៍ខាងលិច ។ ដូច្នេះប្រាសាទអង្គរវត្ត ដែលសាងនៅខាងត្បូងអតិតធានីនេះ ត្រូវតែសាងនៅផ្នែកម្ខាងនៃផ្លូវធំទៅកាន់អង្គរធំ ហើយត្រូវបែរមុខ មករកផ្លូវធំនៅទិសខាងលិច ព្រោះទិសខាងកើតមានស្ទឹងដែលអាចសំរួលដល់ការដឹកជញ្ជូនថ្មអំពីភ្នំគូលែន សំរាប់ការសាងសង់ ហើយក៏អាចជាឧបសគ្គមួយ ក្នុងសំណង់ផងដែរ ។

ក្បាច់ក្រឡោត-ទាបធំៗ ដែលសាកល្បងដំបូងនៅប្រាសាទបាគង " ៨៨១ " នោះ បានយកមកពង្រីកនៅ ទីនេះ : ចម្លាក់មានកំពស់ ២ ម៉ែត្រ ។ ទំហំទាំងអស់របស់ចម្លាក់មានចំនួន ១ គ.ម២ ។

បដិមាសិល្បៈមានសរីយាបថក្អឹង តែមានការតុបតែងលំអច្រើន ទាំងម្ចុំតសក់ និង គ្រឿងអលង្ការ ខុសៗគ្នាទាំងអស់ ក្នុងចំនួនប្រមាណ ១៧៣៧ រូប ដែលឆ្លាក់នៅក្នុងប្រាសាទអង្គរវត្តទាំងមូល " លើកលែងរូបខ្លះ ដែលយើងមិនអាចស្រាវជ្រាវបាន " ។

ប្រាង្គប្រាសាទដែលកសាងឡើងក្នុងអំឡុងដំណាលគ្នា : ចិងមាលា , បាគិល័យ ,

ប្រាសាទកីប៉ៃ , ព្រះពិធុ , ចៅសាយទេវតា , ធម្មានន្ទ , បន្ទាយសំរ៉ែ , អង្គរវត្ត , វត្តអាធ្វា , ព្រះខ័នកំពង់ស្វាយ " ផ្នែកកណ្ដាល " , ប្រាសាទស្ទូភាព , ប្រាសាទទោលសង់នៅលើជាតង ។

## ៤.១៨. រចនាបថ បាយ័ន :

រចនាបថនេះ ក៏បានលេចចេញអំពីការសាគល្បងពិសោធន៍កសាងកំពូលប្រាសាទមុខព្រហ្ម ឬ លោកេស្វរៈ ជាដំបូងនៅប្រាសាទស្ទឹង " ក្រុមព្រះខ័នកំពង់ស្វាយ "ហើយនិងប្រាសាទ ៨ ជ្រុង នៅសំបូរព្រៃគុក ។ ប្រាសាទជាច្រើនត្រូវបានកសាងឡើងចាប់តាំងពីប្លង់ស្មុគ្រស្មាញនៅរាបផ្ទាល់ដី រហូតដល់ប្លង់ប្រលងគ្រួតខឿនតាមបែបប្រាសាទ-ភ្នំ ដោយប្រើប្រាស់សម្ភារៈសំណង់អំពិថ្ម ចំរុះគុណភាព ហើយនិងការសាងសង់ដោយប្រញាប់ប្រញាល់ ខ្វះការប្រុងប្រយ័ត្នដែលជាមូលហេតុនាំអោយប្រាសាទឆាប់ជាក់បែក ទ្រុឌទ្រោម ។

ជំនឿលើលទ្ធិព្រលឹង ព្រហ្មញ្ញសាសនា និង បូជាបុគ្គល បានដើរតួជាមួយនិងវិស័យសង្គមកិច្ចដែលផ្ដល់អាទិភាពខ្លាំងដល់សុខមាលភាពប្រជាជន : សិលាចារិកប្រាសាទតាព្រំ បានប្រាប់ថាគេបាន កសាងមន្ទីរពេទ្យចំនួន ១០២ នៅតាមបណ្ដាខេត្តទាំងអស់ ។ឯសិលាចារិកប្រាសាទព្រះខ័នក៏ប្រាប់ ចំនួនសាលាសំណាក់ទាំង ១២១ ដែរ ។ ក្រៅពីនេះ សមិទ្ធិផ្នែកធារាសាស្ត្រត្រូវបានកែលំអក្នុងប្រព័ន្ធចែកចាយទឹក សំរាប់វប្បធានីនិងត្រើអាងទឹកសំរាប់បំរើសាធារណជន ។ សិលាចារិកសាយហ្វុង បានលាតត្រដាងគុណធម៌ដ៏ខ្ពស់បួយដែលជាក់ផលប្រយោជន៍ ប្រជាជនធ្ងន់ជាងផលប្រយោជន៍បុគ្គល : " ការព្រួយបារម្ភចំពោះជំងឺរបស់ប្រជាជនមានទំហំខ្លាំង ជាងជំងឺផ្ទាល់ខ្លួនពីព្រោះថា ជម្ងឺសាធារណៈនាំមកនូវការឈឺចាប់ដល់ថ្នាក់ដឹកនាំរដ្ឋទាំងឡាយ គឺមិន មែនជាការឈឺចាប់ផ្ទាល់ ខ្លួនទេ " ។

រចនាបថជាយ័នបង្ហាញអោយកុលបុត្រខ្មែរ ឃើញគំនិតពីរ ដែលជាមូលដ្ឋានសំរាប់ការឯកភាពជាតិ ដែលទើបនិងឆ្លងកុតអំពីសង្គ្រាមដ៏ធ្ងន់ធ្ងរ និង ការបះបោរក្នុងស្រុក ។ នោះគឺ ការបង្រួបបង្រួមទាំងជំនឿសាសនាទាំងរចនាសម្ព័ន្ធសង្គម ហើយនិងការយកចិត្តទុកដាក់ដល់ជីវភាពសង្គម ។ ផ្ទាំងចម្លាក់ក្រឡោត-ទាបបង្ហាញប្រាកដនិយមក្នុងសង្គម រីឯចជិមាសិល្បៈឆ្លុះបញ្ចាំងអោយឃើញអំពីការស្រាវជ្រាវរកសុក្រិតភាពក្នុងទំរង់មុខ និង ការជញ្ជឹងគិតឆ្លងតាមបញ្ញា

ចក្ខុ ដែល អាចមើលឃើញឆ្ងាយ ។

ប្រាង្គប្រាសាទដែលកសាងឡើងក្នុងអំឡុងដំណាលគ្នា : ប្រាសាទបាយ័ន ស្រះស្រង់ តាព្រុំ តាសោម បន្ទាយក្តី ព្រះខ័ន នាគព័ន្ធ បន្ទាយឆ្មា សាលាសំណាក់ មន្ទីរពេទ្យ ប្រាសាទជ្រុង ប្រាសាទប្រធាល់ ដីរ តាព្រុំបាទិ ប្រាសាទបាណន់ វត្តនគរ តាណៃ ក្រោលគោ បន្ទាយព្រៃ ប្រាសាទព្រៃ តំផែង អង្គរធំ ព្រះថ្កុល ។

# V . ទស្សនៈអំពីសំណង់ :

## ៥.១. សំណង់សំរាប់មនុស្ស និង សង្គម .

ទំនាក់ទំនងរវាងមនុស្សជាតិ និង ចក្រវាឡ រវាងបណ្តាការស្តែងឡើងនៃសម្ភារៈ និងបណ្តាទិសហើយនិងចង្កោមផ្កាយ មានកំណើតតាមលោកទស្សនៈនៃប្រទេសបូព៌ាបុរាណកាល ។ ឈរលើទស្សនៈនេះ រាល់សមាសធាតុ សត្វ រុក្ខជាតិ សិលាជាតិ លោហធាតុ ពណ៌ បណ្តាចំណែកនៃរាងខ្លួននិងចរិត គ្រប់ព្រឹត្តិការណ៍ជីវិត អាយុ ភេទ ការរំងាប់កិលេស និង ក្តីសប្បាយ ការកើតនិងសេចក្តីស្លាប់បានសាយភាយ នៅក្នុងចន្លោះបណ្តាចំណែកនានានៃ ទីកន្លែង និង ហ្វូងតារាទាំងឡាយ ហើយទាំងអស់នេះ មានទីកន្លែងរបស់វាជាក់លាក់ ហើយនិង " ពេលវេលា " ដែលទាក់ទងទៅនិងដំណើររបស់បណ្តាតារាភព [២៩] ។ មនុស្សជាតិស្ថិតជាអចិន្ត្រៃយ៍ក្រោមឥទ្ធិពលនៃកម្លាំងចក្រវាឡ ដែលធ្វើអោយកើតការ ចំរើនល្អតលាស់ ឬ ការហិនហោច អាស្រ័យដោយមនុស្សចេះរៀបចំខ្លួនឯងដើម្បីដាក់អាត្មា និង សកម្មភាពរបស់ខ្លួនអោយមានបរិនោវិកតិ ជាមួយនិង កម្លាំងទាំងនេះ ។ រីឯអង្គឯកភាពសង្គម ដូចជារដ្ឋ ទីក្រុង ប្រាង្គប្រាសាទ វត្តអារាម ដែលអាចរីកចំរើនល្អតលាស់ក៏អាស្រ័យដោយមានបរិនោវិកតិ ជាមួយ និងក្រិត្យក្រមរបស់ចក្រវាឡដែរ ។ ដូចនេះ គេនាំគ្នាស្រាវជ្រាវបង្កើតនូវ បរិនោវិកតិនេះដោយ កសាងជារដ្ឋ ទីក្រុង អាគារស្នាក់នៅ ប្រាង្គប្រាសាទ វត្តអារាមទាំងនេះឡើងដោយមានធនាសម្ព័ន្ធសង្គម យោលទៅតាមទីកន្លែង និង ពេលវេលា ដោយអនុលោមតាមក្រិត្យក្រមទាំងឡាយ របស់ធម្មជាតិ [៣០] ។

ឆ្លងតាមទស្សនៈនេះ មនុស្សធ្វើការទប់ទល់និងធម្មជាតិតាមរយៈពលកម្មរបស់ខ្លួន ដើម្បីទាញយកផល ហើយនិងរៀបចំដំណើរជីវិតរបស់ខ្លួនអោយសមស្របនិងបរិយាកាសជុំវិញ នៅក្នុងទីកន្លែង

---

២៩ - ក្រុមផ្កាយដែលរលឹករបស់ព្រាហ្មណ៍ [illegible] ដូចជា [illegible]

៣០ - ទស្សនៈរបស់អ្នកប្រាជ្ញជាតិ [illegible] : ដើម្បីជាលំអង្គរ [illegible] ទំព័រ [illegible] នេះ : រាល់អ្នកនិពន្ធ [illegible] ។

និងពេលវេលាជាកំណត់ ។ តាំងពីបុព្វកាលនោះមកម្ល៉េះថ្វីត្បិតតែមនុស្សមិនទាន់មានបច្ចេកទេសក្នុងការសាងសង់លំនៅដ្ឋាននៅឡើយ ប៉ុន្តែដោយសារមនុស្សមានវេទនាឬណីអំពីធម្មជាតិ ពុំអាចរស់នៅក្នុងទីកណ្តាលវាលដោយអាកាសធាតុរងា ដោយសត្វសាហាវយារយីផង ហើយក៏នាំគ្នាទៅរស់នៅក្នុងល្អាងភ្នំសំរាប់ជាជំរករបស់ខ្លួន ។បន្ទាប់មកមនុស្សចេះសង់ផ្ទះដោយខ្លួនឯងក្នុងបំណងទប់ទល់និងធម្មជាតិ និងបរិកាលរបស់គេ ។ នេះជាការពិតណាស់ហើយ អ្វីៗមិនអាចនៅស្ងៀមមួយកន្លែងបានឡើយ ក្នុងក្របខ័ណ្ឌខាងជំនឿទៅលើលទ្ធិព្រហ្មណ៍យើងឃើញមានការកើតចេញឡើង នូវការបូជា ចំពោះបុព្វការីជន ជំនឿលើខ្មោចបិសាច ជំនឿលើអធិធម្មជាតិ ជឿលើធម្មជាតិ ជឿលើពហុទេវៈ ហើយចុងក្រោយជឿលើឯកទេវទេវិញ ។ យើងបង្ហាញជូនការវិវត្តន៍របស់ជំនឿ ចាប់ផ្តើមចេញអំពីបណ្តាប្រភពនៃលទ្ធិព្រហ្មណ៍យ៉ាងដូច្នេះ ។ ក្នុងក្របខ័ណ្ឌសង្គម យើងឃើញមានការចាត់តាំងជារដ្ឋ ស្ថាប័នរដ្ឋ ទាំងឡាយ គ្រឹះស្ថានសាធារណៈធំៗរបស់រដ្ឋ ប្រាង្គប្រាសាទ វត្តអារាម ។ល។ នេះគឺដើម្បីរៀបចំ ទំនាក់ទំនងមួយអោយស្របទៅនិងច្បាប់ទាំងឡាយរបស់ធម្មជាតិ ច្បាប់របស់សង្គម ។ យើងសូម លើកឧទាហរណ៍ ប្រាសាទបាយ័នមួយក្នុងចំណោមវិមានប្រវត្តិសាស្ត្រ ១០៧០ ដែលចុះស្ថិតិរួចហើយ មកបង្ហាញអោយឃើញប្រយោជន៍ធំមួយក្នុងក្របខ័ណ្ឌសង្គម ។ក្រៅពីតួនាទីផ្សេងៗរបស់ប្រាសាទ នេះ " តំណាងភ្នំមាស "-" តំណាងទេវស្ថាន " ប្រាសាទបាយ័ន គឺជារូបភាពបង្រួមមួយរបស់ រាជអាណាចក្រកម្ពុជា ក្នុងជំនាន់នោះ [៣១]។

បើយើងក្រឡេកមើលប្រាសាទបាយ័នក្នុងវិស័យវប្បធម៌ យើងឃើញថា មនោគមវិជ្ជាមួយថ្មីបានបង្កប់នៅក្នុងស្នាដៃនេះ ។ ព្រះបាទជ័យវរ្ម័នទី ៧ ជាពុទ្ធសាសនិក ប្រាសាទនេះក៏បញ្ជាក់បានអំពីជំនឿមួយរបស់ប្រជាជនដែលបានក្លាយជាប្រពៃណីទៅហើយ តាំងពីភាគខាងដើមនៃគ្រិស្តសករាជមកម្ល៉េះ ។ ដូច្នេះប្រាសាទបាយ័នតំណាងអោយរដ្ឋខ្មែរផង អោយជំនឿមួយរបស់ប្រជាជន ហើយនិងសម័យកាលមួយនៃវប្បធម៌ កម្ពុជារុងរឿងផង ។ វាក្លុះបញ្ចាំងអោយឃើញសង្គមខ្មែរមួយដែលមានវប្បធម៌ខ្ពស់ ទាំងការចេះដឹង ការកំណត់ស្យាយ ការអនុវត្តន៍ និង ផ្នែកសង្គមធម៌ ។

ឡេនីនបាននិយាយថា : " វប្បធម៌គ្រឿងក្រសោបអ្វីៗដែលមានតម្លៃ ដែលមនុស្សជាតិបានបង្កើតឡើង ដោយបញ្ញាពលកម្ម និង ប្រាជ្ញាពលកម្មរបស់ខ្លួន " ។

---

៣១ . សឺដែស (Coedès): ដើមកំណើតរដ្ឋធម្មក្រុងឥណ្ឌា - ទំព័រ ១៩៧

យើងអាចចោទជាសំនួរថា តើបុព្វបុរសខ្មែរ ខំកសាងប្រាង្គប្រាសាទដ៏ស្កឹមស្កៃរាប់ពាន់នេះ ដើម្បីអ្វី ? យើងដឹងថា នៅក្នុងសង្គមមួយ វប្បធម៌តែងបង្កប់មនោគមវិជ្ជាមួយជាកំណត់ ។ ក្នុងភាគខាងដើម យើងបាននិយាយរួចមកហើយអំពីតម្លៃនៃមនោគមវិជ្ជានេះ ដទៃអំពីនេះ យើងឃើញប្រយោជន៍មួយរបស់ប្រជាជន នោះគឺការឯកភាពក្នុងជំនឿសាសនា ដែលនាំអោយមានការឯកភាពក្នុងសង្គម គ្មានការប្រេះឆាដែលកើតឡើងដោយប្រកាន់ជំនឿផ្សេងគ្នា ។ ពេលដែលសង្គម-កិច្ចរីងរៃ មនុស្សតែងពឹងផ្អែកលើវិស័យវប្បធម៌ស្មារតី ។ ផលប្រយោជន៍ដែលលេចធ្លោជាក់ស្តែងក្នុងវិស័យកសាងសំណង់ទាំងនេះ គឺបំរើសកម្មភាពសង្គម ។ ជារៀងរាល់ខែ នៃឆ្នាំ ប្រជាជនតែងប្រមូលគ្នាមកប្រារព្ធពិធីបុណ្យ ចូលឆ្នាំថ្មី រាំ រែក លេងល្បែងកំសាន្ត រុជកាំជ្រួច ផ្ការលា សំដែងសៀក នៅក្នុងពិធីលាងអង្គធំ មុខប្រាសាទប្រជល់ជើ " ចម្លាក់ក្រឡោក - នាគ ទាំងឡាយនៅប្រាសាទបាយ័ន និង ប្រាសាទប្រជល់ជើជាភស្តុតាង " ។[៣៦] សំណង់ដទៃទៀត ផ្តល់អត្ថន័យយ៉ាងគ្រប់គ្រាន់បំផុត ដោយមិនចាំបាច់ធ្វើអត្ថាធិប្បាយផងទេ ។ វាបំរើអោយផ្នែក សង្គម កិច្ចយ៉ាងជាក់ស្តែងណាស់ ។ សំណង់ទាំងនោះ គឺ មន្ទីរពេទ្យចំនួន ១០២ សាលាសំណាក់ទាំង ១២១ អាងទឹក ថ្នល់ធំៗ ហើយនិងស្ពានប្រវរទិស ដែលកសាងឡើងអំពីថ្មហើយនៅប្រើប្រាស់បាននៅឡើយរហូតមកដល់សព្វថ្ងៃនេះ " ស្ពានថ្មនៅក្នុងភូមិកំពង់ក្តី " [៣៧] ។

មនុស្សក្នុងសង្គមត្រូវស្គាល់អតីតកាលរបស់ខ្លួនអោយបានច្បាស់លាស់ ដើម្បីស្គាល់បច្ចុប្បន្នកាលរបស់ខ្លួន ។ ប្រទេសកម្ពុជាយើងបច្ចុប្បន្ននេះនៅតែបន្តកសាងផ្នែកសង្គមកិច្ច ដូចអតីតកាលដែរ ។ ហើយជាពោធនៈជាតិក្នុងអតីតកាលដែលបានកសាងប្រាសាទអំពីថ្មស្កឹមស្កៃ ជាពន្លឺអារ្យធម៌របស់ខ្លួន ប្រជាជនកម្ពុជាបច្ចុប្បន្ន ត្រូវបញ្ចេញស្នាដៃរបស់ខ្លួនឡើង ដោយកសាងរោងចក្រអោយបានស្កឹមស្កៃ ក្នុងគោលបំរើសេចក្តីត្រូវការរបស់ប្រជាជនទាំងសម្ភារៈ ទាំងស្មារតីអោយដូចជាអតីតកាលរុងរឿងឡើង ។ លោកនេះបារ៉ុ " ថ្នាក់ដឹកនាំរួមគណ្ឌ " បាននិយាយថា " រោងចក្រទាំងឡាយនាបច្ចុប្បន្ននេះ គឺជាបណ្តាប្រាង្គប្រាសាទនៃអតីតកាល " ។ ដូចនេះ ក្នុងអនាគតកាល សង្គមកម្ពុជាត្រូវមានអោយផលតែដែនផលិតកម្មមួយ ដែលបំរើអោយសង្គមគ្មានវណ្ណៈ បំពេញផលប្រយោជន៍ប្រជាជនពិតប្រាកដ ។ ម្នាក់ៗ ធ្វើពលកម្មទៅតាមសមត្ថភាព ដើម្បីទទួលផលទៅតាមកម្លាំងពលកម្ម ។

---

៣៦ - ប៊ូយ [illegible] : [illegible] - ១៩៩១ . ទំព័រ ២៧-២៨

៣៧ - [illegible] : [illegible] - ទំព័រ ២០៣, ២៥០ , ២៥១

យើងបាននិយាយខាងដើមអំពីអត្ថប្រយោជន៍នៃវិហារធំៗចំពោះមនុស្សនិងសង្គម ។ វិហារទាំងឡាយនេះ មានតម្លៃមនុស្សនិងសង្គម ។ វិហារទាំងឡាយនេះ មានតម្លៃជាប្រវត្តិសាស្ត្រ និង សិល្បៈ។ បើនិយាយអំពីសិល្បៈ គឺត្រូវនឹកដល់ស្នាដៃ មានរាប់សិប មុននឹងចាប់យកបានមុត្តលិកលក្ខណៈមួយដែលកំណត់តម្លៃពិតរបស់មនុស្ស ។ សិល្បៈគឺជាសកម្មភាពផ្នែកប្រឌិត ហើយវាមិនដាច់ចេញពីនយោបាយ និងមនោគមវិជ្ជាឡើយ ។អ្នកនិពន្ធ អារ៉ន ហ្សិស អ្នកប្រាជ្ញជាតិរុស្ស៊ី បានកត់សំគាល់ថា តួនាទីសិល្បៈនៅក្នុងសង្គមយើងបច្ចុប្បន្នគឺ សំរាប់សំដែងប្រាប់នូវសហគមន៍ មួយដែលកើតចេញអំពីការជះឥទ្ធិពលទៅវិញទៅមកនៃវណ្ណៈទាំងអស់របស់ប្រជាជាតិ ហើយនិងប្រព័ន្ធសង្គមទាំងឡាយ។ ពួកអ្នកស្រឡាញ់ម៉ាក្ស ឡេនីន មើលឃើញសិល្បៈ ថាមានតម្លៃមួយជានិច្ច ហើយប្រឹងប្រែងស្រាវជ្រាវរកការបំភ្លឺមនោគមវិជ្ជា ហើយនិងសិល្បារម្មណ៍សាស្ត្រ នៃបាតុភូតដែលបង្ហាញឡើងដោយស្ថាបនិក អ្នកនិពន្ធ នៅក្នុងការវិភាគលើរាល់ស្នាដៃសិល្បៈ។

តម្លៃ គឺជាគោលដៅ គឺ ជាសុក្រិតភាព ដែលមនុស្សស្រមៃមិនដល់ ។ នៅក្នុងសង្គមមានវណ្ណៈ សិល្បៈបង្ហាញគ្រប់ តម្លៃខាងស្មារតី ខាងសិល្បារម្មណ៍សាស្ត្រ ដែលជួយវណ្ណៈ ជាក់ស្តែងអោយដល់មនសិកានៃសហគមន៍របស់គេ និងរបស់អត្តភាពនៃផលប្រយោជន៍របស់គេ ។ វិហារប្រវត្តិសាស្ត្រ និងសិល្បៈរបស់ប្រជាជនកម្ពុជា ឆ្លុះបញ្ចាំងតថភាព តាមរយៈកែវព្រីសនៃផលប្រយោជន៍វណ្ណៈ។ តាមរយៈកែវនេះ ស្នាដៃសិល្បៈនិតខំមកស្រាយនូវផលប្រយោជន៍ ដែលក្នុងនោះ យើងមើលឃើញមុខងារនៃមនោគមវិជ្ជារបស់សិល្បៈនោះ ។

ម៉ាក្ស - ឡេនីន និយម មិនបានគ្រេចតម្លៃមនុស្សសោះឡើយ ដែលក្តាប់យកទីកន្លែងដ៏ធំជាងគេនៃជីវភាពស្មារតីផ្សេងទៀតនៅក្នុងសិល្បៈ ។ ឡេនីន និយាយថា សិល្បៈ ត្រូវជំរុញសិល្បករទាំងឡាយទៅក្នុងចំណោមមហាជន ។ យើងសង្កេតឃើញមាន មុខងារ បី សំខាន់ នៅក្នុងសិល្បៈស្ថាបត្យកម្មរបស់ប្រជាជនកម្ពុជា:

១- មុខងារសំរាប់យល់ដឹង . ២- មុខងារមនោគមវិជ្ជា . ៣- មុខងារអប់រំ ។ មុខងារទាំង នេះកើតឡើងដោយខ្លួនឯង ដោយឆ្លងតាមសកម្មភាពសិល្បារម្មណ៍សាស្ត្ររបស់វា ។

មនុស្ស និង សិល្បៈពុំអាចកាត់ផ្តាច់ពីគ្នាបានទេ ។ មិនដែលមានសិល្បៈណាដែលគ្មានមនុស្ស ឬ មិនដែលមានមនុស្សហើយគ្មានសិល្បៈនោះទេ ។ ដោយសារវិហារប្រវត្តិសាស្ត្រទាំងអស់នេះ

ប្រជាជនកម្ពុជាអាចស្គាល់ខ្លួនឯង ហើយអាចអោយពិភពលោកស្គាល់កាន់តែប្រសើរឡើងថែមទៀត ។ វាជាបញ្ហាជាយមួយនៃការផ្លាស់ប្តូរមិនដាច់ជាមួយនិងអ្វីដែលនៅជុំវិញខ្លួន ។ ជីវភាពមួយ ឬ ប្រទេសមួយដែលមិនដើរទៅរកសិល្បៈ និងត្រូវតំរាមកំហែងដោយការតប់ប្រមល់ខាងសតិអារម្មណ៍ដ៏សម្ងាត់ និងដោយវិបត្តិផ្លូវចិត្ត ។

គ្មានអ្វីប្រសើរជាងស្នាដៃសិល្បៈ ដែលអាចវាស់វែងមិទ្ទភាពនៃគំនិតហើយនិងជីវិតរបស់មនុស្សទេ ។ ដូចនេះនៅចំពោះមុខប្រាង្គប្រាសាទដែលជាស្នាដៃសិល្បៈ យើងកើតគំនិតមួយ កើតការរំភើបមួយ ។ ឡើករប៉ើស្រែកឡើងដោយរំភើបនៅចំពោះមុខផ្ទាំងគំនូររបស់រ៉ាហ្វាអែល : " ខ្ញុំក៏ជាសិល្បករ ដែរ "[៣៤] ខ្ញុំជាសិល្បករដែរ " មនុស្សម្នាក់ស្រែកឡើងក្រោមសំរស់ដ៏ខ្លាំងរបស់សិល្បៈ ។

## ៥.២ អស្ចារ្យ! ក្នុងសិល្បៈស្ថាបត្យកម្មកម្ពុជា

" អស្ចារ្យ " ជាពាក្យដែលមនុស្សគ្រប់រូបតែងភ្ញាក់ឆ្ងាត់ដោយក្តីរំភើបខ្លាំង ភ្លេចខ្លួននៅចំពោះមុខស្នាដៃ វប្បធម៌សិល្បៈរបស់មនុស្ស ទោះជាជនជាតិណាក៏ដោយ អាស្រ័យដោយសិល្បារម្មណ៍សាស្ត្រ នៃស្នាដៃនោះបានជះឥទ្ធិពលមកលើមនោសញ្ចេតនារបស់ទស្សនិកជន ។ តាំងតែពីចុងសតវត្សទី ១៣ នោះមកម្លេះ ជនជាតិបរទេសបានចាប់ភ្ញាក់ផ្អើលនិងសំរស់របស់ប្រាង្គប្រាសាទខ្មែរ ជាដូច " ប្រាសាទមាស " ដែលមន្ត្រីចិនគឺជីវតាក្វាន់ អ្នកស្គាល់បានរៀបរាប់ទុកពីសម័យអង្គរកាល ។ ជាបន្តបន្ទាប់ វិមានប្រវត្តិសាស្ត្រនៅអង្គរត្រូវបានពួកបេសកជន និង ពាណិជ្ជករ ប្រទេសខាងលិចកត់សំគាល់ជាច្រើនលើកច្រើនគ្រាតាំងពីសតវត្សទី ១៦ ហើយនាពាក់កណ្តាលសតវត្សទី ១៩ ពួកអ្នកប្រាជ្ញ និង បុរាណវិទូជាច្រើនបានចាប់ភ្ញាក់កាន់តែខ្លាំងមកលើមរតកវប្បធម៌របស់ប្រជាជនកម្ពុជា ពិសេសក្រុមប្រាសាទនៅអង្គរ ។ ដោយសារការធ្វើអត្ថាធិប្បាយដោយរំភើបរបស់អ្នកធម្មជាតិនិយមឈ្មោះ ហង្សី មូហូ នៅអង្គរវត្តនាឆ្នាំ ១៨៦០ ជនបរទេសជាច្រើនបានមកស្វែងយល់អំពីវប្បធម៌ខ្មែរ ហើយពួកគេបានយកស្នាដៃសិល្បៈខ្លះរបស់ខ្មែរ ទៅធ្វើពិពណ៌មួយនៅបរទេសនាឆ្នាំ ១៨៧៨ ។[៣៥]

អាស្រ័យដោយស្នាដៃដែលស្ទើរតែមិនអាចជឿបានលើកម្លាំងពលកម្មមនុស្ស ប្រជាជនកម្ពុជាខ្លួនឯងខ្លះ នៅតែជឿតាមរឿងព្រេងនិទានថា វិស្សកម្មបានចុះមកកសាងប្រាសាទអង្គរវត្តថ្វាយព្រះកេតុមាលា ។ ថ្នាក់ដឹកនាំរដ្ឋប្រទេសកម្ពុជាយើងបច្ចុប្បន្នក៏ធ្លាប់មានប្រសាសន៍ថា

---

34 - AVNER ZISS : Element d 'esthetique Marxiste pp 50 - 55
អាវណឺ ហ្ស៊ីស: សិល្បវិជ្ជាម៉ាក្សនិយម ទំព័រ ៥០ - ៥៥
(៣៥) ម៉ូរីស ផ្លែរ្យ ប្រាសាទរបស់ក្រុមប្រាសាទអង្គរ ទំព័រ ១៥

"អស្ចារ្យ" ចំពោះវិហារប្រវត្តិសាស្ត្រនៅអង្គរដែរ ។ វេទយិទភាពជំរៅនៃចិត្តរំភើបដែលផ្តិតទៅលើអច្ឆរិយវត្ថុនៃមនុស្សជាតិ មិនអាចទប់សំរែកទាំងមិនដឹងខ្លួន បន្ទាប់ពីមានញាណកម្ម[៣១] ទៅលើបរិភាពរបស់បុគ្គលនោះ ។ នៅចំពោះបុរាណវិហារវប្បធម៌ ពិសេសប្រាសាទអង្គរវត្ត និង បាយ័ន ទស្សនិកជនម្នាក់ៗមានអារម្មណ៍ដោយឡែក ខ្លះអាចសរសេរជាកំណាព្យ ខ្លះស្រែកថា អស្ចារ្យ ខ្លះស្ងៀមស្ងាត់និយាយមិនកើត ខ្លះថា សូមអោយផេះនៃអដ្ឋិរបស់ខ្លួនជ្រាបចូលទៅក្នុងសាច់ថ្ម នៅអង្គរ ... តើជំរៅនៃអស្ចារ្យ នេះមានទម្ងន់ប៉ុណ្ណា ? យើងសូមលើកយកឃ្លាខ្លះៗរបស់ពួកអ្នកប្រាជ្ញ ល្បីៗ មកជំរាបជូន ។ លោកខូដាដឺឡាគ្រេ មានអារម្មណ៍យ៉ាងដូច្នេះ : ១ - "ប្រាសាទបាយ័ន គឺជាអច្ឆរិយៈខាងស្ថាបត្យកម្មលេខ ១ ដែលមើលតែមួយភ្លែតហាក់ដូចជាអស្ចារ្យ " ២ - "បាយ័នសំណង់នៃទេវតា " ៣ - "បាយ័ន គឺអស្ចារ្យជាងគេទាំងអស់ក្នុងចំណោមប្រាសាទទាំងឡាយរបស់ខ្មែរ " ។ លោក ទីស្សង់ឡេ និយាយថា " បាយ័នជាសំណុំតែមួយគត់នៅក្នុងប្រភេទរបស់ប្រាសាទនេះ " ។ លោក ហ្វូកណិរោ ជាស្ថាបត្យករ និយាយថា : " បាយ័នជាវិមានមហាអស្ចារ្យ " ។

លោក ព្យាឡូទិ គាត់សរសេរថា " ខ្ញុំដើរទៅមើលមុខព្រហ្មទាំងឡាយ ប៉ុំព័ទ្ធដោយស្លែពណ៌បៃតង ហើយពេលនោះខ្ញុំញាប់ញ័រដោយការភ័យខ្លាចមិនដឹងមកពីណាដោយបានឃើញភាពញញឹមហ្នឹង ផ្តល់មួយដ៏ធំ ដែលធ្លាក់មកលើខ្ញុំ ... ហើយភ្លាមឯណោះនោះញញឹមមួយផ្សេងទៀត ហើយនៅលើក្លោងទ្វាររបស់កំពែង... ហើយបន្ទាប់មកទៀត ញញឹមបី ញញឹមប្រាំ ញញឹមដប់ ហើយនៅទីណាក៏មានញញឹមដែរ រីឯខ្លួនខ្ញុំត្រូវបានមុខញញឹមទាំងនោះឃ្លាំមើលគ្រប់ជំហាន " ។ អ្នកកវីដដែលនេះ ក៏បានចាប់ភ្លឹកចំពោះព្រៃព្រឹក្សាដែលប៉ុំព័ទ្ធប្រាសាទបាយ័ននេះ ហើយលោកបានសរសេរទៀតថា " គេត្រូវតែប្រើឈើត្រង់វែកដើមអញ្ចាញ និង វល្លិដ៏ច្រើនសន្ធឹកដើម្បីបើកផ្លូវទៅកាន់ប្រាសាទនេះ ។ ព្រៃព្រឹក្សាបានរួបរឹតយ៉ាងក្រាស់ឃ្មឹក ធ្វើអោយបាយ័នថប់ដង្ហើម ហើយទំពាក់ទេចបាយ័ន ។ ដើមជ្រៃធំៗដែលបញ្ឈប់សកម្មភាពបំផ្លាញរបស់វាហើយនោះស្ថិតនៅក្នុងប្រាសាទនេះគ្រប់ទិសទី រហូតដល់កំពូលបាយ័ន ។ នេះជាទ្វារនានារបស់ប្រាសាទ ។ ឫសឈើទាំងឡាយ ហាក់ដូចជាសក់នោះបានគ្របលើមុខព្រហ្មទាំងឡាយរាប់ពាន់សរសៃ ... " ។ លោកហង់រីប៉ាកម៉ង់ថេ គាត់អាចបន្ថយវេទនាមួយរំពេចបានខ្លះ ដោយសារគាត់បានស្ថិតនៅប្រចាំថ្ងៃជាមួយ និងប្រាសាទខ្មែរទាំងឡាយ ហើយគាត់សរសេរថា " មុននេះប្រាសាទបាយ័ន គឺជាឡាប៊ីរីង

---

[៣១] - ទទួលអារម្មណ៍

មិនអាចយល់បានហើយគ្រោះថ្នាក់ផង ក៏ប៉ុន្តែផ្ទុយទៅវិញ មានអានុភាពធ្វើអោយរំភើបចិត្ត ហើយនិងអផ្សែត អណ្តូងនិយមយ៉ាងអស្ចារ្យ "។ លោកហង់រី ម៉ាសាល់ បានមានប្រសាសន៍ថា "អាគារ[៣៧] ច្រឡូកច្រឡំធំទ្បែកណាស់ វាបង្ហាញទ្រង់ទ្រាយផ្ទាំងថ្មមួយដែលគេដាប់ភ្ជាក់ ហើយអផ្សែតឡើងដូចជា ភ្នំខ្ពស់ ស្រួចដែលមនុស្សធ្វើ មនុស្សជាប់ ... ជាយ័ន ... គឺជាប្រាសាទធំទ្បែកណាស់ ។ ក្នុងម៉ោងណាមួយនៃទិវាដែលយើងដើរកំសាន្តនៅទីនោះ ឬ ប្រសិនបើយើងមានសំណាងបាននៅទីនោះ ចំពេលព្រះច័ន្ទពេញបូណ៌មី នៃយប់មានពន្លឺថ្លៃ យើងមានអារម្មណ៍ទាសញ្ញេតនា បានទស្សនាប្រាសាទមួយនេះ ដែលជារបស់ពិភពមួយផ្សេងទៀត : ប្រាសាទដែលសង់ឡើងដោយបុគ្គលធំទ្បែកផ្សេងពីយើង ដែលមានទស្សនៈប្លែកអំពីយើង ។ គេអាចនឹកស្មានថា គេបានត្រឡប់ទៅរកពេលវេលាដែលមានតែក្នុងរឿនទាតនៃរឿងព្រេង ក្នុងពេលដែលព្រះឥន្ទបានបញ្ជាអោយវិស្វករម៉ន កសាងវាំងមួយទៅតាមគំរូវាំងឋានសួគ៌របស់ព្រះឥន្ទ ដើម្បីអោយកូន របស់គាត់ដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយ បុត្រីស្តេចនាគ "។ កញ្ញាម៉ាដឺឡែនហ្សិតូ គាត់មើលឃើញអង្គរវត្តថាជា "សំណង់ពិសេសនៃពាក់កណ្តាលសតវត្សទីទី ១២ ។ គ្មានប្រាសាទណាមួយផ្សេងទៀត ដែលមានគត្តិនាមមួយយ៉ាងនេះ ។ កិត្តិសព្ទរបស់អង្គរវត្ត ពុំដែល ស្គាល់ការពន្លេចណាមួយទាល់តែសោះ " ។ រីឯសោភ័ណភាពរបស់ ប្រាសាទអង្គរ ធ្វើអោយអ្នកនិពន្ធដដែលនេះ កត់សំគាល់ថា " បណ្តាខ្សែបន្ទាត់ " ក្នុងស្ថាបត្យកម្ម " មានសាមគ្គីភាពជាមួយនឹងបរិយាកាសដ៏ស្មុគ្រស្មាញ ។ រៀងរាល់ម៉ោងនៃ ទិវា ធ្វើអោយប្រែក្លាយពណ៌ទាំង ឡាយរបស់ថ្មប្រាសាទ ។ ថ្មមានពណ៌ប្រផេះនៅពេលព្រឹក ពន្លឺថ្ងៃត្រង់បានលេបពណ៌សារៀរ របស់ក្បាច់ក្បាក់ ។ ពន្លឺពណ៌ទាសនាអស្តង្គតកាលធ្វើអោយអង្គរវត្តឡើងពណ៌សុវណ្ណ ។ ពេលរាត្រី ប្រាសាទនេះជាអាករមួយងងឹត គ្របដណ្តប់ដោយស្រមោលខ្ពស់ៗ នៃប្រាសាទកំពូល៥ "[៣៨] ។ នាឆ្នាំ ១៥៣០ ស្ត្រីជាតិភាពើកាំងម្នាក់បានធ្វើសំណូមពរថា " សូមអោយកំទេចផេះផង់នៃកញ្ចិតាត់ ត្រូវបានគេរោយពាសពេញនៅលើផ្លូវថ្នល់ធំទៅកាន់អង្គរវត្ត " ។ នៅក្នុងការរំភើបប្លុសប្រមោក របស់នាងចំពោះអង្គរ កាយវិការនេះជានិមិត្តរូបនៃកម្លាំងដ៏អស្ចារ្យនៃមរតកអតីតកាល " អង្គរវត្ត " ។

ប្រាង្គប្រាសាទអង្គរវត្ត និងក្រុមធនាគារជាយ៉ាន ដែលបានទទួលតម្លៃសាកលអស្ចារ្យមួយនៃបណ្តាអច្ឆរិយៈក្នុងលោក ដែលជាសម្បត្តិរបស់មនុស្សជាតិ តំណាងអោយព្រលឹងនៃការ

---

៣៧ . អាគារ = ចេតិយ ... ទីនេះ ... ប្រាសាទបរាងប្រូម ។

៣៨ ម៉ាដឺឡែន ហ្សិតូ : អង្គរ . ប្រជាជនមួយ និង សិល្បៈ ... ទំព័រ ១៦៣, ១៨០ .

គតិយ៉ាងស៊ីជម្រៅ នៃកម្លាំងពលកម្មរបស់ប្រជាជនដែលបានឯកភាពទៅលើមនោគមវិជ្ជាមួយ នៃសម័យកាលជាក់ស្តែងរបស់ ចក្រភពកម្ពុជទេស ។ លេនីន បានប្រសាសន៍ថា " វប្បធម៌សិល្បៈ មិនចុះមកពីលើមេឃទេ ... " " ក្នុងរាល់វប្បធម៌ជាតិមានធាតុវប្បធម៌ប្រជាធិបតេយ្យ និងសង្គមនិយមទោះបីជាធាតុនោះមិនទាន់រីកធំធេង ក៏ដោយពីព្រោះរាល់ប្រជាជាតិទាំងអស់មានមហាជនពលករដែលត្រូវគេជិះជាន់ ហើយល័ក្ខខ័ណ្ឌជីវភាពរបស់គេ បង្កើតឡើងនូវមនោគមវិជ្ជាប្រជាធិបតេយ្យ និងសង្គមនិយមជាមិនខាន " " ធ្វើអោយសិល្បៈខិតមកជិតប្រជាជន និងធ្វើអោយមនុស្សខិតមកជិតសិល្បៈ ... " ។

តើនរណាទៅបង្កើតអង្គរ ? យោងតាមប្រសាសន៍ខាងលើ មហាជនកម្ពុជាបានបង្កើតស្នាដៃ សិល្បៈដែលមិនមែនសំរាប់មនុស្សមួយក្រុមតូច តែប្រជាជនទាំងអស់ ទទួលស្គាល់ថាជាមរតករបស់ខ្លួន ផ្ទាល់ដែលកើតឡើងអំពីកំលាំងសុខដែលសន្សំពីសោកនាដ៏យ៉ាងតិចណាស់ ក៏ ៧០០ ឆ្នាំដែរ ទុននិងមានដល់សម័យដ៏រុងរឿង ។ ពិតណាស់ហើយ រាល់សមិទ្ធិផលនៃវប្បធម៌ វាតែងតែចេញអំពី កំលាំងពីរ : ប្រាជ្ញា និង កំលាំងកាយ ។ យើងត្រូវទទួលស្គាល់ថា នៅក្នុងពង្សាវតារសម័យរបស់កម្ពុជទេស វប្បធម៌មានប្រភពពីរ មួយរស់នៅក្នុងវាំង អ្នកប្រាជ្ញ អ្នកអក្សរសាស្ត្រ មួយទៀតរស់នៅក្នុងរង្វង់ប្រជាជន ។ ចន្លោះវប្បធម៌ទាំងពីរ តែងរស់នៅជាមួយគ្នាជានិច្ច ប៉ុន្តែ យើងឃើញថាវប្បធម៌ថ្នាក់លើបានឡើងដល់កំពូលខ្ពស់ អាស្រ័យដោយមានអ្នកចេះដឹងជាអ្នក ជួយគ្រោងជ្រែង ។ លេនីន បានប្រសាសន៍ថា " បើកាលណាបញ្ញាជនមិនទាក់ទងនឹងវណ្ណៈណាមួយទេ នោះវាមានតម្លៃស្មើនឹងសូន្យ "[៣៩] ។

នរណាមិនស្ងើចសរសើរទៅចំពោះមុខប្រាសាទអង្គរវត្ត ឬបាយ័ន ? អង្គរត្រង់ណាទៅ ? អង្គរវត្ត ប្រសូត្រចេញ អំពីបាតុភូតកម្ម នៃប្រជាពលករកម្ពុជា ដែលបង្ហាញរូបភាពនៃសិល្បៈរបស់ជាតិមួយ ដែលខុសប្លែកអំពីវប្បធម៌ឥណ្ឌា ដែលគេតែងនិយាយថា " ខ្មែរទទួលវប្បធម៌ " អំពីប្រទេសនេះ ។ កំពូល ៥ តំណាងអោយរូបភាពជាតិកម្ពុជាមួយដ៏ជាក់ច្បាស់ណាស់ ព្រោះគេពុំដែលឃើញមានប្រាសាទណាមួយមានប្លង់របៀបអង្គរវត្តនៅប្រទេសឥណ្ឌាទេ ។ រីឯភាសារបស់ជាតិខ្មែរមួយក៏មានរូបរាងតាំងពីឆ្នាំ ៦០៩ គ.ស. នោះមកម្ល៉េះ នៅលើផ្ទាំងសិលា ឬ តាមមេទ្វារ របស់ប្រាង្គប្រាសាទ ដែលឆ្លើយតបទៅនឹងសេចក្តីត្រូវការក្នុងជីវភាព និងផ្តល់លទ្ធភាពដ៏ទូលាយចំពោះប្រជាជន ដើម្បីរ

---

៣៩ វប្បធម៌ : [illegible] ទំព័រ [illegible]

ចំណែកក្នុងការពង្រីកវប្បធម៌កម្ពុជាជាទូទៅ។ យ៉ាងណាក៏ដោយចុះវប្បធម៌ជាតិពង្រីកខ្លួនមិនត្រឹមតែដោយសារប្រភពរបស់ខ្លួនមួយគត់តែប៉ុណ្ណោះទេ ក៏ប៉ុន្តែត្រូវពឹងលើទ្រព្យសម្បត្តិ ផ្លូវស្ពានតិ ប្រទេសជិតខាង ឬ ឆ្ងាយៗ ដទៃទៀតផងដែរ ។

ឈរលើទស្សនៈខាងលើនេះ យើងឃើញថា នាសម័យ គូលែន នាដើមសតវត្សទី ៩ គូលែន ជាលក្ខណៈរួមគ្នានៃវប្បធម៌អន្តរជាតិ ហើយធ្វើអោយលេចឡើង នូវរូបភាពនៃវប្បធម៌ជាតិកម្ពុជាច្រើនបែបយ៉ាងណាស់ ។ អស្ចារ្យទំនងជានិមិត្តរូបនៃព្រលឹងពលកម្ម ប្រាជ្ញាញាណ និង ទេពកោសល្យច្នៃប្រឌិតដោយព្យាយាម ហើយព្រលឹងនៃការរាប់អាន ការទាក់ទងគ្នា និង ជះឥទ្ធិពលទៅវិញទៅមកយ៉ាងជិតស្និទ្ធរវាងជាតិ និងប្រជាជាតិដែលបង្កើតបានជាគំនិតសន្តិភាព មនុស្សធម៌ វឌ្ឍនភាពសង្គមគស្ម័ និងភាពត្រេកត្រអាលក្នុងសិល្បៈ ចំបើកការហោរប្ញណ៍ និង សិល្បៈ ដើម្បីសិល្បៈ ។ ពេលមានសង្គ្រាមសិល្បៈផ្អាកដំណើរ ។ " អស្ចារ្យ " ព្រោះនាបង្ហើបសម័យនៅកម្ពុជា មនុស្សពុំទាន់បានស្គាល់វិទ្យាសាស្ត្រដូចបច្ចុប្បន្ននេះទេ ក៏ប៉ុន្តែប្រជាជនកម្ពុជា ប្រើប្រាស់ប្រាជ្ញាដ៏ប៉ិនប្រសប់របស់ខ្លួន ដើម្បីអារកាត់ផ្ទាំងថ្ម ជាផ្ទាំងៗ ទម្ងន់រាប់តោន អំពីភ្នំគូលែន សំរាប់កសាងនាប្រាសាទដ៏ល្បីល្បាញ ។ អាស្រ័យដោយទេពកោសល្យដ៏ខ្ពស់ ដែលស្ទើរតែគ្មានតិកតាងនាំអោយគេនឹកស្មានថា មនុស្សពុំអាចលើកថ្មទម្ងន់រាប់តោនឡើងដល់កំពូលប្រាសាទដែលមានកំពស់ ៦៥ ម៉ែត្រអំពីផ្ទៃដីបាន ហើយត្រឡប់ជាមិនិច្ឆ័យថា ចាស់ៗជំនាន់មុនគេៈ " វិធីស្លឹក " សំរាប់កសាងប្រាសាទទៅវិញ ។ បើយើងលើកឡើងអំពីស្ថាបត្យកម្ម ប្រជាជនកម្ពុជាមានចំណេះដឹងខ្ពស់ ទាំងសំណង់ ទាំងសិល្បាវប្បណ៍សាស្ត្រ ៖ អាគារទាំងមូលរបស់ប្រាសាទអង្គរ មានសមតាជាមួយខ្សែបន្ទាត់ បញ្ឈរ និងផ្តេក ហើយមានតម្លៃសាកល [៤០] ឈរនៅលើភាពរួបរួម ដែលកើតចេញអំពីសមប្បហារណជាមួយខ្សែបន្ទាត់ធរណ៊ាមិ ។ ភាពអស្ចារ្យវាមានកាន់តែខ្ពស់មួយបែបទៀត ប្រសិនបើទស្សនិកជនប្រើមនោសញ្ចេតនាអណ្តែតអណ្តូងត្រវែងខ្លួនអោយផុតអំពីតថៈភាព ។ ពួកអណ្តែតអណ្តូងនិយម ពួកនិមិត្តរូបនិយម ដែលបានស្គាល់បណ្តាលោកទស្សនៈចាស់ នៃអាស៊ីអាគ្នេយ៍ អាស៊ីកណ្តាល និង អាមេរិកឡាទីន មើលឃើញប្រាសាទអង្គរ ប្រាសាទបាយ័ន ប្រាសាទប្រែរូប នាគព័ន្ធ ។ល។ មានភាពអស្ចារ្យដោយឡែកអំពីប្រាសាទ បូរ៉ូប៊ូឌួ នៅឥណ្ឌូនេស៊ី អំពី ប៉ីម ម៉ិកតូវ៉ាន់ នៅបាប៊ីឡូន អំពីប្រាសាទទាំងឡាយនៃអារ្យធម៌ម៉ាយ៉ា នៅអាមេរិកកណ្តាល ដែលស្ថិតនៅក្នុងភាពរួមមួយ

---

៤០ - ទស្សនៈនេះ មានរូបគំនូរទាំងអស់ទាំងឡាយនៃទស្សនៈ ឡាមីន ( មើលលោកខាងលើ

នៃទស្សនៈ ភ្នំព្រះសុមេរុ ។ នៅព្រលានប្រជល់ដំរី អ្វីៗដែលគេពិបាកយល់នៅប្រាសាទប្ញីប៊ុខ នៅប្រាសាទបាយ័ន នៅប្រាសាទវិមានអាកាស នៅប្រាសាទអង្គរវត្តនោះ អាចបកស្រាយយ៉ាងងាយយល់បំផុតនៅទីនេះ : ពិភពទាំងឡាយដែលមនុស្សមិនដែលឃើញ ហើយមានតែក្នុងមនោគតិ ស្ថាបនិក សិល្បករ បានបំបាំងនៅពីក្រោយផ្ទាំងថ្ម បៀមរាប់ពិភព ក្រោមសមុទ្រ និង ក្រោមដី ឯជីវភូទាំងឡាយដែលមនុស្សស្គាល់ គឺឆ្លាក់នៅលើផ្ទៃថ្មខាងក្រៅ ។ មកដល់ត្រង់នេះយើងអាចនិយាយបានថា ប្រជាជនកម្ពុជាឈរលើទស្សនៈ ប្រាកដភាពពិតប្រាកដណាស់ ជឿលើអ្វីដែលជាជីវិតនៅជុំវិញខ្លួន ព្រោះការងារសិល្បៈគឺ ធ្វើជាប្ញូយមនុស្ស ធ្វើអោយប្រជាពលករគ្រប់រូបអាចមើល អាចយល់បាន ។ មនុស្សខ្មែរជាមនុស្សលោកិយសច្ចៈ ទោះបីជាកសាងប្រាសាទសំរាប់ដំកល់លិង្គរាជ " ឧទាហរណ៍ រាជេន្ទ្រភទ្រេស្វរៈ ក៏ដោយចុះ " ក៏យើងឃើញថា មានតួអង្គរាជេន្ទ្រវម៌ន ដែលជាមនុស្សនៅក្នុងនោះដែរ ។ អ្វីៗដែលជាអាទិទេព ខ្មែរធ្វើអោយមកជាមនុស្សទាំងអស់ ឧទាហរណ៍ជាក់ស្តែង តួអង្គព្រះរាមក្នុងរឿងរាមកេរ្តិ៍ ឬ ក្នុងឃ្លាប្ញូយរបស់សិលាចារឹកបានសរសេរយ៉ាងដូច្នេះថា " ហរិ កម្ពុ. ជេន្ទ្រ " ប្រែមកថា " ហរិ " : ដែលជានរបតីនៃទឹកដីកម្ពុជា មិនមែនជា " ហរិ " នៃប្រជាជនដទៃណាក្រៅពី កម្ពុជាឡើយ ។ ចំពោះអ្នកសិក្សាលើអ្វីដែលហៅថា " ព្រលឹង " នៃអារ្យធម៌កម្ពុជានោះ " អស្ចារ្យ " ស្ថិតនៅលើកំពូលទាំង ៥ របស់ ប្រាសាទទាំងឡាយ ដូចជា ប្រែរូប មេបុណ្យខាងកើតអង្គរវត្ត ។ល។ កំពូលទាំង ៥នេះ ទំនងជា តំណាងអោយ ១ - ប្រាជ្ញាញាណ ២ - ការច្នៃប្រឌិត ៣ - មេកោសល្យ ៤ - ឧស្សាហ៍ព្យាយាមក្នុងពលកម្ម ៥ - ព្រលឹងនៃការរាប់អាន និង ការផ្សះផ្សាជាតុក្កតក្នុងសង្គម ។ ព្រលឹងទាំង ៥ នេះ ស្ថិតនៅជានិច្ច ក្នុងសន្តានចិត្តខ្មែរតាំងពីបុរាណកាលរហូតមកដល់បច្ចុប្បន្ន ។ លោក ប៊ុន សែន ក៏ធ្លាប់មានប្រសាសន៍ថា សិល្បៈវប្បធម៌ ជាស៊ីម៉ង់រស់ សំរាប់ផ្សារភាពប្រេះឆារជាប្រវត្តិសាស្ត្រ ... ទោះសង្គមបរិវត្តន៍ដល់ណា ក៏មនុស្សក្នុងសង្គមនោះតែងមានការទំនាក់ទំនងនិងគ្នាជានិច្ច ហើយទំនាស់តែងកើតឡើង ។ អ្វីដែលចាស់ហួសសម័យតែងត្រូវបានជំនួសដោយអ្វីដែលថ្មីល្អជាងមុន ។ ការប្រេះឆារតែងអន្ទោលតាមជានិច្ច ប៉ុន្តែការប្រេះឆារជាជាតុក្កតបណ្តោះអាសន្នប៉ុណ្ណោះ ។

យោងតាមទស្សនៈខាងលើ ប្រាសាទទាំងឡាយរបស់ កម្ពុជា ពិសេស អង្គរវត្ត និង បាយ័ន ជានិមិត្តរូបនៃការរួបរួមនៃប្រជាជាតិក្នុងស្រុក ដូចជាំនិង ទ្រឹស្តីនយោបាយនៃសម័យកាល ។ ពួកពុទ្ធ

និយមមើលឃើញអង្គរវត្ត ឬ បាយ័ន តាមទស្សនៈដោយឡែក ពួកព្រាហ្មនិយមមើលឃើញមួយបែបផ្សេង ពួកលោកិយសច្ចៈអោយតម្លៃទៅលើកម្លាំងរបស់មនុស្ស ។ ដូចនេះប្រាសាទ ខាងលើនរណាក៏អាចទទួលយកបានដែរ ។ នេះជាទស្សនៈឆ្លុះឆ្លងភាពប្រេះឆារ ដែលកើតមានក្នុងសង្គមជាតិតាំងពីចុងសម័យ នគរភ្នំនោះមកម្លេះ ។

ជាសរុបមក យើងឃើញថា អស់លោក អ្នកប្រាជ្ញ និង អ្នកសិក្សាស្រាវជ្រាវមុនៗនេះ ដូចជា ព្រឹលុស្គី ប៉ូលមុស ហ្គោល្លូប៊ូវ ស៊ីដែស លោកបានអោយតម្លៃទៅលើលោកទស្សនៈ ដែលយល់ថា ភ្នំព្រះសុមេរុ ជាស្នូលរបស់ទ្វីបទាំង ៤ ហើយភ្នំនេះមានកំពូល ៥ ។ ដូច្នេះប្រាសាទកំពូល ៥ តំណាងអោយភ្នំ សុមេរុរាជនេះឯង ។ ប៉ុន្តែ តាមទស្សនៈរបស់យើង របស់ខ្មែរតែម្តងដែលជាអ្នកប្រាកដនិយម ស្រឡាញ់ធម្មជាតិ យកទស្សនៈមនុស្សជាធំនោះ កំពូលទាំង ៥ នេះមានតម្លៃដូចធំណុចទាំង ៥ ពោល ខាងលើ ឬ តំណាងអោយម្រាមដៃទាំង៥ ដែលជាប្រភពនៃការទ្រទ្រង់អត្ថិភាពប្រចាំថ្ងៃរបស់មនុស្ស។ ជាទៅអំពីនេះ កំពូល ៥ ទំនងជាតំណាងអោយសីលធម៌ ៥ យ៉ាងរបស់ប្រជាជនកម្ពុជា សំរាប់នាំជីវិតប្រចាំថ្ងៃទៅកាន់សន្តិភាព និង សុភមង្គលរបស់បុគ្គលម្នាក់ៗ ។[៦៧]

## អស្ចារ្យ ! ភ្លូខសរន្តេហាចិចី .

យើងសូមលើកយកតែប្រាសាទ អង្គរវត្ត ឬ បាយ័ន ដែលជាសម័យរុងរឿងមកបង្ហាញជូន ក្នុងចំណោងចំនុសពោយហើយ ព្វីដែលស្ថាបនិក-សិល្បករ ធ្វើអោយទស្សនិកជនដែលបានមកដល់ មានតការង្យចរបីថ្ងៃថ្លានេះ ចង់ពិង តង់យល់អំពីគំនិតដែលបង្កប់នៅពីក្រោយស្នាដៃប្រកប ដោយទេពកោសល្យខ្ពស់ និងសិល្បៈរចនាសាស្ត្រនេះ ។ ជនណាក៏ដោយ ពិនថា ប្រជាជនកម្ពុជា ឬ បរទេសទេ ពេលដែលមកដល់ចំពោះអង្គរវត្ត ជំហ្វងបង្អស់តែងរងចាំជល់តួរវ្លេសតួជាធ្ងវផ្លូវថ្មលធំ ដែលបាក់ បែកដោយពេលវេលា ឬក៏ដោយមនុស្សបំផ្លាញដោយចេតនា ឬ អចេតនា ។ នោះគិតសំរែកតោថ្ម ឬ នាគថ្ម ដែលអង្វរកាសុំកុំអោយបុគ្គលណាក៏ដោយលោភលោវ ឬកាប់គាស់យកសំរែងលើខ្លួន ឬ កន្ទុយ របស់ខ្លួនតទៅទៀត ។ នោះគឺជាសំរែកសិល្បករដែលប្រាថ្នាចង់អោយស្នាដៃនេះមានជីវិតរាប់កប្ប កល្បតទៅមុខទៀត ដើម្បីជាអ្នកឈើងនៃតម្រាងរាជតក្កែ ដែលឧទ្ទិសចំពោះសិល្បៈរបស់ប្រជាជន ។ ពើលមកត្រង់នេះឃើញពោយរពើងទ្រូងយ៉ាងសង្ហារ ផោយភ្នែកទៅត្រង់នោះឃើញនាគមេក

---

៦៧ - ចំណុចនេះគ្រាន់តែជាការយល់ឃើញរបស់អ្នកនិពន្ធផ្ទាល់ខ្លួនតែប៉ុណ្ណោះ នៅពេលក្រោយទៀត ។

សព្វថ្ងៃ ឯនាយឯណោះ នាគបើកមាត់ទទឹមគ្នា តំរៀបគ្នាតាមបណ្តោយផ្លូវធំទទឹង ១២ម. ក្រាលដោយថ្មបាយក្រៀម និង ថ្មភក់ភ្ជង់កាត់គូ ប្រវែង ២០០ម. ។ ក្នុងចំនួន ២០០ម. នេះ ភ្នែកយើងបានទៅប៉ះ និងគោបុរៈ ធំរបស់កំពែងខាងក្រៅជាប់និងគូ ។ ភ្នែកយើងពុំអាចមើលឃើញអ្វីទៀតដែលនៅខាងក្នុងក្រៅអំពីកំពូលប្រាសាទ និង ជំពូលថែវទាំង ៣ ខ្ពស់ផុតព្រៃព្រឹក្សា ។ បើយើងមិនឆ្លងកាត់គោបុរៈនេះទេ នោះយើងនៅតែ ឆ្ងល់ថា តើមានអ្វីនៅខាងក្នុងបរិវេណនេះ ។ អ្នកមានសន្ទុះចិត្តចង់ដឹងអ្វីទៀតនៅខាងក្នុង តែងបង្ខំជំហានឆ្លងកាត់ទ្វារនេះទៅមុខទៀត ។ បើអ្នកមានការសង្កេតខ្លាំងមើលឃើញគោបុរៈ នេះជាការសង្ខេបទ្រង់ទ្រាយរូបរាងវិមានធំខាងក្នុង ។ នោះគឺជា បុព្វកថាមួយបែបក្នុងស្ថាបត្យកម្ម តាមរយៈខ្សែបណ្តោយ ដូចក្នុងការពិសិល្បៈល្ខោនដែរក្នុងបំណងពន្យល់ទស្សនិកជន ។ ចូលមុខវិពីភ្លេងមួយធំនេះ នោះក្រសែភ្នែកបានបើកទៅប៉ះនិងទិដ្ឋភាពនៃអាករដ៏សែនធុនដែលវិលិចស្រមោលកំពូលប្រាំបញ្ឈរខ្ពស់លើខ្សែបន្ទាត់ផ្តេកពីថ្នាក់ ប្រសិនបើយើងឈរនៅចំកណ្តាលខ្សែបញ្ឈររបស់ប្រាសាទនេះ ។ បណ្តាលមកពីកំពូលទាំងនោះពណ៌ខ្មៅៗ មិនស្មើគ្នាតាមពួកឈើ ផ្កាថ្ម ។ នេះគឺធ្វើអោយអ្នកមើលឆ្ងល់ទៀតថា តើមានអ្វីដែលនៅក្នុងនោះ ? ដាច់ខាតយើងមិនដើរវិលវង្វេងឯកសារទាំងពីរនេះទេ ប្រសិនបើយើងមានពេលច្រើន ។

យើងចូលទៅដល់ជិតគោបុរៈនៃថែវទី ៣ នោះភ្នែកមិនអាចមើលឃើញអ្វីក្រៅពីផ្ទាំងថ្មលំអដោយចម្លាក់និងសសរ, ទំហំថ្មសន្ធប់យើងដាច់ ត្រជាក់ស្រួត ឃើញពន្លឺបាញ់ចេញតាមច្រកទ្វារទាំងបួនទិស ។ ចិត្តយើងភ័ន្តភាំងថា តើត្រូវមើលអ្វីមុន ព្រោះមួយជុំរបស់ថែវមានរចនាចម្លាក់ក្របាច់-ទាប ដែលមានទំហំសរុប ១ គ.ម២ - កំពស់ ២ម. ។ តើមានចម្លាក់អ្វីខ្លះនៅ ? នោះចិត្តយើងកាន់តែចង់ដឹងថែមទៀត ។ យើងបង្វិលខ្លួនបែរមុខទៅទិសខាងលិចភាគខាងត្បូង យើងឃើញតាមច្រកទ្វារខាងលិចនូវទេព្រានស្បែកដ៏ល្បីល្បាញមិនអាចប្រៀបបានរបស់ប្រាសាទអង្គរវត្ត និងផ្លូវធំខាងលិច នៅក្នុងពិភពលោកនេះ ។ ផ្លូវនេះមានប្រវែង ៣៥០ ម × ៥.៤០ ម ក្រាលថ្មភក់ លំអដោយបង្កាន់ដៃនាគចោលស្រមោល ម្លប់ ឬក្តី ក្នុងពេលមានពន្លឺព្រះអាទិត្យ ។ ដោយឡៀសរាងភាពត្រង់ដែលៗ សិល្បករខ្មែរច្រើនម្ហិកុចក្បាច់សារពើស្អាត ហើយលំអដោយក្បាលនាគផងនៅអផ្លូវនេះ ។ យើងពុំអាចដឹងថា មានអ្វីនៅជុំវិញថែវទី ៣ នេះ ចង់ស្គាល់ត្រូវតែដើរជុំមួយជុំ ហើយភ្នែកពុំអាចមើលឃើញថែវទីពីរទេ លើកលែងតែយើងចេញអោយផុត អំពីគោបុរៈខាងត្បូង ,

ខាងកើត និងខាងជើង នោះទើបអាចឃើញថែវទីពីរ ដែលលេចឡើងខ្ពស់ជាងមួយជាន់ទៀត ។ បន្ទាប់ពីមើលថែវទី ៣ បានមួយជុំ នោះយើងនៅតែចង់ដឹងថា មានអ្វីទៀតនៅជាន់ទី ២ ។ យើងមកដល់ត្រង់ថែវសង់ជាក្រឡាចត្រង្គភ្ជាប់ពីគោបុរៈខាងលិចនៃថែវទី ៣ មកថែវទី ២ ។ អ្នកមានការឆ្ងល់ត្រូវដើរ ឬ វត់ត្រឡប់ត្រកនៃថែវនេះ ប៉ុន្តែក៏នៅមិនអាចដឹងអ្វីនៅក្នុងថែវទី ២ នៅឡើយទេ ដូចនេះត្រូវបង្ខំចិត្តឡើងជណ្ដើរទាំង ៨ ទិសទៅកាន់ថែវទី ២ ទៀត ។ អាថ៌កំបាំងនេះ នៅតែនៅមានបន្តរហូត ។ ទស្សនិកជនអាចមានការងឿងឆ្ងល់ចម្លែកមួយទៀត ពេលដែលគេដើរតាមបណ្ដោយថែវពុះកាត់ចំពាក់កណ្ដាល ពីត្បូងទៅជើងរបស់ថែវរាងកាកបាទនេះ ។ នោះគឺជាសម្លេងខ្ទរ ឮ ខ្ទរៗ ប្រសិនបើយើងយកដៃ ទៅគក់ទ្រូងរបស់យើងនោះ ។ បើចេញអោយផុតតាមទ្វារខាងជើងនៃថែវនេះ ក្រសែភ្នែកបានបកប៉ះ និងបណ្ណាល័យខាងជើង អំពីទីនោះយើងនិងឃើញទ្រង់ទ្រាយកំពូលប្រាសាទជំកណ្ដាលអណ្ដែតរសាត់ក្នុងផ្ទៃមេឃដ៏ខៀវស្រងាត់ ហើយនឹកនៃក្នុងចិត្តថា តើត្រូវប្រើកម្លាំងពលកម្ម និង កម្លាំងប្រាជ្ញាប្រកបដោយការព្យាយាមប៉ុណ្ណាទៅដើម្បីកសាងសំណង់ដ៏ខ្ពស់ លាតលើទំហំដីចំនួន ២០០ ហិកតានេះ ។ យើងនៅតែឆ្ងល់ដដែល ពេលដែលយើងធ្វើដំណើរតាមបណ្ដា ចំចន្លោះថែវទី ៣ និង ថែវទី ២ ។ យើងអាចឡើងតាមជណ្ដើរគ្រប់ជ្រុងទាំង ៤ ទៅកាន់ថែវទី ២ ។ ចម្ងល់ បានកើតឡើងទៀតហើយ ហេតុអ្វីបានជាជញ្ជាំងថែវទី ៣ [៤២] ខាងក្នុងគ្មានលំអអ្វីបន្តិចសោះ ? ឯជញ្ជាំងថែវទី ២ មានចោះបង្អួចតូចល្អបលំអដោយចរឹងជើងទៀនទាំងលើជញ្ជាំងខាងក្នុង និងខាងក្រៅ ។ ចំណងចំ គឺបង្ខំអ្នកមើលអោយគាប់អារម្មណ៍ទៅលើក្រុមអប្សរាប្រកបដោយការតុបតែងលំអយ៉ាងស្រស់ ។ គឺនៅលើជញ្ជាំងទាំងខាងក្នុងទាំងខាងក្រៅរបស់ថែវទី ២ នេះ ហើយដែលទស្សនិកជនមិនអាចអត់ទ្រាំបានក្នុងការកោតសរសើរសំរស់ដ៏ល្អដ៏ត្រេនស័យាបថរបស់នាងអប្សរា ។ ជាន់ទី ៣ សង់ឡើងតាមប្លង់រាងកាកបាទ ព្រទាក់ថែវមានជំហួល ហើយមានប្រាសាទបួននៅតាមជ្រុង និងប្រាសាទកណ្ដាលជំមួយ ។ ជណ្ដើរចោទៗចំនួន ១២ នាំយើងទៅកាន់ស្ថានមួយទៀត ដែលធ្វើអោយយើងមានអារម្មណ៍ប្លែកខុសប្រក្រតី ។ ចិត្តយើងរំភើបកាន់តែខ្លាំង នោះគឺត្រូវតែបង្ខំចិត្តអោយយើងរត់មួយ ជុំថែវដើម្បីទម្លាក់កែវភ្នែកមើលជំហួលថែវទី ២ ទី ៣ ភូមិប្លង់ ព្រៃព្រឹក្សា និង ផ្លូវធ្លលជំខាងលិច ដែលនៅពីខាងក្រោមយើង ក៏ដូចជាងើយមើលអ្វីដែលមាននៅលើប្រាសាទជំកណ្ដាល កំពស់ ៤២ ម៉ែត្រ តាម

---

៤២ - នៅតាមបណ្ដោយថែវទី ៣ ខាងក្រៅ មានចម្លាក់ក្រឡាផ្ទាំង ជាច្រើនអំពីរឿងមហាភារតៈ, រឿងរាមកេរ្តិ៍, ពិធីការក្បួនរាជ នៃស្ដេចសូរ្យវរ្ម័ន ឋាននរក ឋានសួគ៌ ឋានយមរាជ រឿងកូរសមុទ្រទឹកដោះ ហើយនិងសង្គ្រាមរបស់ព្រះវិស្ណុ ។

ចន្លោះបង្អួចតឹង និង ប្រឡោះសសរ ទ្រូវខាងក្នុងនៃផែទី ១ ។ នោះខ្លួនយើងហាក់ដូចជាស្ថិតនៅលើកំពូលភ្នំមួយដ៏ខ្ពស់ ឬ នៅក្នុងយន្តហោះ ឬ មួយហាក់ដូចជាឡើងទៅកាន់ ស្ថានសួគ៌ ដែលប្រដូចទៅនឹង ប៉ម ជាបែល ដែលបណ្ដាកូនៗរបស់ណូអេនាំគ្នាសាងសង់ឡើង សំរាប់ឡើងទៅកាន់ថានលើនោះ ។ ជូនអ្នកមើលអាចស្ទុះសំរែកទាំងមិនដឹងខ្លួន : តើអញនៅទីណា ! តើអញ នៅទីណា ! អញនៅក្នុងស្ថានសួគ៌ទេដឹង ! ចើនៅខាងក្រោមអញ រូបមនុស្ស ឬ សត្វមានទំហំតូចៗគ្រាច់រង្គាត់ចុះ ឡើងគ្មានរៀបរណាយ ។ ក្ដីភិតភ័យខ្លាំងជូនធ្វើអោយមនុស្សមិនអាចនិយាយអ្វីកើត ទ្រូង ! ទ្រូង ! តែរាងកាយញ័រ ស្មារតីនឹកទៅដល់អ្វីដែលស្ទើរតែមិន គួរជឿដល់កម្លាំងពលកម្មរបស់មនុស្សថែមទៀត ។

## សាសនា

សាសនាជាទំរង់មួយក្នុងចំណោមទំរង់ដ៏ចំណាស់ៗនៃមនសិកាសង្គម ។ យើងដឹងហើយថា មនសិកាគឺជាសកម្មភាពនានា នៃសតិអារម្មណ៍របស់មនុស្សដែលរួមមាន មនោសញ្ចេតនា និងសភាព នៃស្មារតីឆន្ទៈនិងសតិអារម្មណ៍ ទ្រឹស្ដី និង ទស្សនៈ ដែលផ្អែកលើការត្រិះរិះពិចារណាដោយគំនិត និងភាសា ។ ពេលណាក៏ដោយ ក៏មនសិកាឆ្លុះបញ្ចាំងអ្វីដែលជាការពិតដែរនៅក្នុងខួរក្បាលមនុស្ស ។ យើងឆ្លុះបញ្ចាំងសាសនាក្នុងទីនេះ គឺផ្អែកលើទស្សនៈសំភារៈនិយមវិចារវិទ្យា ។ វិទ្យាសាស្ត្របាន បញ្ជាក់ថាអ្វីៗទាំងអស់មិនមែនអមតៈទេ សាសនាក៏មិនមែនអមតៈដែរ ពោលគឺ គ្រាន់តែលេចឡើងក្នុងលក្ខណៈប្រវត្តិសាស្ត្រមួយជាក់លាក់ សាយភាយ រីកលូតលាស់ ហើយក៏អាចលិចទៅវិញ យោលទៅតាមមូលហេតុសង្គម និងប្រវត្តិសាស្ត្រ : ឧទាហរណ៍ ប្រវត្តិសាសនានៅកម្ពុជា ជាភស្តុតាងក្នុងពេលដែលមានវិបត្តិសាសនាមួយ ក្រោយសម័យជ័យវរ្ម័នទី ៧ បន្តិច ។ សង្គមនិយម ប្រវត្តិ សាស្ត្រអនុម័តមិនយកវណ្ណៈដូចគ្នាមួយចំពោះរាល់សាសនា ហើយមកស្រាយចាប់ផ្ដើមអំពីផលប្រយោជន៍របស់វណ្ណៈកម្មករ និងសង្គមអ្នកឧស្សាហ៍ព្យាយាម ផលប្រយោជន៍របស់បដិវត្តន៍ ដើម្បីសេរីភាព និង ស្មារតីយុត្តិធម៌ ។ ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជាលេខ ៤៤៣-៨០ ក.ប. បានចេញសារាចរ ដើម្បីអនុវត្តគោលនយោបាយអំពីសាសនា ដោយផ្អែកលើគោលការណ៍ ៤ យ៉ាង ដែលធានាចំពោះជំនឿសាសនា ជាជាប្រយោជន៍របស់ប្រជាជន ហើយព្រមទាំងគោរពសិទ្ធិសេរីភាពខាងជំនឿផងទៀត ។ ដូចនេះយើងឃើញថាគោលនយោបាយរបស់រដ្ឋអំណាចបដិវត្ត ចំពោះអ្នកមានជំនឿទាំងឡាយ

បានប្រកាសអំពីគោលការណ៍នៃសេរីភាពរបស់មនសិការ ហើយតាមរយៈនេះ ជំនឿនិងបរនាសពួតនាសាសនាជាការងារផ្ទាល់ខ្លួនរបស់ប្រជាជន ។ រដ្ឋសង្គមនិយមមិនចូលលូកក្នុង ឥរិយាបថចំពោះជំនឿសាសនារបស់ពលរដ្ឋទេ ហើយទទួលស្គាល់សេរីភាពទាំងខាងជំនឿលើសាសនា ក៏ដូចជាទទួលស្គាល់សេរីភាពអំពីការផ្សព្វផ្សាយប្រឆាំងនឹងសាសនាផងដែរ ។

មុននឹងលើកឡើងខ្លះៗអំពីសីលធម៌ល្អៗទាំងឡាយរបស់ពុទ្ធសាសនាសំរាប់ជាតិ និងប្រជាជន ដែលបាន រក្សាទុកប្រពៃណីរួមមួយនេះ តាំងពីរាប់ពាន់ឆ្នាំកន្លងមកហើយរហូតមកដល់បច្ចុប្បន្ននេះ យើងសូម លើកឡើងខ្លះៗអំពីមហាសាសនាដែលកើតមានឡើងតាំងពីភាគខាងដើមនៃប្រវត្តិសាស្ត្រ របស់ប្រទេសកម្ពុជាយើង ។ ជំនឿលើសាសនាពីរ គឺជាមូលដ្ឋាននៃប្រវត្តិសាសនាក្នុងកម្ពុជាអតីតកាលៈ ចាប់តាំងពីសម័យនគរភ្នំរហូតមកដល់សតវត្សទី ១៥ ប្រទេសកម្ពុជាទទួលយកព្រាហ្មណ៍សាសនា និងពុទ្ធសាសនា ដែលជាសាសនាធំពីរ កើតនៅក្នុងប្រទេសឥណ្ឌាហើយហូរចូលមកក្នុងទឹកដីឥណ្ឌូចិនតាំងពីពាក់ កណ្តាលទី ២ នៃសតវត្សទី ៣ នៃគ្រិស្តសករាជ [៤៣] ។

លោក ស៊ុយវ៉ាំង ឡេវី កត់សំគាល់ថា សាសនាទាំងពីរនេះបានជាទីពេញចិត្តរបស់ពួកអភិជនច្រើនជាងចូលទៅក្នុងចំណោមប្រជាជន ។ មុននេះនៅក្នុងប្រទេសកម្ពុជាយើង មានវណ្ណៈអាចារ្យដែលយើងហៅថា " ជាតូ " [៤៤] មានតួនាទីសំខាន់ក្នុងពិធីបុណ្យសាសនាជាប្រពៃណី ។ សាសនាទាំងពីរនេះ មិនបានបើកលៃងឬការពិបត្តិនិយមទេ [៤៥] ។ សិលាចារឹកស្តុកកក់ធំបាន និយាយថា ក្សត្រសុរិយាវរ្ម័នទី ១ បាននាំគេទៅបង្ក្រាបពួកអ្នកបំផ្លាញរបស់ណាកដ៏ពិសិដ្ឋៗ ហើយនាសតវត្សទី ១៣ មានប្រតិកម្មសិវៈនិយមមួយយ៉ាងសាហាវប្រឆាំង និងស្នាដៃសិល្បៈដ៏ល្អៗ របស់ជ័យវរ្ម័នទី ៧ ។ ក្នុងសម័យនគរភ្នំ បណ្តាក្សត្រិយ៍ភាគច្រើនផ្នែកបុរាណវិទ្យាបង្ហាញប្រាប់ថាមានពុទ្ធសាសនា ហីនយាន ត្រូវភាសាសំស្ក្រឹតជាយាននោះ បានមកដល់មុនព្រាហ្មណ៍សាសនា ។ ពុទ្ធសាសនាមហាយាន កើតក្រោយនិកាយហីនយាននាក្នុងសតវត្សទី ៧ ហើយមានជោគជ័យក្នុងសម័យអង្គរ ទន្ទឹមគ្នា និងព្រាហ្មណ៍សាសនាដែលត្រូវបានគេប្រើប្រាស់ជាផ្លូវការ ។

នៅដើមសតវត្សទី ៩ ការមកដល់របស់ជ័យវរ្ម័នទី ២ បានកត់សំគាល់នូវការបង្កើតជំនឿថ្មីមួយ គឺលទ្ធិទេវរាជ " ភាសាខ្មែរបុរាណហៅថា កំរតែងជគត តរាជ " ដែលមានអាយុបន្តរហូតមកដល់

---

៤៣ . [illegible] ១៩៦៧ - ទំព័រ ១១ , ១២

៤៤ - [illegible]

៤៥ . [illegible]

សម័យស្រុតចុះនៃរាជាណាចក្រខ្មែរ ។

ចាប់តាំងពីសម័យនោះមក អាទិទេព គឺជាបុគ្គលដែលមានជីវិតហើយសិល្បករឆ្លាក់រូបលិង្គ ឬយតំណាងអោយ សិវៈពាក់កណ្ដាល មនុស្សពាក់កណ្ដាល ពេលនិយាយអោយស្រួលយល់ ខ្មែរធ្វើទេវៈអោយមកជាមនុស្ស ។ តាមហេតុការណ៍នេះ យើងអាចកំណត់បានថា ប្រជាជនកម្ពុជា ប្រកាន់យកទស្សនៈមនុស្សកាន់តែខ្លាំង ចាប់តាំងពីភាគខាងដើមនៃសតវត្សទិ ៩ រំលាយចោលទស្សនៈអាទិទេពនិយមដែលផ្សព្វផ្សាយនៅក្នុងជំនឿសាសនា។ ដើម្បីអោយងាយយល់ ជៀសវាងអ្វីដែលបរមត្ថវិជ្ជាពេក ប្រជាជនកម្ពុជាបានប្រែក្លាយឯកសិវៈលិង្គ មកត្រីមូរតិលិង្គ ហើយឆ្លាក់អោយកើតជាតួសិវៈ វិស្ណុ ឬ ព្រហ្ម ឬហរិហរៈ ឬ ពុទ្ធរេជិកា ក្រោម រូបភាពមនុស្ស ដោយឈរនៅលើទស្សនៈមនុស្សដដែល ។

ដោយយោងតាមឯកសារសិលាចារឹកដែលរកឃើញនៅលើទឹកដី កម្ពុជា ហើយនិងឯកសារប្រវត្តិសាស្ត្រ របស់ប្រទេសចិន យើងដឹងថា ព្រហ្មញ្ញសាសនាពិតប្រាកដនៅសម័យនគរភ្នំ គឺជាសាសនាលាយឡំរវាងនិកាយពីរ ។ គេដឹងទៀតថា មជ្ឈមណ្ឌលរបស់ពុទ្ធសាសនា មី ស្ថិតនៅវត្តរំលោកនៅក្បែរប្រាសាទ ភ្នំដា សព្វថ្ងៃនេះ ។ ដូច្នេះសម័យនគរភ្នំ គឺ គោរពសាសនាពី ក៏ប៉ុន្តែនិកាយជាផ្លូវការនោះ គឺ សិវៈនិយម ។ ក្នុងសតវត្សទិ ៧ សិលាចារឹករបស់វត្តទួលព្រះធាតុក៏បានអោយសញ្ញាណ៍ពីវត្តមានរបស់ពុទ្ធសាសនាហីនយានដែរ ។ រីឯសិលាចារឹកវត្តព្រៃវាលសរសេរក្នុងឆ្នាំ ៦៦៤ គ.ស. ក៏បានប្រាប់អំពីវត្តិភាពរបស់ភិក្ខុពីរ អង្គដែរ ។ ឯពុទ្ធសាសនាមហាយាន " ស.វ.ទិ ៧ - ទិ ៨ " ចម្លាក់ដោយសិលាចារឹក ប្រាសាទអំពិលរលំ ប្រាសាទសំបូរ " ៦៨៣ គ.ស. " ហើយនិងប្រាសាទ តាតាំ " ៧៩១ គ.ស. " ។ ផលិតកម្មសិល្បៈរបស់ពុទ្ធសាសនា គឺស្ថិតនៅក្នុងតេជិតម៉ត្រុងអង្គបុរី ខេត្ត តាកែវ " ហើយ លាតសន្ធឹងពីសតវត្សទី ៦ ទៅទី ៨ ។ ប្រពៃណីរបស់ប្រជាជននគរភ្នំ គឺ ភ្ជាប់ទៅនិងសាសនា អមរាវតី ហើយនិងសិល្បៈ ក្រោយ-គុបតៈ " ឥណ្ឌា " ។ ក៏ប៉ុន្តែនគរភ្នំ ក៏បានទទួលនូវទ្វីបខ្មែរ គឺ សេរីលង្កា ហើយនិងទ្វារវតីដែរ ។ ពុទ្ធសាសនាហីនយាន កើតមុនពុទ្ធសាសនាមហាយាន ។ ទាំងពីរនេះកកើតក្រោយព្រហ្មញ្ញសាសនា ។ មូលហេតុអ្វីក៏ព្រហ្មញ្ញសាសនាមានប្រជាប្រិយនៅមុនសម័យអង្គរុងរឿង ? ១ - សិវៈនិយមជាសាសនាផ្លូវការ ២ - សិវៈនិយមស៊ីរូលចំពោះមហាជនក្នុងសង្គមព្រហ្មញ្ញ ៣ - ឫសគល់របស់

ព្រហ្មញ្ញសាសនាបានចាក់ឫសក្នុងសង្គមកម្ពុជា តាំងពីមុនសម័យពួកអារិយាង : ជំនឿលើដី - លើភ្នំ ដែលជារូបភាពរបស់លទ្ធិព្រលឹង ។

សាសនាធំទាំងពីរនេះ បានជ្រួតជ្រាបខ្លាំងទៅក្នុងចង្កោមពួកអភិជនសក្តិភូមិជាងទៅក្នុងប្រជាជន តែយើងត្រូវតែយល់អោយច្បាស់ថា នៅក្នុងសង្គមមួយ យោលទៅតាមពេលវេលា និងប្រវត្តិសាស្ត្រជាក់ស្តែង តែងមានវប្បធម៌ពីរ : វប្បធម៌ចង្កោមអ្នកជិះជាន់ និងវប្បធម៌របស់មហាជនប្រជាជន។ ថ្វីត្បិតតែយ៉ាងដូច្នេះ បណ្ដាថ្នាក់ដឹកនាំគ្រប់គ្រងរដ្ឋកម្ពុជា តែងតិតដល់ការបូកបញ្ចូលធាតុវប្បធម៌ទាំងពីរនេះអោយក្លាយទៅជាប្រពៃណីរួមមួយ ជាមរតករួមមួយ ចូលជ្រៅទៅក្នុងប្រជាជន។ ភស្តុតាងជាក់ស្តែងចំពោះរឿងនេះគឺ ១ - ការ ប្រើប្រាស់ភាសាពីរ : ភាសាសំស្ក្រឹតដែលគេចាត់ទុកថា ជាភាសាអ្នកប្រាជ្ញ ភាសាថ្នាក់ខ្ពស់ ហើយនិងភាសាខ្មែរបុរាណ ដែលប្រើប្រាស់ក្នុងប្រជាជន ។ គេបានចារឹកភាសាទាំងពីរនេះជាមួយគ្នានៅលើផ្ទាំងសិលាតែមួយ ឬ នៅលើមេទ្វារនៃបណ្ដាប្រាង្គ ប្រាសាទ ។ ២ - ការសាងសង់ប្រាសាទ ៣ ហើយនិងការកសាងវត្តអារាមសំរាប់និកាយខុសៗគ្នា ក្នុងចំណោមប្រជាជន ។ ក្នុងចំណងសំដៅចំពីផលប្រយោជន៍ប្រទេសជាតិទាំងមូល និងព្រលឹងនៃការទំនាក់ទំនងសង្គម សិល្បករថ្នាក់ ឬស្ថាបនិក បានប្រែក្លាយអ្វីៗដែលមិនមែនខ្មែរអោយមកជាខ្មែរ ។ ឧទាហរណ៍ មួយអំពីការកសាងរូប ហរិហរៈ ឬ រូបវិស្ណុដៃបួន ។ ក្នុងឃ្លាមួយដកស្រង់ចេញអំពីសិលាចារឹក យើងឃើញមានពាក្យថា " ហរិកម្ពុជេន្ទ្រ ... " ។ ពាក្យនេះមានន័យថា ប្រជាជនកម្ពុជា គោរពតែហរិ " វិស្ណុ " ដែលជាកំពូលនៃផលប្រយោជន៍របស់ទឹកដីកម្ពុជា ពោលគឺថ្នាក់ដឹកនាំថ្នាក់ណា ដែលគោរពផលប្រយោជន៍របស់ប្រជាជន។ វាក្យសព្ទ " ទេវ - រាជ " តំណាងអោយមនុស្ស ។ មនុស្សនោះគឺ ខ្មែរ ។ រីឯវិស្ណុបដិមា ដែលមានដៃទាំងបួនកាន់សង្ខ " តំណាងទឹក " កាន់កងចក្រ " តំណាងភ្លើង " កាន់ដំបង " តំណាងខ្យល់ " ហើយនិងដុំមូល " តំណាងអោយផែនដី [៦៧] " គ្មានអ្វីក្រៅពីបញ្ជាក់ ប្រាប់អត្ថិភាពនៃធាតុទាំងបួនដែលជាលោកសត្យានុម័ត សំរាប់ទ្រទ្រង់ជីវិតនៃជីវភូនោះទេ ។ គេគនកពន្លបួន គឺ ពិតជាតំណាងទឹក ដី ភ្លើង ខ្យល់ ដែលទ្រទ្រង់អត្ថិភាពរបស់អាណាចក្រកម្ពុជា ដែលជាផ្នូរបផ្តល់ភាពចំរុងចំរើន សុភមង្គលដល់ប្រជាជនដែលត្រូវតែតបស្នងសងវិញក្នុងការបញ្ចេញកម្លាំងពលកម្ម ដើម្បីទ្រទ្រង់ស្ថិតស្ថេរសង្គមកម្ពុជា ។ នាសតវត្សទី ១៣ ទស្សនៈលោកិយសច្ចៈនេះស្ថិតនៅក្នុងវេនសីការបស់ខ្មែរនៅឡើយ ។ ប្រធានរឿងស្តីអំពីការកួរសមុទ្រ

---

៦៦ - ម៉ាដឺឡែន ហ្សិតូ - រង្វា - ប្រជាជនខ្មែរ សិល្បៈខ្មែរ

៦៧ - យោងតាមការពន្យល់ ជាជំនួសអោយផែនដីមេរីឡូ

ទឹកដោះនៅអង្គរវត្ត និងនៅខ្លោងទ្វារចូលទៅកាន់អង្គរធំ បានបង្ហាញប្រាប់អំពីការបញ្ចេញពលកម្មរបស់ប្រជាជនកម្ពុជាទាំងមូល ដើម្បីចំរាញ់យកគោគជល អំពីធម្មជាតិខ្មែរ ពោលគឺយកជ័យជំនះទៅលើ " ភ្នំ-ព្រៃព្រឹក្សា " ហើយនឹងទៅលើ " ទឹក " ដែលចាំបាច់សំរាប់ជីវិត និងរបរកសិកម្មរបស់សង្គម ។[៥៨] លក្ខណៈសំខាន់នៃសីលធម៌សង្គមរបស់លទ្ធិ " ពុទ្ធ-ស្តេច " ដែលជំនួសលទ្ធិ " ទេវរាជ " នោះ បានបង្ហាញអោយឃើញនូវក្តីកង្វល់ចំពោះជីវភាពប្រជាជនច្រើនជាងអត្តទត្តបុគ្គល ។ បរសិការសង្គមនៅក្នុងសន្តានចិត្តរបស់ថ្នាក់ដឹកនាំរដ្ឋ បានជ្រួតជ្រាបទៅក្នុងមហាជនប្រជាជនដ៏ជ្រាលជ្រៅ ហេតុនេះហើយបានជាប្រទេសកម្ពុជាអាចនៅសំបូររុងរឿង អាស្រ័យដោយមនោគវិជ្ជារបស់រដ្ឋបានចំពីរយប្រយោជន៍សម្បូរភាពពិតប្រាកដ ។

# សីលធម៌របស់សាសនាដែលមានប្រយោជន៍ សំរាប់ជាតិនិងប្រជាជន

នៅក្នុងពិភពលោកបច្ចុប្បន្ននេះ មានសាសនាធំតែបីទេ គឺ ពុទ្ធសាសនា គ្រិស្តសាសនា និងឥស្លាម សាសនា ។ ពុទ្ធសាសនាបានកើតឡើងក្នុងសតវត្សទី ៦ - ទី ៥ មុនគ្រិស្តសករាជនៅក្នុងប្រទេសឥណ្ឌាបុរាណ ក្រោយមកមានពីរ និកាយ ៖ មហាយាន និងហីនយាន ។ នាសតវត្សទី ៤ មុនគ.ស.ពុទ្ធសាសនាមានដល់សម័យកំពូលរបស់ខ្លួន ។ សាសនានេះបានសាយភាយនៅក្នុងអាស៊ីអាគ្នេយ៍ អាស៊ីកណ្តាល គឺចិន នៅស៊ីប៊េរី ហើយនៅក្នុងទីទាំងនោះពុទ្ធសាសនាបានចូលលាយជាមួយព្រហ្មញ្ញសាសនា និងសាសនាតាវ ។ល។

គ្រិស្តសាសនាចែកចេញជាបីៈ កាតូលិក អកធូដុក និង ប្រូតែស្តង់ ។ អត្ថបទសាសនាគឺគម្ពីរប៊ីប្លិ ។ គ្រិស្តសាសនាកើតឡើងនាសតវត្សទី១ក្នុងទឹកដីប៉ាឡេស្ទីនដែលជាខេត្តមួយខាងកើតនៃចក្រភពរ៉ូម៉ាំង។ គ្រិស្តសាសនាដំបូងជាសាសនារបស់ពួកអ្នកត្រូវគេជិះជាន់ ក្រោយមកទើបពួកអ្នកកាន់អំណាចយកមកប្រើប្រាស់ដើម្បីបំរើផលប្រយោជន៍របស់ពួកគេ ។

ឥស្លាមសាសនា គឺជាស្នាដៃរបស់ម៉ាហូមេត ដែលបានចងក្រងជាគម្ពីរគូរ៉ង់ដែលពួកអារ៉ាប់ហៅថា " សូរទាំង៤ នៃជំនឿ " ។ សាសនាឥស្លាមបានសាយភាយនៅអាស៊ី នៅតាមច្រាំងសមុទ្រមេឌីទែរ៉ាណេ នៅទន្លេ វ៉ាំងដុសនិងច្រាំងសមុទ្រ អាត្លង់ទិក ។ សាសនានេះកើតឡើងនាឆ្នាំ

---

៥៨ - គីដែស ( Coedes ) ដើម្បីពង់រួមភាពនៃគ្រួស-ចំនួន ១០៣ ។ ធ្លាប់នាំបានមកនេះ [illegible] [illegible] [illegible] ។ [illegible] " ទឹក " [illegible] ។

៦២២ ។

យើងសង្កេតឃើញថា សាសនាទាំងពីរនេះតែងលើកឡើងរៀងៗខ្លួន នូវសីលធម៌សំរាប់អប់រំដល់បណ្តាសាវ័ករបស់ខ្លួន ។ ទីនេះយើងលើកសីលធម៌របស់ពុទ្ធសាសនាតែមួយគត់មកបង្ហាញជូន អាស្រ័យដោយប្រទេសកម្ពុជាយើងបច្ចុប្បន្ននេះ បានធានាអះអាងចំពោះសិទ្ធិនិងសេរីភាពលើជំនឿសាសនា ពិសេសប្រជាជនកម្ពុជាដែលបន្តប្រពៃណីមួយនេះអំពីដូនតារបស់ខ្លួន ។ តើសីលធម៌ទាំងនេះអាចអប់រំអ្វីខ្លះដល់ប្រជាជន ? សូមអ្នកអានទាំងអស់អញ្ជើញពិចារណាជាមួយយើងខ្ញុំដូចតទៅនេះ :

- " រស់នៅតែមួយថ្ងៃ ដោយធ្វើខ្លួនអោយល្អហើយដឹងខ្លួនគិត ប្រសើរជាងរស់នៅ ១០០ ថ្ងៃ ដោយគ្មានគតិបណ្ឌិតហើយនិងមិនបានគិត " ។

- " រស់នៅតែមួយថ្ងៃ ដោយបានបញ្ចេញថាមពលដ៏សំបើមប្រសើរជាងរស់នៅ ១០០ ថ្ងៃ ដោយសោះអង្គើយហើយនិងគ្មានថាមពល..." " ដកស្រង់អំពីគម្ពីរធម្មបទសហស្សវគ្គ " ។

សីលធម៌ខាងលើនេះ សំដៅយកពេលវេលាជាការសំខាន់ មួយថ្ងៃៗ មនុស្សត្រូវគិតថាអញបានធ្វើអ្វីខ្លះហើយ អំពើដែលធ្វើត្រូវជាកុសល ប្រកបដោយគតិបណ្ឌិត មិនបណ្តោយអោយពេលវេលាកន្លងហួសទៅ ដោយមិនបានធ្វើអ្វីជាប្រយោជន៍ដល់ខ្លួន ដល់សង្គមនិងដល់ជាតិមាតុភូមិ។

ក្នុងវគ្គមគ្គមានសីលធម៌ពីរសំរាប់អប់រំមនុស្សអោយរស់នៅថ្លៃថ្នូរក្នុងសង្គម មិនឈ្លោះគ្នា មិនប្រកាន់ចំពោះអ្នកដទៃ និយាយត្រង់ទៅត្រង់មក ហើយមិនពោលពាក្យសីកសៀតដាក់គេ ដែលនាំអោយមានជំទាស់រវាងគ្នានឹងគ្នា : ១- វាចាត្រឹមត្រូវ " សម្មាវាចា " គឺជាវាចាត្រឹមត្រូវដែលវៀរចាកពាក្យមិនពិត ពាក្យសីកសៀតញុះញង់បំបែកបំបាក់ ពាក្យជេរប្រទេចតិះដៀលដៀលដាក់ ពាក្យឈ្លោះឈ្លោះ ឥតបានការឥតប្រយោជន៍ ។ ២-ការងារត្រឹមត្រូវ "សម្មាកម្មន្ត" គឺការប្រព្រឹត្តល្អ វៀរចាកការសម្លាប់សត្វមានជីវិត ការលួចទ្រព្យសម្បត្តិអ្នកដទៃ ការប្រព្រឹត្តសេពកាមគុណជាមួយប្រពន្ធកូនអ្នកដទៃ ។ ៣- ការចិញ្ចឹមជីវិតដោយត្រឹមត្រូវ " សម្មាអាជីវៈ " គឺការចិញ្ចឹមជីវិតដោយមិនប្រព្រឹត្តខុសក្នុង ដូចជាការប្លន់ទ្រព្យសម្បត្តិអ្នកដទៃ ការធ្វើជំនួញផ្សេងៗដោយកេងប្រវ័ញ្ចប្រកបដោយទុច្ចរិត...

សីលធម៌នេះនាំអោយមនុស្សម្នាក់ៗដែលបានប្រកាន់យក មានសេចក្តីចំរុងចំរើន ដោយ

សន្តិភាព អ្នកផងដទៃតែងគោរពរាប់អាន ព្រោះការស្គាល់ខ្លួនឯងច្បាស់ ជាប្រភពនាំអោយរីកលូតលាស់របស់បុគ្គល ខ្វះអ្វីកុំអោយតែខ្វះការអៀនខ្មាស់ អ្នកមានបុគ្គលិកលក្ខណៈ គឺមិនចេះប្រមាថ ធ្មានចិត្តច្រណែនឈ្នានីស ។ កិច្ចអភិវឌ្ឍន៍សេរីរបស់មនុស្សម្នាក់ៗ ជាលក្ខណៈអភិវឌ្ឍន៍សេរីនៃមនុស្សទាំងឡាយ[៩៥] ។

នៅក្នុងសង្គមកម្ពុជាអតីតកាល ក៏ដូចបច្ចុប្បន្ននេះដែរ គ្រួសារតូចដែលជាកោសិកាសង្គម តែងអប់រំតាមគន្លងព្រហ្មវិហារ ៤ យ៉ាងសំរាប់អប់រំដល់កូនចៅ ។ សីលធម៌នេះមិនត្រឹមតែមានប្រយោជន៍ក្នុងសង្គមគ្រួសារ តែវាសំរាប់សង្គមទាំងមូល ហើយនិងអន្តរជាតិផងដែរ ។ សីលធម៌ទាំងនោះគឺ: ១ - មេត្តា គឺជាការរាប់អាន សេចក្តីប្រណី និងបំណងចង់អោយអ្នកដទៃមានសេចក្តីសុខ ធំបីនដូចខ្លួនដែរ ។ ២ - ករុណា គឺជាការអាណិតអាសូរ ៣ - មុទិតាគឺជាដំណើរមានចិត្តរីករាយទៅនឹងសេចក្តីសុខរបស់អ្នកដទៃពុំរើសមុខ បើឃើញគេមានសេចក្តីសុខធំបីន ក៏មានចិត្តជួយអបអរ មិនមានចិត្តឈ្នានីស ៤-ឧបេក្ខា :គឺមានន័យថា អ្នកមានបំណងតែមួយ មានគោលដៅតែមួយ ។ នាបច្ចុប្បន្ននេះ បុគ្គលណាក៏មានបំណងចង់បានសន្តិភាពដែរ ។ ពោលសង្គ្រាម និយាយសិល្បៈឈប់ឬអ្វីៗទៀត ដែលជាចរាសប៉ុន្មានឆ្នាំក្រោយរបស់សង្គម ត្រូវជួបតែនឹងខិនភាពគ្មានអភិវឌ្ឍន៍ ។ ឧបេក្ខាគឺមានន័យប៉ុង្មានទៀតថា នរជនណាដែលមានសមត្ថភាពប្រឈមមុខទប់ទល់នូវភាពវិបល្លាសនៃជីវិតដោយស្ងប់ស្ងៀម ។

-យើងបានដកស្រង់គោលគំពីរសិល - វិន័យ ដែលស្តីអំពីការគោរពបូជារបស់មនុស្ស ចំពោះទិសទាំងបួននោះផ្លូវន័យដែលជាឱ្យសំរាប់បញ្ជាក់អំពីភារកិច្ចក្រតញ្ញូរបស់មនុស្សចំពោះគ្រួសារផ្ទាល់ ក៏ដូចជាសំរាប់អ្នកជិតខាងនិងសង្គមទាំងមូលដែរ ។ ភារកិច្ចទាំងបួនយ៉ាងនោះគឺពិតជាបង្កប់នៅក្នុងព្រះត្រៃបិដកស្ទះទាំងបួននៃកំពូលព្រហ្មទេពជាយូរមកហើយ ។ ទិសទាំងបួនត្រូវបានគេចាត់ទុកថា " ពិសិដ្ឋ " ដែលគួរជាទីគោរពបូជា ។ ១- ទិសខាងកើត គឺតំណាងអោយ មាតាបិតា ២- ទិសខាងត្បូងគឺតំណាងអោយគ្រូជាគ្រូអាចារ្យ ៣- ទិសខាងលិចគឺតំណាងអោយភរិយានិងកូន ៤- ទិសខាងជើង គឺ តំណាងអោយញាតិសន្តាន មិត្តភក្តិ និងអ្នកជិតខាង ។

១- មាតាបិតា ជាទីគោរពរបស់បុត្រធីតា ។ សព្វថ្ងៃនេះបុត្រធីតា តែងគោរពបូជាមាតាបិតាជានិច្ច។ បុត្រធីតាត្រូវតែមេត្តាករុណាកតញ្ញូកិច្ចចំពោះព្រហ្មនៃគ្រួសារយ៉ាងខ្ពង់ខ្ពស់ដែលទ្រាំទ្រគាត់ក្នុងពេលគាត់ជរា

---

៩៥ - មនុស្សធម៌ វប្បធម៌ និង ជីវិត ១៩៩៩ - ៨១ ។

ធ្វើអ្វីៗដែលចាំបាច់សំរាប់គាត់ រក្សាកិត្តិយសគ្រួសារតាមប្រពៃណីរបស់គាត់ រក្សាមរតកដែលគាត់រកបាន ធ្វើបុណ្យបញ្ជូនកុសលជាកិច្ចតបស្នងសងគុណអោយបានសមរម្យក្នុងពេលដែលគាត់អនិច្ចកម្មទៅនោះ ។ ឯមាតាបិតា ក៏ទទួលខុសត្រូវចំពោះបុត្រធីតាដូចតទៅៈ ដាស់តឿនកូនចៅកុំអោយប្រព្រឹត្តក្នុងផ្លូវខុស តំរែតំរង់ទៅរកសកម្មភាពល្អ និងមានប្រយោជន៍ ធានារ៉ាប់រងក្នុងការអប់រំរៀបចំកូនចៅអោយមានគូស្រករក្នុងគ្រួសារដែលល្អ ហើយនិងចែករំលែកទ្រព្យសម្បត្តិតាមកាលដ៏សមគួរ ។

២ -ទំនាក់ទំនងរវាងគ្រូបាធ្យាយ និងសិស្ស- សិស្សត្រូវគោរពគ្រូបាធ្យាយហើយ និងស្តាប់បង្គាប់ ។ ប្រសិនបើមាន សិស្សត្រូវផ្គត់ផ្គង់នូវរាល់សេចក្តីត្រូវការរបស់គ្រូបាធ្យាយ ត្រូវសិក្សារៀនសូត្រដោយព្យាយាម ។ ចំពោះគ្រូត្រូវបណ្តុះបណ្តាលអប់រំសិស្ស បង្រៀនសិស្សអោយល្អ ខិតខំផ្តល់សន្តិសុខ សំរាប់ការងារក្រោយការសិក្សារបស់សិស្ស ។

៣ - ទំនាក់ទំនងរវាងប្តីនិងប្រពន្ធ- សេចក្តីស្នេហាដែលតភ្ជាប់រវាងប្តី និងប្រពន្ធ ត្រូវបានគេចាត់ទុកថា " ពិសិដ្ឋ "ដែរ ។ គេអាចហៅម្យ៉ាងទៀតថា " សទារ-ព្រហ្មចរិយ " ដែលមានន័យថាជីវិតសំរាប់គ្រួសារពិសិដ្ឋ ។ ប្តីនិងប្រពន្ធត្រូវតែមានភក្តី គោរពគ្នានិងស្មោះត្រង់ ។ កាតព្វកិច្ច គឺត្រូវមានទៅវិញទៅមក : ប្តីត្រូវគោរពប្រពន្ធ គឺមិនត្រូវខ្វះការគោរពនេះបានឡើយ ត្រូវស្រឡាញ់និងមានភក្តីចំពោះប្រពន្ធ ត្រូវធានារ៉ាប់រងចំពោះការសុខទុក្ខរបស់ភរិយា ។ ម្យ៉ាងទៀតប្តីត្រូវចេះធ្វើអោយប្រពន្ធរីករាយចិត្តដោយជូនរង្វាន់ជាគ្រឿងអលង្ការផងទៀត ។ រីឯភរិយាវិញ គឺនាងត្រូវប្រុងប្រៀបកិច្ចការផ្ទះសំបែង រាក់ទាក់ចំពោះភ្ញៀវ មិត្តភក្តិ ញាតិសន្តាន និង និយោជិក ។ ភរិយាក៏ត្រូវស្រឡាញ់ប្តីនិងភក្តីចំពោះប្តីដែរ ហើយចេះថែទាំទ្រព្យសម្បត្តិដែលប្តីរកបាន និងប្រសប់ ហើយក្លាហានផងនៅក្នុងរាល់សកម្មភាព ។

**៤-ទំនាក់ទំនងរវាងមិត្ត-ញាតិសន្តាន និង ប្រៀងលាន- ក្នុងករណីនេះ អ្នកទាំងនេះត្រូវតែរាក់**ទាក់ ចិត្តទូលាយទៅវិញទៅមក ហើយសំដែងការស្រឡាញ់រាប់អានគ្នា និងរាក់ទាក់ ។ គេត្រូវតែបំពេញកិច្ចការទៅវិញទៅមកសំរាប់សុខមាលភាពរបស់គេ រាក់ទាក់ស្មើទៅស្មើមក មិនទាស់ទែងគ្នា ជួយជុះគ្នា និងមិនត្រូវបោះបង់គ្នាក្នុងគ្រាលំបាក ។

ក្នុងសង្គមកម្ពុជា អតីតកាល ក៏ដូចបច្ចុប្បន្នដែរ ប្រជាជនកម្ពុជាម្នាក់ៗ យ៉ាងហោចណាស់ ក៏

បានប្រកាន់ខ្ជាប់នូវសីលធម៌ជ្រាំយ៉ាងជាប្រចាំ មិនថាចាស់ឬក្មេងឡើយ ព្រោះសីលនេះជាផ្លូវនាំគេអោយទៅកាន់សន្តិភាព និងសុភមង្គលក្នុងជីវិត ។ គេតែងនឹកគិតថាគ្មានសង្គមណាដែលស្ថិតនៅក្រៅជីវិតបរិសុទ្ធ ដែលចាក់គ្រឹះនៅលើមូលភាពសីលធម៌និងស្មារតីបាន ដោយស្ថានភាពសម្ភារៈនិងសង្គមវាសមស្របដែរ ។ អំពើអសីលធម៌ហើយនិងឧក្រិដ្ឋកម្ម គឺពិតជាកើតចេញមកអំពីភាពទុគ៌តនិងសង្គមមានវណ្ណៈ ។ ផ្លូវសំរាប់នាំមនុស្សអោយមានសុភមង្គលក្នុងលោកិយ : ពុទ្ធសាសនិកតែងប្រកាន់នូវគាថានេះនៅក្នុងការស្វែងរកសុភមង្គលក្នុងលោកិយសព្វថ្ងៃនេះ ។ ផ្លូវទាំងនោះគឺ:

១-មនុស្សម្នាក់ៗ ត្រូវតែប្រឹងប្រែងនិងមានប្រសិទ្ធិភាព មានសមត្ថភាព និងក្លៀវក្លាក្នុងអាជីវៈរបស់ គេ ។ គេត្រូវតែមានម្ធ្យោបាយគ្រប់គ្រាន់សំរាប់ផ្គត់ផ្គង់របស់គេ ។

២- គេត្រូវរក្សាទ្រព្យធនដែលរកបានមកហើយ ដោយសារកម្លាំងពលកម្មរបស់គេ ។

៣- គេត្រូវមានមិត្តភក្តិល្អ ភក្តី មានការរៀនសូត្រមានគុណធម៌ មានចិត្តទូលាយ ហើយឆ្លាតវាងវៃ ។ មិត្តនោះគឺជាអ្នកដែលនាំគេអោយប្រកាន់តែផ្លូវទៀងត្រង់ ។

៤- គេត្រូវតែចំណាយទ្រព្យធនប្រកបដោយវិចារណញ្ញាណ ទៅតាមប្រាក់កាសដែលរកបាន គឺមិនច្រើនពេក ហើយក៏មិនតិចពេក គេមិនត្រូវប្រកាន់ភាពកំណាញ់ស្វិត ។ គេត្រូវតែរស់នៅដោយពលកម្ម និង មធ្យោបាយផ្ទាល់របស់គេ ។

សច្ចៈធម៌អមតៈ-

" កំហឹងមិនដែលរំងាប់ដោយកំហឹងទាល់តែសោះ ។ ក៏ប៉ុន្តែវាអាចរំងាប់បានដោយសារមេត្តាធម៌ ។ នោះគឺជាសច្ចៈធម៌អមតៈ " ។

" គេត្រូវតែឈ្នះកំហឹង ដោយសារមេត្តាធម៌ ឈ្នះកំណាច ដោយអំពើល្អ ឈ្នះកំណាញ់ ដោយសប្បុរសធម៌ ហើយនិងឈ្នះកុហក ដោយនិយាយត្រង់ហើយពិត " ។

" អ្នកឈ្នះ បណ្តាលអោយកើតកំហឹង ហើយអ្នកចាញ់ត្រូវធ្លាក់ទៅក្នុងភាពក្រីក្រ ។ នរណាម្នាក់ ដែលបោះបង់ជ័យជំនះ ហើយនិងបរាជ័យ គឺតែងរីករាយនិងស្ងប់ " ។

" ជ័យជំនះតែមួយគត់ដែលនាំមកនូវសន្តិភាព និង សុភមង្គល គឺជាជ័យជំនះលើខ្លួនឯង អ្នកដែលឈ្នះ ខ្លួនឯង អ្នកនោះគឺប្រសើរជាងគេនៃពពួកអ្នកឈ្នះទាំងឡាយ " ។

# ពាក្យសព្ទពិសេសប្រើប្រាស់ក្នុងសៀវភៅនេះ

« ក » :

គ្រូម៉ាញ៉ុង : ពូជមនុស្សមុនប្រវត្តិ ក្នុងយុគសម័យថ្មបំបែក ភាគខាងលើ ពិសេសគឺ ពូជនៅអឺរ៉ុប មានជំនឿ មានសិល្បៈ - រស់នៅជាក្រុមៗ - ជីវភាពរស់នៅ គឺការបរបាញ់សត្វ - ជំរក ល័ល្អាងភ្នំ ។

កុលាលភាជន៍ : គ្រឿងធាន - ក្អម - ឆ្នាំង ។ល។

កាឡី : សក្តិរបស់ព្រះសិវៈ។ កាឡីប្រែថា " ខ្មៅ "

កោះកែរ : ឈ្មោះរបស់ក្រុមប្រាសាទកសាងក្នុងសម័យជ័យវរ្ម័នទី ៤ ក្នុង ខេត្តកំពង់ធំ ទសវត្ស ទី ១០ : ពីឆ្នាំ ៩២១ - ៩៤៤ គ.ស.។

គ្រឡោត - ទាម " ក្បាច់ " ចម្លាក់រាងៗ នៅលើជញ្ជាំង ឬសសរ តាមចណ្ដាប្រាង្គប្រាសាទ ក្នុងសម័យ មុនអង្គរ - អង្គរ និង ក្រោយអង្គរ ។

« គ »

គ្រីម៉ាល់ឌី : សូមមើល ពូជ គ្រូម៉ាញ៉ុង ។

គីរ្តិមុខ : មុខអាក្រក់ដូចខ្មោច - ប្រាសាទភាគច្រើនមានគីរ្តិមុខជាប្រាសាទ សាងឡើងសំរាប់ កប់ខ្មោច " ប្រាទសតន្ត្រូលោស៊ី បុរាណកាល " ។

គូ : ពាក្យខ្មែរបុរាណកាល សំដៅយកស្រះទឹកធំៗ - ឬប្រឡាយដែលគេជីក ព័ទ្ធជុំវិញប្រាសាទបុរាណ។

គោបុរៈ : ក្លោងទ្វារធំៗចូលទៅកាន់ប្រាសាទ ។

គិរី : ភ្នំ

គូលែន " ភ្នំ " : ឈ្មោះភ្នំដែលស្ថិតនៅភាគខាងជើងខេត្ត សៀមរាប ដែលជាកន្លែង យកថ្មភក់ កសាងប្រាសាទនាសម័យអង្គរ ហើយក៏ជាប្រភពធំនៃ អារ្យធម៌អង្គរដែរ នេះគឺនរៈប្រជាជនបានកសាងប្រាសាទជាច្រើន ។

« ជ »

ជាតិពន្ធុវិទ្យា : សិក្សាពីរឿងរ៉ាវពីពូជសាសន៍មនុស្ស ។
ជីវក្ខ : សត្វមានជីវិត ។

« ឌ »

ដុលម៉ិន : ស្ពានក្បកឬសារមញ្ញូពីថ្មធំៗ សាងឡើងសំរាប់កប់ខ្មោច ។ គេជីកបញ្ចុះថ្មឯង កប់នៅក្នុងដី រាងវង់មណ្ឌល ។ គេបញ្ចុះខ្មោច នៅចំកណ្តាលវង់មណ្ឌលនោះ ។

« ឋ »

ឋាបរិក : អ្នកសាងសង់ ។

« ណ »

ណេអង់ឌែរតាល់ : ពូជមនុស្ស - ស្វា កើតឡើងក្នុងយុគ្គសម័យថ្មបំបែក ភាគកណ្តាល ។ មានជំនឿ - ចេះ កប់ខ្មោច ។
ណេគ្រីតូ : ពូជមនុស្សខ្មៅ - មានរូបរាងតូច ក្បាលមូល សក់រួញក្រញាញ់ សម្បុរខ្មៅ រស់នៅក្នុងកោះ អង់ដាម៉ង់ ក្បែរកោះស៊ុមម៉ាត្រា ។

« ត »

តប: : ពិត . ដាក់ណាត់ .

« ថ »

ថាននិយកម្ម : ការតាំងផ្ទាត់ តាមទំលាប់ចំណោម ។
ថ្មកក់ : ថ្ម ដែលកកើតឡើងអំពីសារពាង្គកាយដែលខ្សោះឬពិធនិងស៊ីម៉ង់ធម្មជាតិ ។ ថ្មនេះត្រូវបានប្រជាជនសម័យបុរាណកកស់រាប់កសាងប្រាសាទ ។

« ទ »

ធម្មតា : ច្បាប់, គោលការណ៍ ,

« ន »

នរវិទ្យា : សិក្សាអំពីមនុស្ស .

ម៉ិនហៀរ : ដូច ដុលម៉ិន ប៉ុន្តែគេដាំក្បាំថ្មធំៗ ទៅក្នុងដី តាមរយៈខ្សែបណ្តោយ ។

និម្មិតកម្ម : ការច្នៃប្រឌិត បង្កើតរឿង ។

និរប្រវេសន៍ : ការចាកចេញអំពីប្រទេសរបស់ខ្លួន តំបន់របស់ខ្លួន ដើម្បីទៅរស់នៅ ក្នុងតំបន់មួយ ប្រទេសមួយ ផ្សេងទៀត ។

នេត្រាទស្សន៍ : រូបមន្តបង្កើតឡើងក្នុងសម័យអាក្សេធវី បេស្តូប៉ូតាមី ដើម្បីបង្ហាញរូប

ភាពមួយនៅលើផ្ទៃសំប៉ែត : រូបជិតមើលឃើញធំ រូបឆ្ងាយមើលឃើញតូច , ទាប ហើយរហូត ដល់តំណុចមួយ ។

« ប »

បាសាណវិទ្យា : វិទ្យាសាស្ត្រដែលសិក្សាអំពី រាល់វត្ថុធាតុដែលកប់នៅក្នុងដីអស់រាប់ សែនលានឆ្នាំហើយដែលក្លាយភាពដើមរបស់វា ទៅដូចជាសិលាធាតុ ។

ប្រាសាទសាជី : ប្រាសាទដែលកសាងឡើងមានសណ្ឋាន ជាជាន់ថ្នាក់ ធំក្រោម ហើយ ស្រួចលើ ដូចជាប្រាសាទ អង្គរវត្ត - បាយ័ន ។ល។

បុរេប្រវត្តិ : ប្រវត្តិសាស្ត្រដែលអធិប្បាយអំពីប្រវត្តិសាស្ត្រមនុស្សជាតិតាំងពីរាប់ លានឆ្នាំមក ហើយ ។

បដិមាសាស្ត្រ : រឿងរ៉ាវទាក់ទងដល់ អាទិទេព , វីរជនដែលត្រូវបានគេយកមកបង្ហាញ តាមរយៈ សិល្បៈ ។

បដិមា សិល្បៈ : សិល្បៈខាងឆ្លាក់ បណ្តាបដិមាផ្សេងៗ ។

ប្រាសាទ - ភ្នំ : ស្មើនឹងប្រាសាទសាជី ។

ប្រទក្សិណ : ដើរព័ទ្ធជុំវិញវត្ថុជាទីសក្ការៈដោយទុកអោយវត្ថុនោះស្ថិតនៅខាងស្តាំ ដៃជានិច្ច ដើរប្រទក្សិណព្រះវិហារ ។ល។

ប្រសវ្យ : ដើរព័ទ្ធជុំវិញវត្ថុជាទិសក្ខរៈដោយទុកអោយវត្ថុនោះស្ថិតនៅខាងឆ្វេងដៃ ពិធីដង្ហែសព ។

បារាយណ៍ : ផ្ទៃទឹកដែលគេទប់សំរាប់ប្រើប្រាស់ ដោយលើកទំនប់ខ្ពស់ៗព័ទ្ធជុំវិញ : បារាយណ៍ខាងកើត បារាយណ៍ខាងលិច ។ ល ។

« ផ »

ផ្តែទ្វារ : សមាសធាតុសំខាន់ក្នុងស្ថាបត្យកម្ម ។ ផ្តែទ្វារ គឺសិលាមួយផ្ទាំងមានរចនាក្បាច់ និងរឿងទេវកថា តាមរចនាបថនីមួយ ៗ ។ គេដាក់នៅពីលើទ្វារចូលទៅកាន់ប្រាសាទ ឬ គ្រប់ទ្វារនៅតាមបណ្តាច្រកចូលនានា ។

« ព »

ព្រហ្មន៍ : អាទិទេពធំតែមួយគត់ក្នុងលទ្ធិព្រហ្មនិយម ។

ពោធិសត្វ : អនាគតព្រះពុទ្ធ ។ លោកេស្វរៈជាពោធិសត្វរបស់ពុទ្ធសាសនាមហាយាន ។

« ភ »

ភូគព្ភសាស្ត្រ : សិក្សាអំពីការកកើតរបស់ភូគោល " ផែនដី " ។

« ម »

ម៉ិន ហៀ : សូបាហ៊ីល ដុល ម៉ិន

មាតាធិបតេយ្យ : ជំនឿមួយនៅអាស៊ី អគ្នេយ៍ ដែលគេអោយតម្លៃទៅលើស្ត្រី ជាធំ ក្នុងអារ្យ ធម៌ដែលយកកសិកម្មជាធំ ហើយមានជំនឿទៅលើព្រះច័ន្ទ ។

មេព្យាទិស : ខ្សែបន្ទាត់ដែលចុះពីចំណុចកណ្តាលវត្ថុធាតុ " សំណង់ " តាមទិសធំៗ : កើត លិច ជើង ត្បូង ។ គេប្រើនៅក្នុងគណិតវិទ្យា ។

មករ : សត្វទឹកមានជើង និងប្រមោយ ។ វាមានតម្លៃស្មើនិង សត្វនាគ និង ក្រពើ ។

មហេន្ទ្របព៌ត : មកពីមហា " ធំ " + ឥន្ទ្រ " ព្រះឥន្ទ " + បព៌ត " ភ្នំ " : ជាឈ្មោះរបស់ ភ្នំ គូលែន ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី ២ ។

មូលធបី : មូលដ្ឋាននៃចំណេះ , ត្រិះ , មូលហេតុ ។

បនោរិកត៌ : ការសេបសូន - ស៊ុសង្វាក់ ។

មេរុ : តាមលោកទស្សនៈចាស់ មានន័យថា ជាភ្នំមានកំពូល ៥ ស្ថិតនៅចំកណ្តាលចក្រវាឡ ។

« រ »

រូបវិវត្ត : ការប្រែប្រួលរចនាសម្ព័ន្ធនៃសិលាជាតិ ដោយសំពៀតអាកាសធាតុ កំដៅ ឬដោយ ឧស្ម័ន ភ្នំភ្លើង ក្នុងពេលវារស់សកម្មភាពទៅ ។

រតនប័យ : គ្រឿងលំអរផលិតអំពី លោហៈ មាស ឬ ប្រាក់ ដោយជាងទង ។

រាហូ : ជាឈ្មោះផ្កាយទី ៨ ក្នុងពួកតារាគពទាំង ៩ ក្នុងក្បួនហោរាសាស្ត្ររបស់ខ្មែរ ។ រាហូ ក៏មានរឿងរ៉ាវនៅក្នុង រឿង កូរសមុទ្រទឹកដោះដែរ ។ រាហូ ជាក្បាច់ដែលខ្មែរយកមកតំណាង ឱ្យ កម្លាំង " អមតៈ " នៅក្នុង សិល្បៈតុបតែងលំអ ។

រូបីយ៍ : មានរូប ។ ជាក់ស្តែង

រាម " ព្រះ " : ជាអវតាររបស់ព្រះវិស្ណុ ក្នុងរឿងរាមកេរ្តិ៍ ។

« ល »

លទ្ធិ ជីវពល : ជឿថាអ្វីៗ សុទ្ធតែមានអាត្មន " ព្រលឹង " ។

លោកេស្វរៈ : ពោធិសត្វ ចិត្តមេត្តា នៃ ពុទ្ធសាសនា មហាយាន " យានធំ " ។

« វ »

វិទ្យុសកម្មសេ ១៤ : ឧបករណ៍ប្រើប្រាស់ក្នុងបុរាណវិទ្យា សំរាប់វាស់វែងអាយុកាលនៃវត្ថុធាតុ ។ ឧបករណ៍នេះ អាចវាស់ដោយគិតល្បឿង ក្នុងអាយុចាប់តាំងពី ៣០.០០០ ឆ្នាំ ចុះក្រោម ។

វរ្ម័ន : អ្នកការពារ : ឧ . ជ័យវរ្ម័ន គឺអ្នកការពារជ័យជំនះ។
វិស្វករម្ម័ន : ស្ថាបត្យករថានសួគ៌។ កូនរបស់ព្រះសិវៈ។
វ្រ័ត : មានរាងកោងដូចស្រទបចេក : ឧ. ជំបូលរាងវ្រ័ត។

« ស »

ស្តូវាកម្ម : ស្រទាប់សំបកផែនដី " ផ្នែកខាងលើ "។
សមប្បមាណ : ស្មើគ្នា ដោយយក ចំណុចមួយ ឬ តំនូសមួយជាគោល ( SYMETRIE ).
សិល្បាបូណ៌សាស្ត្រ សោភ័ណ។
សារីរច្ឆេទនសាស្ត្រ : ការសិក្សាអំពីរចនាសម្ព័ន្ធរបស់រាងកាយ ។
សាធូ : សំណង់ ធំៗ ក្នុងបច្ឆិមសម័យនៅអឺរ៉ុប របស់ពួកសក្តិភូមិ អភិជន អ្នកបួស ដែលមាន ប្រព័ន្ធការពារយ៉ាងស្មុគស្មាញណាស់ ។
សមតា : ស្មើគ្នា ( equilibre )
សិន្ធុ : សមុទ្រ
សសរពេជ្រ : សសរទ្រផ្តែរទ្វារក្នុងប្រាសាទ ប្រកបដោយក្បាច់រចនាតាម រចនាបថ និមួយៗ។
សៃលេន្ទ្រ : រាជវង្សនៃកោះជ្វា សម័យជំនាលគ្នានឹងចិនឡា របស់កម្ពុជា។
សទ្ធា " ទិរេះ" : ការទុកចិត្តលើ
សន្ទេហវិធី : វិធីធ្វើអោយមនុស្សនិកជនមានការសង្ស័យ ហើយធប់ពឹង។

« ហ »

ហីនយាន : យានតូចៈជានិកាយរបស់ពុទ្ធសាសនា ថេរវាទ ដែលផ្សព្វផ្សាយពីកោះសេរីលង្កា តួងតាមអារ្យធម៌ មន។
ហរិៈ : ព្រះវិស្ណុ
ហរៈ : ព្រះសិវៈ
ហរិហរៈ : វិស្ណុ និងសិវៈ ស្រាបរួមគ្នាតែមួយ។

« ឡ »

ឡាប៊ីរ៉ាំង : ផ្លូវដែលមានប្រព័ន្ធស្មុគ្រស្មាញបំផុត ។

« អ »

អរូបីយ៍ : គ្មានរូប ‑ ស្ថិតក្នុងក្តីស្រមៃ ។

អូស្ត្រូណេសូអ៊ិត : អាប្រចបិអាស៊ីអាគ្នេយ៍ ដែលឈរលើលក្ខណសម្បត្តិ ៣ ធំៈ
១ ប្រើប្រាស់ធ្នូ
២ មាតាធិបតេយ្យ ៣ ជំនឿលើតួតែប " លទ្ធិព្រលឹង " ។

អាករទិធិ : ស្រទាប់រ៉ែនៅក្នុងដី ។

អាត្មន៍ : ពាក្យសំស្ក្រឹត មានន័យថា ព្រលឹង ។

អបតៈ : មិនចេះស្លាប់

អាករ : ទម្ងន់ទាំងមូលរបស់វត្ថុធាតុ

អធិបោក្ខ : ការប្តេជ្ញា ‑ ការកំណត់

អប្សរា : នាដករីថានសួគ៌

« ឥ »

ឥស្សរបុរៈ : បុរីរបស់សេវៈ បុរីរបស់អាទិទេព ។

ឥន្ទ្រ : អាទិទេពព្រាហ្មណ៍សាសនា ។ ជាអាទិទេពតំណាងរន្ទះ និងព្យុះភ្លៀង ។
ជិះលើដំរីក្បាលបី ឈ្មោះថា ឰរ៉ាវ័ន្ត ។

« ឱ »

ឱម៉ា : សក្តិរបស់ព្រះសិវៈ ។

# មាតិការឿង

## ជំពូកមួយ

### សិក្សាបុរាណវិទ្យា


| | | ទំព័រ |
|---|---|---|
| I - | អ្វីទៅហៅថាវិធានប្រវត្តិសាស្ត្រ ? | ៥ |
| ១.១. | តួលេខនៃវិធានប្រវត្តិសាស្ត្រ | ៧ |
| ១.២. | សិល្បារម្មណ៍សាស្ត្រ ប៉ាក្សទិយប | ៨ |
| ១.២.៤. | តើពាក្យកម្ពុជា ចេញមកពីណា ? | ១១ |
| ១.៣. | នវសិលារបស់ប្រជាជនកម្ពុជា | ១៤ |
| ១.៤. | វប្បធម៌សម្ភារៈឆ្លុះបញ្ចាំងអំពីទំនាក់ទំនងជាមួយពិភពក្រៅ | ១៧ |
| ១.៥. | ព្រលឹងឆ្លុះបញ្ចាំងតាមស្នាដៃសិល្បៈ | ១៩ |
| II - | ទិន្នាការសិល្បៈខ្មែរ | ២៥ |
| ២.១. | វិស័យបដិមាសិល្បៈ | ២៥ |
| ២.២. | វិស័យស្ថាបត្យកម្ម | ៣៦ |
| **២.៣.** | **ប្លង់សំខាន់ពីរ ក្នុងសំណង់ប្រាសាទ** | **៤៤** |
| ២.៤. | ការវិវត្តន៍របស់ប្រាសាទ | ៤៧ |

# ជំពូកពីរ

## សារៈសំខាន់របស់ប្រាសាទខ្មែរ


| | | ទំព័រ |
|---|---|---|
| III. | តម្លៃពិតរបស់ប្រាសាទ | ៥៦ |
| ៣.១. | តម្លៃខាងនិមិត្តរូប | ៥៦ |
| ៣.២. | តម្លៃសិល្បៈចំពីប្រយោជន៍ | ៥៨ |
| ៣.៣. | តម្លៃសិល្បារម្មណ៍សាស្ត្រ | ៦០ |
| ៣.៤. | សញ្ញាណសារវត្ថុ– ការបង្រួបបង្រួម ក្នុងទំរង់ស្ថាបត្យកម្ម | ៦២ |
| IV. | វឌ្ឍនាបថសំខាន់ៗ ក្នុងសិល្បៈស្ថាបត្យកម្ម របស់វិមានប្រវត្តិសាស្ត្រ | ៦៥ |
| V. | ទស្សនៈអំពីសំណង់ | ៧៨ |
| ៥.១. | សំណង់សំរាប់មនុស្សនិងសង្គម | ៧៨ |
| ៥.២. | អស្ចារ្យ! ក្នុងសិល្បៈស្ថាបត្យកម្ម | ៨២ |
| | សាសនា | ៩១ |
| | សីលធម៌របស់សាសនា | ៩៥ |

## គន្ថនិទ្ទេស


គូវ៉ាល់ បេហ្សយហ្សា : ការវិវត្តន៍របស់ផ្លែទ្វារ ទស្សនាវដ្ដីសិល្បៈអាស៊ី -ក្បាលទី ១៣,៤.

កាប៉ាឡេស្វា គត្ដភរិយា : ព្រហ្មញ្ញសាសនានៅក្នុងកម្ពុជាអតីតកាល- ១៩៦១.

កម្ពុជា : សៀវភៅបោះពុម្ពផ្សាយ ដោយក្រុមហ៊ុនបោះពុម្ព កុងទីណង់តាល់- ហុងកុង .

កាហ្សីតភ័រ " ហ្សង់" : ជាតិពន្ធុវិទ្យា ឆ្នាំ ១៩៦៧ .

ជាវ តាតួន : សារណាអំពីទម្លាប់របស់ប្រជាជនកម្ពុជា ទាសតវត្ស ទី ១៣.

ផូហ្វាំង ប៊ុទីញេ : ប្រវត្តិវិទ្យាប្រទេសកម្ពុជា .

ទីភ្នាក់ងារសារពត៌មានណូវ៉ូស្ទី : វប្បធម៌- ១៩៨៧ .

ទស្សនាវដ្ដី : វប្បធម៌ និងជីវិត- លេខ ៥ -៨៦. បោះពុម្ពនៅសហភាពសូវៀត .

នាយកដ្ឋាន អ. ស.ទ. : បញ្ជីវិកានប្រវត្តិសាស្ត្រ- សន្និបាតប្រចាំឆ្នាំ ១៩៨០.

នគរខ្មែរ : ទស្សនាវដ្ដីប្រចាំត្រីមាសលេខ ៣.១៩៧០

ប្រូហ្វេស. អង្គការបោះពុម្ពផ្សាយ - ប៉ូស្ដ : ប្រវត្តិសង្ខេបនៃប្រទេសកម្ពុជា

ប៊ីស៊ីលីយេ " ហ្សង់ " : អាស៊ី- អគ្នេយ៍-ប្រទេសកម្ពុជាក្បាលទី១

ប៊ីស៊ីលីយេ " ហ្សង់ " : និទ្ទាការសិល្បៈខ្មែរ- ការបោះពុម្ពផ្សាយរបស់សារៈមន្ទីរគីមេ ក្បាល ១២

ប៉ូលប៉ែលលីយ៉ូត : សារណាអំពីទម្លាប់កម្ពុជា របស់ជាវតាតួន ១៩៥១ .

ប៊ូរីស ផ្លែហ្ស : ប្រាង្គប្រាសាទក្នុងក្រុងអង្គរ - ១៩៦៣

ម៉ាដឺឡែន ហ្សិត្ដ : ប្រជាជនមួយ សិល្បៈមួយ

ម៉ារុយ បេនិស្ស : ទំនាក់ទំនងរវាងសិល្បៈខ្មែរដំបូង និង សិល្បៈ ឥណ្ឌា- សាលាចុងបូព៌ាប្រទេស ១៩៧០ .

រ៉ឺណេ ប៊ិត : សិល្បៈ និងមនុស្ស ១៩៥៧ .

ល្វីស ម៉ាឡេរ : បុរាណវិទ្យាក្នុងដែនដីសណ្តរនៃទន្លេមេគង្គ១៩៥៨.

វ. ជាលីស : មនុស្សនិងគំនិត-ការបោះពុម្ពផ្សាយប្រូហ្វ្រេស .

វចនានុក្រមសំស្ក្រឹត- បារាំង : បោះពុម្ពឆ្នាំ ១៩៧២.

ស៊ីស៊ីល និង រ៉ូឡង់ម៉្រ៉ី : ខេត្តបាត់ដំបង - ប្រទេសកម្ពុជា-បុរាណវិទ្យា និង នរវិទ្យា រូបនិយម. ក្នុងអ្នកសេអានិ ក្បាលទី ៤ លេខ ២ ខែកក្កដា ១៩៨២ .

សឺដែស : ព្រេនានាទទួលវប្បធម៌ឥណ្ឌារបស់ឥណ្ឌូចិន និងឥណ្ឌូនេស៊ី .

សឺដែស : ដើម្បីយល់អង្គរអោយកាន់តែច្បាស់.

សាលាចុងបូព៌ាប្រទេស : សិលាចារិកពីរ នៃសម័យបុរាណ ក្បាល ៣១ .

ហង់រី ម៉ារសាល់ : ក្បាច់រចនា និងចម្លាក់ខ្មែរ- ក្បាលទី ៣ ១៩៥១.

ហង់រី ម៉ារសាល់ : វត្ថុបុរសក៍ អង្គរថ្មី- ១៩៦១ .

ហង់រី ម៉ារសាល់ : សមុច្ច័យខ្មែរ- សាលាចុងបូព៌ាប្រទេស ១៩៣៩.

ហង្សី ម៉ារសាល់ :ព្រឹត្តិប័ត្រសមាគមសិក្សា អំពីឥណ្ឌូចិន- ក្បាល ១១.១៩៣៦.

ហ្វ្រង់ស្វា ម៉ារទីនី : អត្ថបទសំរាំងនៅលើភាសាវិទ្យាខ្មែរ-មជ្ឈមណ្ឌលឯកសារសហោគារ និងស្រាវ ជ្រាវសាកលវិទ្យាល័យភ្នំពេញ- ១៩៧១.

ហ្គា ម៉ារីយ៉ុង : ប្រវត្តិសិល្បៈទូទៅ- ១៩៥០.

ហង្សី ជ៉ាប៉ង់ទេ : វត្ថុបុរសក៍ទៅកាន់អង្គរ- ភ្នំពេញ- កម្ពុជា .

វ៉ាល់ បូឡា រាហុល : ការអប់រំរបស់ព្រះពុទ្ធ- ការបោះពុម្ពផ្សាយរបស់ ស៊ីយ - ១៩៦១ .



ផ្តែរទ្វាររចនាបថ សំបូរព្រៃគុក : បង្ហាញស្លាកស្នាមនៃក្បាច់រចនាឥណ្ឌា
សត្វមករ រំយោលទងផ្កា : ប្រាសាទ កសាំងនា ស.វ.ទី ៧ ។



រូបលើ : ផ្តែរទ្វាររចនាបថព្រៃក្មេង-ស.វ.ទី ៧-



រូបក្រោម : ផ្តែរទ្វាររចនាបថ កំពង់ព្រះ -ស.វ.ទី ៨-



រូបលើ : ផ្តែរទ្វាររចនាបថ គូលែន- ដើម.ស.វ ទី ៩.
បង្ហាញការកសាងកម្លាំងទ័ពក្នុងបំណងការពារជាតិ ។



រូបក្រោម : ផ្តែរទ្វាររចនាបថ បាខែង-ដើមស.វ.ទី ១០

## ទំព័រ ឃ



រូបលើ ៖ ផ្តែរទ្វាររចនាបថ កោះកែរ- ពាក់កណ្តាល ស.វ.ទី ១០ ។



រូបក្រោម ៖ ផ្តែរទ្វាររចនាបថ ប្រែរូប-ចុង ស.វ ទី១០ ។



ឧបករណ៍ បុរេប្រវត្តិ ល្អាងស្ពាន : ប្រជាជនកម្ពុជាមកតាំងទីនៅទីនេះប្រមាណ ៤០០០ ឆ្នាំ មុន គ.ស ។